Theology on the Web.org.uk

Making Biblical Scholarship Accessible

This document was supplied for free educational purposes. Unless it is in the public domain, it may not be sold for profit or hosted on a webserver without the permission of the copyright holder.

If you find it of help to you and would like to support the ministry of Theology on the Web, please consider using the links below:

Buy me a coffee https://www.buymeacoffee.com/theology

PATREON https://patreon.com/theologyontheweb

PayPal https://paypal.me/robbradshaw

---

A table of contents for *Honeycomb* can be found here:

https://biblicalstudies.org.uk/articles_honeycomb.php

# សំណុំទឹកឃ្មុំ

# Honeycomb

ព្រឹត្តិបត្រទេវសាស្ត្រខ្មែរ ផ្តល់នូវចំណេះដឹងផ្នែកព្រះគម្ពីរដល់លោកអ្នក
ប្រៀបដូចជា ទឹកឃ្មុំ ផ្តល់កម្លាំងដល់អ្នកដំណើរដែលកំពុងខ្សោយល្វើយ ។

A Khmer Theological Journal to give biblical knowledge to its readers as a honeycomb gives strength to exhausted travelers.

---

**Vol. 1, No. 1** **July 2000**

## From the Editor

*Honeycomb* is a new journal by and for the church in Cambodia. We thank God for his medium in which its leaders can discuss and debate issues of theology and practice. May it prove a stimulus for thought, fuel for devotion, and a prod to action.

Its articles are published in both Khmer and English. The language in which the article is first printed is that in which the article was submitted. This issue's articles were all submitted in English; we pray that soon works penned in Khmer will dominate the journal. Not that there is rivalry; national and expatriate believers are working side by side in Cambodia's ministry.

A journal is a forum for discussion. Not all readers will agree with everything written in it, just as all its contributors do not see eye to eye in all details. That is O.K. We are committed together to the central message of the Christian faith—that God exists, that the Bible is His Word, and that God has uniquely revealed Himself in the life, crucifixion, and resurrection of Jesus of Nazareth. These articles are designed to stir up thinking; a reader who disagrees is encouraged to submit an article and explain why!

May God use this journal for His glory and the spread of His kingdom.

# ចេញពីបណ្ណាធិការ

សំណាំទឹកឃ្មុំ គឺជាព្រឹត្តិបត្រមួយថ្មី សំរាប់ជួយពង្រឹងដល់ក្រុមជំនុំនៅប្រទេសកម្ពុជា ហើយនិងរៀបចំឡើង ដោយក្រុមជំនុំនៅប្រទេសកម្ពុជាដែរ ។ យើងអរព្រះគុណព្រះជាម្ចាស់ចំពោះកិច្ចការនេះ ដែលអាចឲ្យអ្នកដឹកនាំក្រុមជំនុំពិភាក្សាគ្នា និងអាចជជែកវែកញែក ពីរឿងរ៉ាវជាច្រើនស្តីពីផ្នែកទេវសាស្ត្រ ហើយនិង ស្តីពីទម្លាប់នៃការប្រព្រឹត្តផ្សេងៗ ។ សូមឲ្យព្រឹត្តិបត្រនេះបង្ហាញឲ្យមានការជំរុញដល់គំនិត ជួយផ្តល់កម្លាំងដល់ការចូលគាល់ព្រះ ដោយប្រើព្រះគម្ពីរ ហើយនិងជួយឲ្យមានសន្ទុះចំពោះសកម្មភាពការងារផ្សេងៗទៀតផង ។

អត្ថបទនៅក្នុងព្រឹត្តិបត្រនេះ គឺបោះពុម្ពជាពីរភាសា ខ្មែរ និង អង់គ្លេស ភាសាដែលយើងបោះពុម្ពមុនគេ គឺដោយព្រោះអត្ថបទនោះបានបញ្ជូនមកដល់មុន។ យើងអធិស្ឋាន សូមឲ្យអត្ថបទទាំងឡាយបានសរសេរជាភាសាខ្មែរ ក្នុងពេលឆាប់ៗនេះ នឹងផ្តល់ឲ្យភាសាខ្មែរមានចំនួនច្រើនលើសលប់នៅក្នុងព្រឹត្តិបត្រនេះ ។ ចំពោះរឿងនេះមិនជាការប្រកួតប្រជែងគ្នាឡើយ ពួកអ្នកជឿថ្នាក់ជាតិ និងបរទេសធ្វើការប្រកៀកស្មាគ្នា នៅក្នុងព័ន្ធកិច្ចបំរើព្រះក្នុងប្រទេសកម្ពុជា ។

ព្រឹត្តិបត្រ គឺជាវេទិកា សំរាប់ពិភាក្សា ។ មិនមែនអ្នកអានទាំងអស់នឹងយល់ស្របទាំងស្រុងតាមអ្វីៗ ដែលបានសរសេរនៅក្នុងព្រឹត្តិបត្រនោះ ក៏ដូចគ្នាដែរនឹងអ្នក ដែលបានរួមបរិច្ចាគទាំងអស់ មិនបានពិនិត្យមើលឲ្យបានល្អិតល្អន់ក្បោះក្បាយទាំងអស់ដែរ ។ តែមិនអីទេ យើងស្ម័គ្របួរផ្តាច់ជាមួយគ្នាដោយ ប្រកាន់យកព្រះរាជសារនៃជំនឿគ្រីស្ទបរិស័ទ គឺថាមានព្រះជាម្ចាស់ព្រះគម្ពីរគឺជាព្រះបន្ទូលរបស់ព្រះជាម្ចាស់ ហើយនិងជឿថាព្រះបានបើកសម្តែងរូបអង្គទ្រង់នៅក្នុងជីវិតមួយដ៏ពិសេស ក្នុងការរងទុក្ខដោយគេឆ្កាង និង ការរស់ឡើងវិញរបស់ព្រះយេស៊ូ អ្នកស្រុកណាសារ៉ែត ។ អត្ថបទទាំងឡាយនេះ សរសេរឡើងដើម្បី បំផុសគំនិត ចំពោះអ្នកអានដែលមិនព្រមយល់ស្របតាមអត្ថបទណាមួយនោះ យើងសូមលើកទឹកចិត្តឲ្យសរសេរជាអត្ថបទដាក់មក ហើយនិងពន្យល់ពីមូលហេតុ ដោយព្រោះហេតុអ្វីផង !

សូមឲ្យព្រឹត្តិបត្រនេះបានលើកសិរីរុងរឿង និងពង្រីកអាណាចក្ររបស់ព្រះជាម្ចាស់នៃយើង ។

*Honeycomb* is published by Training of Timothys
Central Post Office, P. O. Box 479, Phnom Penh, Kingdom of Cambodia
phone (855) 23 216052. fax (855) 23 216220.
email Russell_Bowers@wvi.org

editor, Russell H. Bowers, Jr.
translation, Uon Seila
technical support, Luy Peou

Manuscripts and communications should be addressed to the editor.
Printed in Phnom Penh, Kingdom of Cambodia.

គម្រោងកម្មវិធីហ្វឹកហ្វឺន ធីម៉ូថេ បានបោះពុម្ពព្រឹត្តិបត្រ *សំណុំទឹកឃ្មុំ* នេះឡើង
ទាក់ទងតាមការិយាល័យប្រៃសណីយ៍ ប្រអប់សំបុត្រលេខ ៤៧៩ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទលេខ (៨៥៥) ២៣ ២១៦០៥២ ទូរសារលេខ (៨៥៥) ២៣ ២១៦ ៤២០
សារអេឡិចត្រូនិច: Russell_Bowers@wvi.org
បណ្ណាធិការ Russell H. Bowers, Jr.
ផ្នែកប្រែសម្រួល: អ៊ួន សិលា
ផ្នែកបច្ចេកទេស: លុយ ពៅ
សំណេរអត្ថបទ និង ការទាក់ទង ត្រូវដាក់ជូនមកបណ្ណាធិការ
បោះពុម្ពនៅទីក្រុងភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

VOLUME 1 JULY 2000 NUMBER 1

# Honeycomb

**Forgiving Those Who Trespass Against Us** 1

*Russell H. BOWERS, Jr.*

**ការអត់ទោសចំពោះអស់អ្នកដែលធ្វើបាបប្រឆាំងនឹងយើង** ១១

*ដោយ លោក រ៉ស់ បាវើស៍*

**Wholistic Ministry and Mission** 24

*Graham CHIPPS*

**ព័ន្ធកិច្ច និង បេសកកម្មគ្រប់ជ្រុងជ្រោយ** ៣២

*ដោយ លោក ហ្គ្រាម ឈីប*

**Translating the Bible into Khmer** 43

*Arun SOK NHEP*

**ការបកប្រែព្រះគម្ពីរជាភាសាខ្មែរ** ៤៧

*ដោយ លោក សុខ ញឹបអរុណ (បកប្រែពីភាសាអង់គ្លេសដោយ លោក អ៊ួន សិលា)*

**Cambodian Youth in the New Millennium** 53

*Brian MAHER*

**ជំរុញលើកទឹកចិត្តចំពោះយុវជនកម្ពុជានាសហស្សវត្សរ៍ថ្មី** ៥៩

*ដោយ លោក ប្រាយអិន ម៉ាហឺរ៍*

***Biography:* Samoeun Intal** 68

*UON Seila*

**ការជួបជាមួយ លោកស្រី សាមឿន អ៊ីនតាល់** ៧៣

*ដោយ លោក អ៊ួន សិលា*

***Book Review: Poles Apart* by John R. Davis** 79

*Darrell CALDWELL*

**ពិនិត្យមើលឡើងវិញក្នុងសៀវភៅ** ៨៥

*ដោយ លោក ដារ៉ែល ខាតវែល*

HONEYCOMB 1/1 (July 2000): 1–10

# Forgiving Those who Trespass Against Us

*Russell H. BOWERS, Jr.*

Nothing is more important when we think about our relationship with God than is the matter of forgiveness. Because we are sinners, forgiveness is essential if we are to enjoy any fellowship with a holy God. But will God truly forgive sinful people? If we do come to experience God's forgiveness, how should that inform our relations with those who wrong us? How freely, genuinely, completely, and repeatedly should we forgive them? Should our forgiveness know any limits? Does it erase any and all consequences of the sin we have forgiven?

This article will not discuss God's forgiveness of us as much as it will discuss our forgiveness of others. It will assume that in Christ forgiveness is full and free—that our sin is removed "as far as the east is from the west" and "remembered against us no more." Using God's pardon as a pattern, this article will explore how the forgiven individual should treat someone who sins against him.

## Giving a name to evil.

What name should we give to those occasions when we disobey God or wrong other people? Those which require *forgiveness* must be called *sin*. They are not merely *mistakes*. People do make mistakes, with varying degrees of guilt attached when they do. Nor are we talking about *human nature* and the limitations we face simply because we are human. It is true that as

we live among our brother and sister human beings we often have to correct their mistakes and be patient with their human limitations. But what we will need to *forgive* is their *sins*. *Sin* implies a *choice* to do what is wrong—something the one who does it either does know or should know is wrong. People are more than machines who have to act the way they do simply because they are made that way. At times we must *choose* to act against what would for the moment give us power or pleasure, or against what other people are thinking or doing, so that we can do what is *right*. A person who finds himself in the middle of a mob of people looting or killing must resist going along with what they are doing. The individual has a *choice*; to *choose* to join the mob is *sin*.

The fact that sin exists means that there must be actions which are always right or always wrong. There must be a law, and someone who creates and enforces that law. That lawgiver is God. We cannot define "right" and "wrong" on the basis of how the people in power define them. If we do, then the terrible actions of people like Hitler, Stalin, and Pol Pot were "right," because they defined them as being "right." No, the standard of "right" and "wrong" must come from outside man himself or the opinions which happen to be popular at the time. The standard is found in the unchanging character of God, as he reveals himself in scripture.

Biblical words further teach us about sin's nature. It is "missing" a goal or way (חָטָא, ἁμαρτία), "perversion" or "twistedness" (עָוֹן), "rebellion" or "transgression" (פֶּשַׁע, παράβασις), "injustice" (ἀδικία), "lawlessness" (ἀνομία), and a "fall" (παράπτωμα). Theologically, sin is when we do not measure up to the will and moral character of God. Because we are responsible for our actions, sinners incur "guilt" (אָשָׁם, ἔνοχος [adj.]). *Guilt* means that sin is not beyond our control—we *choose* to sin. We cannot blame either our DNA, our upbringing, the people around us, or Satan. Attempting to evade blame is something that is natural for us to do. Adam and Eve tried to do that after the first human sin. But we are guilty and therefore answerable for our crimes.

### God's reaction.

If the way God deals with our sin is to provide the example of how we should deal with others' sins, we must observe what the Bible teaches about how God reacts. Briefly, God responds with (1) wrath and judgment, and then (2) an offer of grace. We must not ignore God's first reaction of wrath in our rush to enjoy God's second reaction of grace.

Sometimes, however, we do fail to speak seriously enough of God's wrath and judgment of sin. But this is both an Old Testament (Psalm 2:5, 12; Lamentations 2:2, 4) and a New Testament (Romans 1:18; 2:5, 8; Ephesians 2:3; 5:6; Revelation 6:16, 17; 16:1, 19; 19:15) teaching. In His holiness God will judge sin; in His justice He will do so fairly. The rich and powerful will receive no special treatment in God's court. God's wrath and judgment are not trivial matters, because as Hebrews 10:31 says, "it is a dreadful thing to fall into the hands of the living God."

Having announced his hatred and approaching judgment of sin, God turns and offers forgiveness through Christ. This is the gospel Christians value so highly. God's holiness and justice move Him to judge, while His love prompts Him to reconcile the sinner. The interplay between the need to judge and the urge to forgive is captured by Ezekiel—"I will judge you, each one according to his ways, declares the Sovereign Yahweh. Repent! Turn away from all your offenses; then sin will not be your downfall. Rid yourselves of all the offenses you have committed, and get a new heart and a new spirit. Why will you die, O house of Israel? For I take no pleasure in the death of anyone, declares the Sovereign Yahweh. Repent and live!" (18:30–32).

What we must do to avoid the judgment God threatens and instead enjoy the forgiveness he offers is described by the words "confession," "repentance," and "faith." These three words describe parts of what is really a single reaction. The source of the Greek word ὁμολογέω *confess* is two words which when put together mean "to say the same." Therefore its definitions include "agree, admit, confess, declare (publicly), acknowledge." To "say

the same" thing regarding our sin that God says means to admit that what we have done is *sin* (and neither an innocent *mistake* or the fault of limited *human nature*), that it is wicked, and that it deserves God's judgment. Biblical confession is neither reciting a list of things we may have done wrong without really thinking about it, nor is it a hazy general admission "I have sinned." It is a specific acknowledgment, with the same sense of sin's seriousness as God expresses. "He who conceals his sins does not prosper, but whoever confesses and renounces them finds mercy" (Proverbs 28:13).

Repentance—the word Ezekiel uses—means a complete change of mind which results in a change of our lives. I had one way of thinking, one set of values, one way of behaving; I now abandon these and think, value, and act in the opposite direction. Repentance may include grief, but grief is not its chief component—its chief component is a change of mind and life. Luke clearly shows that repentance precedes forgiveness (13:1–5; 24:47). Thus, though God forgives it does not come easily even for the sinner, let alone for God who paid sin's price. If we understand confession and repentance in this way, it should silence critics who suggest that the Christian gospel offers a cheap forgiveness based on a lighthearted understanding of sin's seriousness.

Forgiveness is further tied to faith. Faith means that I rely upon the grace that God offers through the death and resurrection of Jesus of Nazareth. Even though it might seem unlikely that the majestic and holy God should think kindly toward sinners, he in fact wants to forgive and reconcile us, and by faith we accept the offer he extends through his son. This is faith.

Based on Christ's sacrifice, God forgives when we confess, repent, believe. The biblical words which describe forgiveness are as rich as those which describe sin. The most common Old Testament word is סָלַח "to forgive, pardon" (always with God as the subject). Also used are נָשָׂא "to lift up, bear or carry, take away," כִּפֶּר to cover over, pacify, make propitiation," עָבַר "to pass over, overlook, forgive," and מָחָה "to wipe or blot out." The New Testament overwhelmingly uses ἀφίημι "to let go, send away,

cancel, remit, pardon," but also employs χαρίζομαι "to act graciously," ἀπολύω "to set free, release, pardon, send away, dismiss," ἵλεως "gracious, merciful," and πάρεσις "passing over, letting go unpunished." These words point out to us different facets of "the incomparable riches of [God's] grace, expressed in his kindness to us in Christ Jesus" (Ephesians 2:7).

**Our imitation of God's pattern.**

How should we use God's pattern of dealing with sin to direct how we respond when wronged? First, we must give the wrong its proper name. When someone sins against me I must call it sin. I must help the one who has done the wrong to see that it is sin. Jesus instructed, "If your brother sins against you, go and show him his fault" (Matthew 18:15). He has a fault, name it a fault, and show him that it is a fault. I must not ignore it, leave it unnamed, and allow it to continue to anger me. Jesus' instruction reminds us of Leviticus 19:17—"Do not hate your brother in your heart. Rebuke your neighbor frankly so you will not share in his guilt." Leaving sin unnamed and unconfronted allows it to simmer into hatred, so that sin has multiplied. Because I am nurturing ill-will toward another person, now I am as guilty as he. So the first step in dealing with sin is to name it as sin.

To illustrate, an unfortunate pattern among many Cambodians in the years following Pol Pot has been to deny or ignore the past. Too painful to face, Khmer Rouge crimes have been essentially dismissed from the conscious mind, leaving its victims to fight against them alone and subconsciously, and so fall prey to depression and post-traumatic stress syndrome. "Let bygones be bygones," some people suggest. But mass torture and murder are not "bygones." They are sins, they are crimes—and they need to be named such if healing is ever to take place.

Once a "fault" or "sin" has been named, we must face its seriousness. A sin which is left unaddressed and unforgiven shatters any sense of goodwill among family, friends, and neighbors. One reason to confront the sin, then, is to mend

relationships. Ignoring it allows a division to continue and grow. Confronting with a view to correcting also helps us fight the temptation to seek personal revenge, which is clearly forbidden in scripture (Romans 12:17–21).

As I confront my brother with his sin, my goal—as God's—is to urge him to repent so that I may extend my forgiveness. Jesus' command to "show him his fault" is followed by "If he listens to you, you have won your brother over." The rift is healed. Elsewhere Jesus expands this idea: "If your brother sins, rebuke him, and if he repents, forgive him. If he sins against you seven times in a day, and seven times comes back to you and says, 'I repent,' forgive him" (Luke 17:3–4).

If human forgiveness is to match God's it must be 1) sought by the offended party (Luke 19:10), 2) extended generously (Psalm 103:12), 3) extended permanently (Hebrews 10:17), 4) extended repeatedly (Luke 17:4), and 5) extended even to those who have sinned atrociously (2 Chronicles 33:9–13).

**Forgiveness vs. consequences.**

Forgiveness both cancels the judicial punishment which the sin deserved and allows the relationship between offender and one offended to be restored. But these do not necessarily mean that all the *consequences* of the sin are erased. If a woman should choose to wallow in drunkenness for years and then repent, God will forgive the sin, but not necessarily replace her damaged liver and restore her health. If a man should choose to beat his wife and neglect his children, God can forgive that sin but will neither restore the years lost nor erase the memories of what he has done. Forgiveness does not necessarily erase consequences.

The Bible shows that this is true. When David sinned and confessed, Nathan assured him, "Yahweh has taken away your sin. You are not going to die [that is, you are forgiven]." But he continued, "Because by doing this you have made the enemies of Yahweh show utter contempt, the son born to you will die [that is, you and your family will suffer consequences]."

By application, we must forgive a brother who sins against us and repents—that is, we enjoy fellowship with him again without holding a grudge. But his forgiven sin may nevertheless alter my future relations with him. I may decline to lend my computer to a person who has already twice damaged it through neglect on previous occasions when I let him borrow it. A church treasurer who embezzled funds may be forgiven upon genuine repentance but never entrusted with such a position again. A pastor who fails to remain sexually pure may be forgiven by God and his church, but may find himself no longer "above reproach" (as 1 Timothy 3:2 requires of overseers) and therefore disqualified from continuing as pastor. Sins may be genuinely forgiven but still bear consequences.

This is true of the way both a nation as well as the way an individual forgives. Someone who has committed gross crimes against humanity and repents (as did Manasseh—see 2 Chronicles 33:1–20) may be forgiven both by God and his victims. Yet the nation may still try and punish him for those crimes. God's forgiveness—and ours—may not eliminate all consequences.

**It's good for us.**

For many years psychologists did not study forgiveness. But now it is being discovered to contribute significantly to a victims' emotional and physical healing and wholeness. Although the sinner gains through being forgiven, the victim who does the forgiving gains as well. Further, forgiveness breaks the cycle of repaying vengeance with vengeance, which can cause any family or society (one thinks of Kosovo, Israel, and Northern Ireland) to spiral ever deeper into violence.

**A Cambodian statement.**

On 17 May 1999 about a dozen Cambodian church leaders met to discuss the issues of crimes against humanity, repentance, forgiveness, and judicial consequences. As a result of this and two

subsequent meetings a statement was drafted on these issues. A copy of that statement follows:

***Forgiveness of Those Guilty of Atrocities***

God, creator and lord of all, hates oppression and genocide. He regards them as evils which should not be simply dismissed no matter how much time has passed since they were committed. He promises to judge those who perpetrate such crimes.
*Gen 6:5–7; Deut 25:17–19; Ezek 18:20*

God, however, loves everyone—even those responsible for these atrocities. He declares that he will forgive all who honestly confess their sin to him, when such confession is accompanied by a commitment to believe in and follow his son Jesus. This forgiveness is not granted the penitent based on his merit, no matter how good he may subsequently become, or how many good deeds he may promise to perform. It is an undeserved gift from God, who is merciful toward even the worst offenders. His grace is sufficient to forgive all sin when the guilty person repents and trusts in Jesus.
*Jn 3:16; 6:37; 1 Tim 1:12–16*

But where is the justice in free eternal forgiveness? Surely all guilty of high-handed oppression should be punished by God forever? The answer is this—God's judgment due the sinner was placed on another. Jesus was sent to die—to be executed—in the place of others. He himself was innocent, but died the death deserved by sinners, including those guilty of gross crimes against humanity. Because Jesus is uniquely God's son, his death provided sufficient punishment for the sins of all humanity, though it proves effective only for those who repent and believe. Belief in the Lord Jesus, accompanied as it must be by a turning from sin to follow him, can bring eternal forgiveness from God only because sin's penalty has been paid.
*Isa 53:4–6; Mk 10:45; 2 Cor 5:21; Rom 3:9–26*

Because God forgives, he calls on his people to personally do the same. Sometimes this seems impossible, but God assists all who ask for help to forgive those who have abused them. It is for God to ultimately condemn, not us. If he forgives, we must also.
*Rom 12:14, 17–21; Matt 6:12; 18:15–35*

God's forgiveness, however, may not rescue the guilty from consequences in this life which stem from their sin. Our sin may affect our health, our relationships, and, in the case of those guilty of crimes, our liability to judgment by the state. God regards no one as above the law. Therefore those who commit murder and atrocity, whether Christians or not, should face the judgment of the court. Such judgment may even include a death sentence. God entrusts authority to governments to punish criminals and protect citizens through just laws and appropriate judicial procedures. Governments, in turn, are accountable to God regarding how they exercise this trust. God does not exempt anyone from these legal procedures, even if he has repented and been forgiven by God. Any sentence of the court, of course, does not revoke God's eternal forgiveness.
*2 Sam 12:11–14; Rom 13:1–7*

The state may decide that it best fulfills its God-given role of avenger of evil by executing or punishing those it finds guilty of crimes against humanity. However, if it determines that the defendant has experienced a genuine change of heart over his past, evidenced by a profound and sustained reversal of behavior, it may choose to commute its sentence, while still deploring the defendant's sin. The wisdom of the court must decide what is best in each such extraordinary case.
*1 Kings 21:20–29; 2 Chron 33:9–13*

Thus governments operate within their rights when they punish even repentant criminals. The courts may, of course, choose to lessen or forgive the sentences of the truly repentant, recalling Portia's words in Shakespeare's *Merchant of Venice* that earthly power most resembles God's when mercy seasons justice.

But, regardless of the consequences on this earth which may follow a sinful action, may we as individuals follow the apostle's admonition to "Be kind and compassionate to one another, forgiving each other, just as in Christ God forgave you."

សំណុំធីកឃ្មុំ ១/១ (កក្កដា ២០០០): ១១-២៣

# ការអត់ទោសចំពោះអស់អ្នកដែលធ្វើបាបប្រឆាំងនឹងយើង

ដោយ លោក រ៉ស់ បាឌរឌ៉ីស

*******

គ្មានអ្វីសំខាន់ នៅពេលដែលយើងគិតអំពីទំនាក់ទំនងរបស់យើងជាមួយ ព្រះជាម្ចាស់ជាងរឿងរ៉ាវនៃការអត់ទោសនោះឡើយ ។ ដោយហេតុតែយើងជាអ្នកមានបាប ការអត់ទោសគឺមានសារៈសំខាន់ណាស់ បើសិនយើងមានទំនាក់ទំនងដ៏ប្រសើរជាមួយព្រះដ៏បរិសុទ្ធនោះ ។ ប៉ុន្តែតើព្រះជាម្ចាស់ នឹងអត់ទោសអោយអ្នកមានបាបពិតប្រាកដមែនឬ ? ក្រោយមកប្រសិនបើយើងពិសោធន៍នូវការអត់ទោសរបស់ព្រះជាម្ចាស់ចំពោះយើង តើការនោះនាំឲ្យយើងអត់ទោសឲ្យអ្នកដទៃ ដែលបានធ្វើខុសចំពោះយើងបានដោយរបៀបណា ? តើយើងត្រូវអត់ទោសដោយស្ម័គ្រចិត្ត សុទ្ធចិត្តពេញលេញ ហើយនិង ប៉ុន្មានដងទៅដល់ពួកគេ ? តើការអត់ទោសរបស់យើងគួរតែមាននូវដែនកំណត់ទេ ? តើបំភ្លេចវាចោលរាល់ផលវិបាកផ្សេងៗទាំងអស់នៃអំពើបាប ដែលយើងបានអត់ទោស ហើយឬយ៉ាងណា ?

អត្ថបទនេះ នឹងមិនពិភាក្សាស្តីពីការអត់ទោសរបស់ព្រះជាម្ចាស់ចំពោះយើងឲ្យបានច្រើន តែនឹងពិភាក្សាអំពីការអត់ទោសរបស់យើង ចំពោះអ្នកដទៃ ។ គឺត្រូវសន្មតថា ការអត់ទោសរបស់ព្រះគ្រីស្ទ គឺពេញលេញ ហើយឥត បង់ថ្លៃ ដែលថាអំពើបាបរបស់យើងត្រូវលាងសំអាត "របៀបដូចជាទិសខាងកើតឆ្ងាយពីខាងលិច" ហើយនិង "គ្មានការចងចាំណាទៀត ដែលទាស់ទទឹងនឹងយើងទៀតឡើយ" ។ អ្នកដែលប្រើប្រាស់ការអត់ទោសរបស់ព្រះជាម្ចាស់ធ្វើជាគំរូ អត្ថបទនេះនឹងនាំឲ្យឃើញនូវរបៀបអត់ទោសដល់បុគ្គល ដែលបានប្រព្រឹត្តធ្វើបាបទាស់នឹងខ្លួនគាត់ ។

ការអោយឈ្មោះថាជាការអាក្រក់ ។ នៅពេលដែលយើងមិនស្តាប់បង្គាប់ព្រះជាម្ចាស់ ឬ ក៏ធ្វើខុសចំពោះអ្នកដទៃ តើយើងត្រូវហៅអំពើបែបនោះដូចម្តេច? អំពើទាំងឡាយណាដែលតំរូវឲ្យមានការ អត់ទោសដែលគេហៅថា អំពើបាប ។ គឺវាមិនគ្រាន់តែ ជាកំហុសប៉ុណ្ណោះទេ ។ មនុស្សគឺមានកំហុស ដោយមានកំរិតប្រែប្រួលនៃការជាប់ជំពាក់ក្នុងពិរុទ្ធភាព នៅពេលដែលគេធ្វើ ។ យើងនិយាយអំពីនិស្ស័យមនុស្ស ហើយនិងដែនកំណត់ ដែលយើងជួបប្រទះយ៉ាងងាយពីព្រោះយើងជាមនុស្ស ។ នេះគឺជាការពិតដែលថា យើងរស់នៅក្នុងចំណោមបងប្អូនប្រុសស្រីកើតជាមនុស្ស យើងជាញឹកញយត្រូវតែកែកំហុសរបស់គេ ហើយនិងមានការអត់ធ្មត់ ចំពោះដែនកំណត់ ក្នុងភាពមនុស្សរបស់ពួកគេ ។ ប៉ុន្តែអ្វីដែលយើងនឹងត្រូវការនោះគឺអត់ទោស នូវអំពើបាបរបស់ពួកគេ ។ អំពើបាបគឺមានន័យថា អ្វីដែលយើងជ្រើសរើសធ្វើអ្វីដែលខុសនោះ គឺអ្វីៗដែលនរណាម្នាក់ធ្វើ ទោះបើបានដឹងខ្លួនក្តី ឬទាំងមិនដឹងខ្លួនក្តី គួរតែដឹងថា នេះគឺជាកំហុសក៏ដោយ ។ មនុស្សមិនមែនជាម៉ាស៊ីនឯណា ដោយគ្រាន់តែធ្វើតាមម៉ាកដែលគេផលិតមកនោះ ។ ជួនកាល យើងត្រូវតែជ្រើសរើស ក្នុងការប្រព្រឹត្តប្រឆាំងនឹងអ្វីដែលផ្តល់អំណាច ឬក៏ការសប្បាយតែមួយភ្លែត ឬក៏ប្រឆាំង នឹងអ្វីដែលអ្នកដទៃគិត ឬក៏ធ្វើដើម្បីឲ្យយើង អាចធ្វើអ្វីដែលត្រឹមត្រូវ ។ មនុស្សម្នាក់ដែលដឹងថាខ្លួនស្ថិតនៅកណ្តាលនៃហ្វូងមនុស្សដែលលួច ឬក៏កាប់សំលាប់មនុស្សដូចគ្នា គឺអំពើបែបនោះត្រូវតែគេចចេញ ពីការធ្វើតាមអ្វីដែលគេបានធ្វើនោះ ។ បុគ្គលដែលមានជំរើស ហើយបែរជាទៅជ្រើសរើស សេពគប់ក្នុងហ្វូងមនុស្សបែបនោះគឺជាអំពើបាប ។

ការដែលថាមានបាបនោះ គឺមានន័យថាត្រូវតែមានសកម្មភាព ដែលតែងតែមានភាពត្រឹមត្រូវ ឬក៏តែងតែខុសជាដរាប ។ គឺត្រូវតែអាស្រ័យលើច្បាប់ហើយនិងនរណាមួយ ដែលបង្កើត ហើយដាក់ច្បាប់នោះអោយប្រតិបត្តិតាម ។ អ្នកដែលប្រទានច្បាប់នោះ គឺព្រះជាម្ចាស់ ។ យើងមិនអាច កំណត់ឲ្យដឹងថា "ត្រឹមត្រូវ" និង "ខុសឆ្គង" ដោយយោងលើតាម មនុស្សដែលមានអំណាចអោយអត្ថន័យលើច្បាប់នោះ ។ បើសិនជាយើងយល់ស្រប ពេលនោះអំពើរបស់មនុស្ស ដូចជា ហ៊ីត្លែរ, ស្តាលីន និង ប៉ុលពត ថាជាការ "ត្រឹមត្រូវ" ពីព្រោះមនុស្សបានកំណត់អត្ថន័យថាវាជាការ"ត្រឹមត្រូវ" ។ មិនមែនដូច្នេះឡើយ

មាត្រដ្ឋាននៃ ការ"ត្រូវ" និង ការ "ខុស" នោះត្រូវតែមកពីខាងក្រៅគំនិតមនុស្ស ឬ គំនិតទាំងឡាយ ដែលកើតឡើងមានប្រជាប្រិយនាពេលនោះ ។ មាត្រដ្ឋានសំរាប់វាស់ឲ្យដឹងខុសត្រូវនោះ គឺប្រទះឃើញក្នុងលក្ខណៈមិនផ្លាស់ប្តូរនៃព្រះជាម្ចាស់ ដូចដែលទ្រង់បញ្ចេញឲ្យឃើញរូបអង្គទ្រង់ផ្ទាល់ក្នុងបទគម្ពីរ ។

ព្រះបន្ទូលនៅក្នុងព្រះគម្ពីរ បង្រៀនយើងកាន់តែច្បាស់ថែមទៀត អំពីនិស្ស័យរបស់អំពើបាប ។ អំពើបាប គឺជា "ការដើរខុស" ទិសដៅ ឬ ខុសផ្លូវ ។ "ការខុសឆ្គង" ឬ"អំពើវៀចវេរ" "ការបះបោរ" ឬ "អំពើរំលងច្បាប់" "អំពើអយុត្តិធម៌" "មិនគោរពច្បាប់ ឥតសណ្តាប់ធ្នាប់" និង "ការធ្លាក់ក្នុងអំពើអាក្រក់" ។ តាមបែបទេវសាស្ត្រ អំពើបាប គឺនៅពេលដែលយើងវាស់ទៅមិនដល់តាមបំណងព្រះហឫទ័យ និង ចរិតលក្ខណៈផ្នែកសីលធម៌របស់ព្រះជាម្ចាស់ ។ ពីព្រោះតែយើងទទួលខុសត្រូវចំពោះសកម្មភាពរបស់យើង ពិរុទ្ធភាពដែលអ្នកមានបាបត្រូវទទួល ។ ពិរុទ្ធភាព មានន័យថាអំពើបាបដែលកើតឡើងមិនហួសពីការគ្រប់គ្រងរបស់យើង គឺមានន័យថា យើងជ្រើសរើសទៅប្រព្រឹត្តអំពើបាបនោះ ។ យើងមិនអាចបន្ទោសដល់សារធាតុផ្តល់កំណើតរបស់យើង ការអប់រំ មនុស្សដែលនៅជុំវិញយើង ឬ អារក្សនោះឡើយ ។ ចំពោះការប៉ុនប៉ងស្តីបន្ទោស ដល់គេឯងនោះ វាជាទម្លាប់ធម្មជាតិរបស់យើងទៅហើយ ។ អ័ដាម និង អេវ៉ា បានព្យាយាមធ្វើការនោះ បន្ទាប់ពីមនុស្សបានធ្លាក់ក្នុងអំពើបាបមុនដំបូង ។ ដោយសារតែយើងជាប់ពិរុទ្ធ ទើបហេតុដូច្នេះហើយ បានជាយើងខំឆ្លើយដោះសាចំពោះអំពើឧក្រិដ្ឋរបស់យើង ។

ប្រតិកម្មរបស់ព្រះជាម្ចាស់ ។ បើសិនព្រះជាម្ចាស់ដោះស្រាយអំពើបាបរបស់យើង គឺត្រូវផ្តល់ជាគំរូសំរាប់យើង ក្នុងការដោះស្រាយជាមួយអំពើបាបរបស់អ្នកដទៃ យើងត្រូវតែសង្កេតមើលនូវអ្វីដែលព្រះគម្ពីរបានបង្រៀន អំពីរបៀបដែលជាប្រតិកម្មរបស់ព្រះជាម្ចាស់ ។ និយាយឲ្យខ្លីទៅ ព្រះជាម្ចាស់ ឆ្លើយតប (ទី១) ដោយសេចក្តីក្រោធ និង សេចក្តីជំនុំជំរះ ហើយបន្ទាប់មក (ទី២) ការផ្តល់នូវសេចក្តីប្រណីសន្តោស/ព្រះគុណ ។ យើងមិនត្រូវធ្វើព្រងើយ និង ប្រតិកម្មនៃសេចក្តីក្រោធទី១ របស់ព្រះជាម្ចាស់ឡើយ ដោយយើង ប្រញាប់តែអរសប្បាយនឹងប្រតិកម្មទីពីរ ដែលជាសេចក្តីប្រណីសន្តោស / ព្រះគុណរបស់ព្រះអង្គ ។

ទោះជាយ៉ាងណាក៏ដោយ ជួនកាលយើងខកខានក្នុងការនិយាយឲ្យបានប្រាកដប្រជាអំពីសេចក្តីក្រោធ និង ការជំនុំជំរះអំពើបាបរបស់ព្រះជាម្ចាស់ ។ ប៉ុន្តែនេះគឺជាសេចក្តីបង្រៀនទាំងពីរទាំងក្នុងគម្ពីរសញ្ញាចាស់(ទំនុកតម្កើង ២:៥, បរិទេវ ២:២,៨) ហើយនិងក្នុងគម្ពីរសញ្ញាថ្មី (រ៉ូម ១:១៨, ២:៥,៨, អេភេសូ ២:៣,៥-៦, វិវរណៈ ៦:១៦, ១៧, ១៦:១, ១៩:១៥) ។ នៅភាពបរិសុទ្ធ របស់ទ្រង់ ព្រះអង្គនឹងជំនុំជំរះអំពើបាប ដោយភាពយុត្តិធម៌របស់ព្រះអង្គ និងជំនុំជំរះដោយយុត្តិធម៌បំផុត ។ ទោះបីអ្នកមាន និង អ្នកមានអំណាចនឹងមិនបានទទួលនូវឯកសិទ្ធិពិសេសណាមួយឡើយ នៅក្នុងទីលានកាត់ក្តីរបស់ព្រះជាម្ចាស់ ។ សេចក្តីក្រោធ និង ការជំនុំជំរះ មិនមែនជារឿងសាមញ្ញនោះទេ ពីព្រោះដូចដែលព្រះគម្ពីរ ហេព្រើ ១០:៣១ បានចែងថា "រីឯការដែលធ្លាក់ទៅក្នុងកណ្តាប់ព្រះហស្តនៃព្រះដ៏មានព្រះជន្មរស់នៅ នោះគួរស្ញែងខ្លាចណាស់" ។

ការប្រកាសនូវសេចក្តីសំអប់របស់ព្រះអង្គ និង ការជំនុំជំរះនៃអំពើកាន់តែឈានមកជិតដល់ ព្រះជាម្ចាស់បែរមក ហើយនិង ផ្តល់នូវការអត់ទោសបាបតាមរយៈព្រះគ្រីស្ទ ។ នេះជាដំណឹងល្អ ដែលគ្រីស្ទបរិស័ទឲ្យតម្លៃយ៉ាងខ្ពស់ បំផុត ។ ភាពបរិសុទ្ធ និង សេចក្តីយុត្តិធម៌របស់ព្រះអង្គបណ្តាលឲ្យព្រះអង្គជំនុំជំរះដោយសេចក្តីស្រឡាញ់ បណ្តាលឲ្យព្រះអង្គជានានឹងមនុស្សមានបាបឡើងវិញ ។ ចំពោះការដើរតួជាកណ្តាលរវាងការជំនុំជំរះ ដែលចាំបាច់ត្រូវតែធ្វើ និង ការជំរុញឲ្យមានការអត់ទោសបាបត្រូវបានគេឃើញនៅក្នុងអេសេគាល៖ «អញនឹងជំនុំជំរះឯងរាល់គ្នា គ្រប់គ្នាតាមអំពើប្រព្រឹត្តរៀងខ្លួន ចូរឯងរាល់គ្នាវិលមកវិញ ចូរបែរចេញពីអំពើរំលងរបស់ឯងទៅយ៉ាងនោះ សេចក្តីទុច្ចរិតនឹងមិនបំផ្លាញឯងទេ ចូរបោះបង់ចោលអំពើទាំងប៉ុន្មានរបស់ឯង ដែលឯងរាល់គ្នាប្រព្រឹត្តនោះ ហើយឲ្យខ្លួនមានចិត្តថ្មីនិងវិញ្ញាណថ្មីចុះ ដ្បិតឱពូជពង្សពួកអ៊ីស្រាអែលអើយ ឯងរាល់គ្នាចង់ស្លាប់ធ្វើអី ពីព្រោះអញឥតមានសេចក្តីអំណរចំពោះការស្លាប់របស់អ្នកដែលត្រូវស្លាប់នោះទេ ដូច្នេះ ចូរឯងរាល់គ្នាវិលមក ដើម្បីឲ្យបានរស់នៅវិញ នេះជាព្រះបន្ទូលនៃព្រះអម្ចាស់យេហូវ៉ា ! » (១៨:៣០-៣២) ។

អ្វីដែលយើងត្រូវតែធ្វើ ដើម្បីជៀសវាងនូវសេចក្តីជំនុំជំរះ ដែលគំរាមយើងនោះ ហើយនិងយើងបែរទៅជាអរសប្បាយនូវការអត់ទោសបាបដែលព្រះអង្គផ្តល់ឲ្យមកទៅវិញ ដោយពណ៌នាតាមពាក្យផ្សេងៗ "លន់តួបាប" កែ

ប្រែចិត្តហើយនិង "ជំនឿ" ។ ពាក្យទាំងបីនេះពណ៌នាពីផ្នែកនានានូវអ្វីដែលពិតជាប្រតិកម្ម តែមួយគត់របស់ព្រះជាម្ចាស់ ។ ពាក្យថា លន់តួ មានប្រភពចេញពីភាសាក្រិក គឺមាន ពាក្យពីរម៉ាត់ ដែលដាក់ជាមួយគ្នា មានន័យថា "និយាយដដែល" ។ ហេតុដូច្នេះហើយ អត្ថន័យរបស់ពាក្យនោះ គឺមានគិតបញ្ចូលទាំងពាក្យ "យល់ព្រម, ព្រមទទួល, សារភាព, ប្រកាស(ជាសាធារណៈ), ការទទួលស្គាល់" ។ ដើម្បី"និយាយដដែល" ដែលទាក់ទងនឹងអំពើបាបរបស់យើងគឺថា ព្រះជាម្ចាស់ចង់បានសេចក្តីថា ឲ្យយើងព្រមទទួលនូវអ្វី ដែលយើងធ្វើនោះគឺជាអំពើបាប (មិនថាឡើយកំហុស ដោយមិនដឹងថាការនោះជាអំពើបាប ឬកំហុសនៅក្នុងព្រំដែននិស្ស័យរបស់មនុស្ស) គឺថាវាជាអំពើអាក្រក់ ហើយ និងវាសមនឹងទទួលនូវការជំនុំជំរះរបស់ព្រះជាម្ចាស់។ ការសារភាពបាបនៅក្នុងព្រះគម្ពីរ គឺមិនមែនជាការសូត្រតាមបញ្ជីនៃទង្វើដែលយើងអាចធ្វើខុស ដោយមិនបានគិតអំពីការ នោះពិតប្រាកដ ឬក៏មិនមែនជាការព្រមទទួលជាទូទៅ ដែលមិនច្បាស់លាស់នោះឡើយ ដោយនិយាយថា "ខ្ញុំបានធ្វើបាប" ។ វាជាការព្រមទទួលស្គាល់ជាក់លាក់ដោយមានអារម្មណ៍ថា វាជាអំពើបាបដ៏ធ្ងន់ធ្ងរ ដែលព្រះជាម្ចាស់បានសម្តែងឲ្យដឹងដូចគ្នានោះដែរ ។ "អ្នកណាដែលគ្របបាំងការរំលងរបស់ខ្លួន នោះនឹងមិនចំរើនឡើងទេ តែអ្នកណាដែលលន់តួ ហើយលះបង់អំពើនោះ នឹងប្រទះបានសេចក្តីមេត្តាករុណាវិញ" (សុភាសិត ២៨:១៣) ។

ការប្រែចិត្ត ពាក្យដែលអេសេគាលប្រើ មានន័យថា ការកែគំនិតយ៉ាងពេញលេញ ដែលជាលទ្ធផលឲ្យមានការកែប្រែចិត្តរបស់យើង ។ ខ្ញុំធ្លាប់មានរបៀបគិត ផ្នត់គំនិតនៃការឲ្យតម្លៃមួយផ្សេង របៀបមួយនៃការប្រព្រឹត្តិ តែឥឡូវនេះខ្ញុំបោះបង់ការទាំងនោះ បែរមកគិតឲ្យតម្លៃ និង ប្រព្រឹត្តតាមបែបមួយផ្ទុយពីការដែលខ្ញុំធ្លាប់ធ្វើពីមុន ។ ការប្រែចិត្តអាចគិតបញ្ចូលទាំងការសោកស្តាយ ប៉ុន្តែការសោកស្តាយនោះមិនមែនជាផ្នែកដ៏សំខាន់ឡើយ ផ្នែកដ៏សំខាន់របស់ការប្រែចិត្ត គឺជាផ្លាស់ប្តូរគំនិត និង ជីវិត ។ លោកលូកាបានបង្ហាញយ៉ាងច្បាស់ថា ការប្រែចិត្តវាទៅមុន ការអត់ទោសបាប (១៣:១-៥, ២៤:៤៧) ។ ហេតុដូច្នេះ ហើយ ទោះបីជាព្រះជាម្ចាស់អត់ទោសបាបក៏ដោយ វាមិនបានមកដោយងាយៗ ឡើយ សូម្បីតែចំពោះមនុស្សមានបាប ចុះទម្រាំបើព្រះជាម្ចាស់ដែលជាអ្នកបង់ថ្លៃលោះអំពើបាប កាន់តែមិនងាយទៅទៀត ។ បើសិនយើងយល់ថា ការលន់តួ

និង ការប្រែចិត្ត វាងាយបែបនេះ នោះនឹងធ្វើឲ្យមានការរិះគន់ដោយសម្ងាត់ដែលគេនិយាយថា ដំណឹងល្អរបស់គ្រីស្ទបរិស័ទ ផ្តល់ឲ្យមានការអត់ទោសបាបថោក ដោយផ្អែកលើការយល់ដឹង ដែលមិនច្បាស់លើភាពដ៏ធ្ងន់ធ្ងររបស់អំពើបាប ។

ការអត់ទោសបាបភ្ជាប់ទៅជាមួយជំនឿ ។ ជំនឿមានន័យថា ខ្ញុំពឹងផ្អែកលើព្រះគុណ ដែលព្រះជាម្ចាស់ផ្តល់ឲ្យ តាមរយៈការសុគត និង ការរស់ឡើងវិញរបស់ព្រះយេស៊ូនៃភូមិណាសារ៉ែត ទោះបីជាវាដូចជាមិនទំនងដែលថាព្រះដ៏មានព្រះតេជៈ និង បរិសុទ្ធមិនសមមកគិតដល់មនុស្សមានបាបសោះ តាមពិតទៅព្រះអង្គចង់អត់ទោសបាប និង ចង់ផ្សះផ្សានឹងយើងឡើងវិញ ហើយនិងដោយជំនឿយើងទទួលយកការអត់ទោសបាបនោះ ដែលព្រះអង្គផ្តល់មកតាមរយៈព្រះរាជបុត្រារបស់ព្រះអង្គ ។ នេះឯងជាជំនឿ ។

ដោយផ្អែកលើយញ្ញបូជារបស់ព្រះគ្រីស្ទ ព្រះជាម្ចាស់អត់ទោសបាបឲ្យនៅពេលដែលយើងលន់តួ កែប្រែចិត្ត ជឿ ។ ព្រះបន្ទូលនៅក្នុងព្រះគម្ពីរពណ៌នាពីការអត់ទោសបាប គឺមានច្រើនដូចពាក្យទាំងឡាយដែលពណ៌នាពី អំពើបាបដែរ ។ ពាក្យដែលសាមញ្ញបំផុតនៅក្នុងព្រះគម្ពីរសញ្ញាចាស់គឺ "អត់ទោសប្រណីទោស" (តែងតែនៅជាមួយព្រះជាម្ចាស់ ជារឿងសំខាន់) ។ ពាក្យដែលប្រើជាច្រើនដែរនោះ "លើកឡើង ទ្រាំទ្រ ឬផ្ទុក ដោះចេញ" លុបបំបាត់ ស្កប់ចិត្ត ការធ្វើឲ្យគាប់ព្រះហឫទ័យ "ដើរហួស មើលរំលង អត់ទោសបាប" និង លុបបំបាត់ ឬ លុបចេញ" ។ ប្រើយ៉ាងច្រើននៅក្នុងគម្ពីរសញ្ញាថ្មី "អនុញ្ញាត ឲ្យទៅ បញ្ជូនទៅ លុបចោល លើកលែង អត់ទោស" ប៉ុន្តែក៏មានប្រើផងដែរ "ធ្វើដោយប្រោសប្រណី" ដោះឲ្យរួច ដោះលែង លើកទោស បញ្ជូនទៅ រំសាយចេញ" "ដោយប្រោសប្រណី ដោយមេត្តាករុណា" ហើយនិង "ការមើលរំលង ការឲ្យរួចខ្លួនមិនប្រកាន់ទោស" ។ ពាក្យទាំងនេះចង្អុលបង្ហាញប្រាប់ឲ្យយើងដឹងតាមជ្រុងផ្សេងៗនៃ "ព្រះគុណរបស់ព្រះ ដែលមិនអាចរកអ្វីមកប្រៀបផ្ទឹមបាន ដែលបានបញ្ជាក់ឲ្យដឹងតាមរយៈព្រះយេស៊ូគ្រីស្ទ" (អេភេសូ ២:៧) ។

ការយកតម្រាប់របស់យើងតាមគំរូរបស់ព្រះជាម្ចាស់ ។ តើយើងប្រើគំរូនៃការដោះស្រាយជាមួយអំពើបាប របស់ព្រះជាម្ចាស់ ដើម្បីតម្រង់យើងនូវរបៀប ដែលយើងត្រូវឆ្លើយតបទៅមនុស្ស ដែលធ្វើខុសនឹងយើង ដោយរបៀបណា? ទីមួយយើងត្រូវឲ្យឈ្មោះនូវអំពើខុសឆ្គងនោះឲ្យត្រឹមត្រូវតាម

លក្ខណៈរបស់វា ។ នៅពេលដែលអ្នកណាម្នាក់ប្រព្រឹត្តខុសឆ្គងទាស់នឹងខ្ញុំនោះ ខ្ញុំត្រូវហៅថាវាជាអំពើបាប ។ ខ្ញុំត្រូវជួយឲ្យមនុស្សម្នាក់ដែលប្រព្រឹត្តឆ្គងនោះ ឃើញថា វាជាអំពើបាប ។ ព្រះយេស៊ូបានបង្រៀនថា "បើសិនជាបង ឬ ប្អូន ធ្វើបាបនឹងអ្នក នោះឲ្យទៅបន្ទោសគាត់ឲ្យដឹងពីកំហុសរបស់គាត់" (ម៉ាថាយ ១៨:១៥) ។ គាត់មានកំហុសប្រាប់ពីឈ្មោះនៃកំហុសនោះ ហើយនឹង បង្ហាញ គាត់ថានោះវាជាកំហុស ។

ខ្ញុំមិនត្រូវធ្វើមិនដឹងមិនឮទេ មិនប្រាប់ឲ្យស្គាល់ឈ្មោះនូវកំហុសនោះ ហើយនិង មិនត្រូវទុកឲ្យវាបន្តធ្វើឲ្យខ្ញុំខឹងឡើយ ។ សេចក្តីបង្រៀនរបស់ព្រះ យេស៊ូ រំលឹកឲ្យយើងនឹកឃើញដល់ លេវីវិន័យ ១៩:១៧ «មិនត្រូវឲ្យមានចិត្ត ស្អប់ដល់បងប្អូនឯងឡើយក៏កុំឲ្យខាននឹងបន្ទោសដល់អ្នកជិតខាងឯងដែរ ដើម្បី កុំឲ្យជាប់មានបាបដោយព្រោះគេ» ការទុកអំពើបាបដោយមិនបានប្រាប់ឲ្យដឹង និង ដោយមិនបានដោះស្រាយតទល់គ្នានោះ នាំឲ្យវាក្លាយទៅជាសេចក្តីសំអប់ ដោយហេតុនោះអំពើបាបបានដោរឡើងខ្លាំង ។ ពីព្រោះតែកំពុងតែមានចិត្តគុំ ដល់មនុស្សម្នាក់ទៀតនោះ ឥឡូវខ្ញុំក៏មានពិរុទ្ធភាពដូចគាត់នោះដែរ ។ ដូច្នេះ ជំហានដំបូងក្នុងការដោះស្រាយជាមួយនឹងអំពើបាប គឺថាត្រូវប្រាប់ ឲ្យដឹងថាវា ជាអំពើបាប ។

ដើម្បីគូសបញ្ជាក់ប្រាប់ឲ្យដឹងពីគំរូដែលគួរឲ្យសោកស្តាយក្នុងចំណោម ជនជាតិខ្មែរ ក្នុងប៉ុន្មានឆ្នាំក្រោយពីជំនាន់ប៉ុល ពត ដែលបានបដិសេធ ឬ ធ្វើមិនដឹងមិនឮកំហុសពីអតីតកាល ។ មានការឈឺចាប់យ៉ាងខ្លាំងណាស់ ដើម្បី នឹងប្រឈមមុខ ចំពោះអំពើឧក្រិដ្ឋរបស់ខ្មែរក្រហមបានត្រូវគេខំបំភ្លេចនៅក្នុង គំនិត ដែលបន្សល់ទុកឲ្យជនរងគ្រោះរបស់អំពើនេះ ខំត្រដរប្រយុទ្ធនឹងអំពើ នេះនៅក្នុងគំនិតតែម្នាក់ឯង និង ទាំងមិនដឹងខ្លួនច្បាស់ ។ ដោយហេតុនេះ ហើយ ទើបបានក្លាយជារំពារនៃការធ្លាក់ទឹកចិត្ត និង មានសញ្ញានៃការកើតពោគវិបត្តិ ផ្លូវចិត្ត ។ «ចូរយើង បំភ្លេចរឿងអតីតកាលទៅ» អ្នកខ្លះបានស្នើឲ្យធ្វើបែបនេះ ។ ប៉ុន្តែការធ្វើទារុណកម្ម និង ការកាប់សម្លាប់យ៉ាងសាហាវយង់ឃ្នងមិនមែនជា រឿងដែល «ងាយបំភ្លេច» នោះឡើយ ។ វាជាអំពើបាប វាជាអំពើឧក្រិដ្ឋ ហើយ និងអំពើទាំងនោះត្រូវតែបង្ហាញឲ្យដឹង ទើបការផ្សះផ្សាដំបៅដួងចិត្តនោះអាច ជាបាន ។

នៅពេលដែល «កំហុស» ឬ «អំពើបាប» ណាមួយបានបង្ហាញឲ្យដឹង យើងត្រូវតែប្រឈមមុខនឹងភាពធ្ងន់ធ្ងររបស់វា ។ អំពើបាបដែលលាក់ទុក មិនបានលើកមកនិយាយ និង មិនបានអត់ទោសឲ្យនោះ ធ្វើឲ្យខូចដល់បំណងល្អក្នុងគ្រួសារ មិត្តភក្តិ និង អ្នកជិតខាង ។ ហេតុផលមួយដែលត្រូវប្រឈមមុខដោះស្រាយ និង អំពើបាបនោះគឺថា ដើម្បីជួសជុលនូវទំនាក់ទំនងនោះឲ្យល្អប្រសើរឡើងវិញ ។ ការធ្វើមិនដឹងមិនឮ វាធ្វើឲ្យមានការបាក់បែកជាបន្ត និង កាន់តែធំឡើង ។ ការប្រឈមមុខដោះស្រាយ ដែលមានគំនិតជួយកែលំអផងនោះក៏ជួយឲ្យយើងប្រយុទ្ធនឹងសេចក្តីល្បួង ដែលនាំឲ្យមានការសងសឹកនោះ ដែលបានហាមឃាត់យ៉ាងច្បាស់នៅក្នុងបទគម្ពីរ (រ៉ូម ១២:១៧-២១) ។

នៅក្នុងខណៈ ដែលខ្ញុំប្រឈមមុខដោះស្រាយជាមួយបងប្អូនរបស់ខ្ញុំ ដែលគាត់បានធ្វើបាបទាស់នឹងខ្ញុំ បំណងរបស់ខ្ញុំគឺដូចជាបំណងរបស់ព្រះជាម្ចាស់ដែរ គឺដើម្បីជំរុញឲ្យលន់តួ ដូច្នេះធ្វើឲ្យមានការពង្រីកការអត់ទោសបាបរបស់ខ្ញុំចំពោះគាត់ ។ ព្រះរាជបញ្ជារបស់ព្រះយេស៊ូ «ចូរទៅបង្ហាញឲ្យគាត់ដឹងពីកំហុសរបស់ខ្លួន» ហើយបន្តទៀតថា «បើគាត់ព្រមស្តាប់អ្នកអ្នកនឹងបានបងប្អូនរបស់អ្នកមកវិញ» ។ ការប្រេះឆាបានជាឡើងវិញ ។ នៅកន្លែងដទៃទៀត ព្រះយេស៊ូបានបន្ថែមគំនិតថា «បើបងប្អូនធ្វើបាបនឹងអ្នក ត្រូវឲ្យអ្នកបន្ទោសដល់គាត់ បើគាត់ប្រែចិត្តមកវិញ នោះ ចូរអត់ទោសដល់គាត់ចុះ បើគាត់ធ្វើបាបនឹងអ្នក ៧ ដង ក្នុង ១ ថ្ងៃ ហើយត្រឡប់មកនិយាយនឹងអ្នក ៧ ដង ថា ខ្ញុំប្រែចិត្តហើយ នោះត្រូវឲ្យអ្នកអត់ទោសដល់គាត់ជាកុំខាន» (លូកា ១៧:៣-៤) ។ បើការអត់ទោសរបស់មនុស្ស វាស៊ីគ្នានឹងការអត់ទោសរបស់ព្រះជាម្ចាស់ វាត្រូវតែ ១) ភាគីដែលរងការឈឺចាប់ត្រូវស្វែងរកការអត់ទោសនោះ (លូកា ១៩:១០); ២)ពង្រីកការអត់ទោសបាប ដោយសប្បុរសបំផុត (ទំនុកតម្កើង ១០៣:១២) ; ៣)ពង្រីកដោយអចិន្ត្រៃយ៍ (ហេប្រឺ ១០:១៧); ៤) ពង្រីកការអត់ទោសបាបម្តងហើយម្តងទៀត (លូកា ១៧:៤) ហើយនិង ៥) ពង្រីកនូវការអត់ទោសបាបនេះ សូម្បីតែអស់អ្នកទាំងឡាយ ដែលបានធ្វើបាបដ៏សាហាវយង់ឃ្នង (២របាក្សត្រ ៣៣:៩-១៣) ។

ការអត់ទោសបាបវាខុសគ្នា និង ផលវិបាក ។ ការអត់ទោសបាបភាគីទាំងពីរ គឺត្រូវលុបចោលការដាក់ទណ្ឌកម្មផ្នែកតុលាការ ដែលអំពើបាបនោះ

ត្រូវទទួលយក ហើយនិងអនុញ្ញាតឲ្យទំនាក់ទំនងរវាងអ្នកធ្វើបាប ហើយ និងអ្នករងនូវការធ្វើអំពើបាបបានជានានឹងគ្នាឡើងវិញ ។ ប៉ុន្តែមិនមែនបានសេចក្ដីថាផលវិបាកទាំងឡាយដែល បណ្ដាលមកពីអំពើបាបនោះ ត្រូវតែលុបចោលទាំងអស់នោះទេ ។ បើស្ត្រីម្នាក់ជ្រើសរើសប្រឡូកក្នុងការសេពសុរាអស់រយៈពេលជាច្រើនឆ្នាំ ហើយក្រោយមកកែប្រែចិត្ត ព្រះជាម្ចាស់នឹងអត់ទោសបាបឲ្យ ប៉ុន្តែមិនមែនបានសេចក្ដីថា ព្រះអង្គនឹងផ្ដល់ថ្លើមថ្មីឲ្យ និងផ្ដល់ឲ្យគាត់មានសុខភាពល្អដូចដើមនោះទេ ។ បើបុរសម្នាក់ជ្រើសរើសរស់នៅក្នុងជីវិតមួយដែលមិនខ្វល់ខ្វាយ រឿងថែទាំកូនចៅ និង គិតតែពីវាយដំប្រពន្ធ ព្រះជាម្ចាស់អាចអត់ទោសបាបបែបនោះបាន ប៉ុន្តែមិនអាចធ្វើឲ្យប៉ុន្មានឆ្នាំ ដែលគាត់បានប្រព្រឹត្តនោះបានជានាឡើងវិញ ឬ ក៏ការចងចាំដែលគាត់មានទាំងប៉ុន្មានឲ្យរលប់ បាត់ពីអារម្មណ៍របស់គាត់បានឡើយ ។ ការអត់ទោសបាបមិនចាំបាច់ថាទាល់តែលុបបំបាត់ឲ្យអស់នូវផលវិបាកទាំងឡាយនោះឡើយ ។ ព្រះគម្ពីរបង្ហាញថាការនេះជាការពិត ។ នៅពេលដែលព្រះបាទដាវីឌប្រព្រឹត្តបាប ហើយនិង បានលន់តួបាប ណាថាន់បានអះអាងនឹងទ្រង់យ៉ាងច្បាស់ថា «ព្រះយេហូវ៉ា (យ៉ាវេ) បានដកយកអំពើបាបរបស់ទ្រង់ហើយ ។ ព្រះអង្គនឹងមិនសុគតឡើយ [គឺថាព្រះអង្គទទួលបាននូវការអត់ទោសហើយ] ។» ប៉ុន្តែណាថាន់បានបន្តទៀតថា "ពីព្រោះតែព្រះអង្គបានធ្វើការនេះ ទ្រង់បានធ្វើឲ្យក្លាយជាខ្មាំងសត្រូវនៃព្រះយេហូវ៉ាហើយ ដែលបង្ហាញថាមានការមើលងាយដល់ព្រះជាម្ចាស់ ដូច្នេះបុត្រាដែលត្រូវកើតមកនោះត្រូវសុគត [គឺថាទ្រង់ និង គ្រួសាររបស់ព្រះអង្គត្រូវរងនូវការឈឺចាប់ចំពោះផលវិបាកទាំងឡាយនេះ ] ។"

ដោយការអនុវត្តន៍តាមគោលការណ៍នេះ យើងត្រូវតែអត់ទោសដល់ បងប្អូនដែលបានធ្វើបាបទាស់នឹងយើង ហើយព្រមកែប្រែចិត្ត គឺថាយើង ត្រេកអរ និងប្រកបជាមួយអ្នកនោះម្ដងទៀត ដោយគ្មានប្រកាន់នូវការប្រទូស្ត រាយអ្វីឡើយ ។ ប៉ុន្តែអំពើបាបរបស់គាត់ ដែលបានអត់ទោសឲ្យហើយនោះ ទោះ ជាយ៉ាងណាក៏ដោយអាចមានការប្រែប្រួល ចំពោះទំនាក់ទំនងរបស់ខ្ញុំជាមួយគាត់នៅថ្ងៃអនាគត ។ ខ្ញុំអាចមានការរារែកចិត្តក្នុងការឲ្យខ្ចីកុំព្យូទ័រទៅមនុស្សដែលធ្លាប់ធ្វើខូចពីរដងរួចមកហើយ ដោយសារតែទង្វើខ្ចីខ្វាពីលើកមុន នៅពេលដែលខ្ញុំបានឲ្យគាត់ខ្ចីកុំព្យូទ័ររបស់ខ្ញុំ ។ ហិរញ្ញិក ដែលកាន់ថវិកានៅព្រះវិហារម្នាក់ ដែល

បានបន្តំប្រាក់ព្រះវិហារ អ្នកនោះអាចអត់ទោសឲ្យបានដោយសំអាងលើការកែប្រែចិត្តដោយស្មោះស ប៉ុន្តែគេមិនយកអ្នកនោះឲ្យកាន់ការងារបែបហ្នឹងម្តងទៀតឡើយ ។ គ្រូគង្វាលម្នាក់ដែលខុសសីលធម៌ផ្នែកភេទ ព្រះជាម្ចាស់ និង ក្រុមជំនុំរបស់គាត់អាចអត់ទោសឲ្យគាត់បាន ប៉ុន្តែគាត់លែងក្លាយ ជាមនុស្សដែល "ឥតកន្លែងចាប់ទោសបាន" ទៀតឡើយ (ដូចមានចែងក្នុង ១ធីម៉ូថេ ៣:៣ ត្រូវឲ្យមានអ្នកត្រួតត្រា) ហើយដោយហេតុនោះ មិនគ្រប់លក្ខណៈសម្បត្តិធ្វើជាគ្រូគង្វាលបន្តទៀតឡើយ ។ អំពើបាបអាចអត់ទោសឲ្យជាពិតប្រាកដមែន ប៉ុន្តែផលវិបាករបស់វានៅជាប់តមករហូត ។

នេះជាមធ្យោបាយដ៏ពិតប្រាកដ សំរាប់ការអត់ទោសបាប ចំពោះប្រជាជាតិ ក៏ដូចគ្នានឹងការអត់ទោសបាប សំរាប់ផ្ទាល់ខ្លួនម្នាក់ៗដែរ ។ អ្នកដែលបានប្រព្រឹត្តបទឧក្រិដ្ឋយ៉ាងធ្ងន់ធ្ងរ ប្រឆាំងនឹងមនុស្សជាតិ ហើយបានកែប្រែចិត្ត (ដូចជាម៉ាណាសេ-ដូច្នេះដែរនោះ សូមមើល ២របាក្សត្រ ៣៣:១-២០) ព្រះជា ម្ចាស់ និង ជនរងគ្រោះអាចអត់ទោសឲ្យបាន ។ តែទោះជាយ៉ាងណាក៏ដោយ ប្រទេសជាតិអាចនៅតែព្យាយាម និង ដាក់ទណ្ឌកម្មដល់គាត់ ចំពោះអំពើឧក្រិដ្ឋទាំងឡាយនោះ ។ ការអត់ទោសរបស់ព្រះជាម្ចាស់ និង ការអត់ទោសរបស់ យើង មិនលុបបំបាត់ ឲ្យអស់នូវផលវិបាកទាំងអម្បាលម៉ាននោះឡើយ ។

វាជាការល្អសំរាប់យើង ។ អស់រយៈពេលជាច្រើនឆ្នាំ ពួកអ្នកចិត្តវិទូមិនបានសិក្សាស្រាវជ្រាវអំពីការអត់ទោសបាបឡើយ ។ ប៉ុន្តែឥឡូវនេះត្រូវបានគេរកឃើញនូវប្រយោជន៍ដ៏សំខាន់ ចំពោះការផ្សះឲ្យជាដល់អារម្មណ៍ (ផ្នែកចិត្ត) និង ផ្នែករាងកាយទាំងស្រុង ។ ទោះបីជាអ្នកប្រព្រឹត្តបាបបានចំណេញ ដោយព្រោះអំពើបាបរបស់ខ្លួនបានអត់ទោសឲ្យក៏ដោយ ជនរងគ្រោះដែលបានអត់ទោសឲ្យគេនោះក៏ចំណេញដែរ ។ លើសពីនេះទៀត ការអត់ទោសបាប បានបំបាត់នូវវិវត្តន៍វិលចុះវិលឡើង នៃការសងសឹកដែលមិនចេះចប់ ជាហេតុ បណ្តាលឲ្យគ្រួសារ ឬ សង្គម (សូមគិតពី កូសូវ៉ូ ; អ៊ីស្រាអែល ហើយនិង អៀឡង់ខាងជើង) កាន់តែបាក់បែករីកធំឡើង រហូតធ្លាក់ដល់នាំឲ្យមានអំពើហិង្សា ។

សេចក្តីថ្លែងការណ៍របស់ជនជាតិខ្មែរ ។ នៅថ្ងៃទី ១៧ ខែ ឧសភា ១៩៩៩ មានអ្នកដឹកនាំគ្រីស្ទបរិស័ទមួយចំនួនបានមកជួបប្រជុំ ដើម្បីពិភាក្សាលើបញ្ហានៃអំពើឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ការប្រែចិត្ត ការអត់ទោសបាប

ហើយនិងផលវិបាកផ្នែកចៅក្រម ដោយសារតែហេតុនេះ ទើបមានការជួប ប្រជុំគ្នាពីរលើកជាបន្តបន្ទាប់គ្នា សេចក្តីថ្លែងការណ៍មួយត្រូវបានគេរៀបចំឡើង ជាសេចក្តីពង្រាងស្តីអំពីបញ្ហាទាំងឡាយនេះ ។ សេចក្តីថ្លែងការណ៍នេះមាន ដូចតទៅ ៖

**ការអត់ទោសចំពោះអស់អ្នកដែលជាប់មានពិរុទ្ធភាពនៃអំពើឃោរឃៅ**

ព្រះ ដែលជាព្រះអាទិករ និង ជាព្រះអម្ចាស់លើទាំងអស់ ព្រះអង្គស្អប់ ខ្ពើមការសង្កត់សង្កិន និង ការប្រព្រឹត្តអំពើឃោរឃៅប្រឆាំងមនុស្សជាតិ ។ ព្រះ អង្គចាត់ទុកអំពើទាំងនោះ ជាទីស្អប់ខ្ពើមបំផុត ។ ទ្រង់មិនបំភ្លេចចោល ឬ ទតរំលងអំពើទាំងនោះទេ ទោះបីជាគេបានប្រព្រឹត្តការនោះរយៈពេលយូរយ៉ាង ណាក៏ដោយ ។ ព្រះអង្គនឹងជំនុំជំរះ ចំពោះអស់អ្នកណា ដែលប្រព្រឹត្តនូវអំពើ ឧក្រិដ្ឋបែបនោះ ។

**លោកុប្បត្តិ ៦:៥-៧, ចោទិយកថា ២៥:១៧-១៩, អេសេគាល ១៨:២០**

ប៉ុន្តែទោះបីជា អ្នកទាំងនោះទទួលខុសត្រូវចំពោះអំពើឃោរឃៅក៏ដោយ ក៏ព្រះស្រឡាញ់មនុស្សគ្រប់គ្នា ។ ព្រះអង្គបានអះអាងថា ទ្រង់នឹងអត់ទោសចំពោះ អស់អ្នកណា ដែលព្រមលន់តួបាបខ្លួនចំពោះទ្រង់ ដោយសុទ្ធចិត្ត ឲ្យតែការលន់តួ នោះស្របជាមួយនឹងជំនឿប្តូរផ្តាច់ ហើយព្រមដើរតាមព្រះយេស៊ូគ្រីស្ទ ។ អ្នក ដែលលន់តួបាបខ្លួនចំពោះ ព្រះជាម្ចាស់រមែងទទួលបានការអត់ទោសពីព្រះអង្គ ។ ឯការអត់ទោសនោះ មិនពឹងផ្អែកទៅលើ កុសលផលបុណ្យ ដែលគាត់បានធ្វើ នោះទេ ទោះបីជាការនោះអាចជួយឲ្យគាត់ក្លាយទៅជាមនុស្សល្អ ឬ គាត់សន្យាថា នឹងធ្វើល្អនៅថ្ងៃមុខក៏ដោយ ។ ដ្បិតការអត់ទោសនោះ គឺជាអំណោយទានមកពី ព្រះ ពោរពេញទៅដោយការប្រោសប្រណី ដែលមនុស្សមានបាបក្នុងសណ្ឋាន ណាក៏ដោយ មិនស័ក្តិសមនឹងទទួលទាល់តែសោះ ។ នៅពេលដែលព្រះគុណា របស់ផងព្រះអង្គ គឺល្មមគ្រប់គ្រាន់ហើយ ដើម្បីនឹងទោសដល់អំពើបាបរបស់ យើង នៅពេលដែលយើងព្រមកែប្រែ និង ទុកចិត្តដល់ព្រះយេស៊ូ ។

**យ៉ូហាន ៣:១៦, ៦:៣៧, ១ធីម៉ូថេ ១:១២-១៦**

តើការអត់ទោសអស់កល្បជានិច្ចមានយុត្តិធម៌ដែរឬទេ? តើជនដៃដល់ គ្រប់រូប ដែលជាប់ពិរុទ្ធពីបទសង្កត់សង្កិន ត្រូវទទួលទណ្ឌកម្មពីព្រះជាម្ចាស់ជា រៀងរហូតឬ ? ចម្លើយគឺយ៉ាងដូច្នេះ - សេចក្តីជំនុំជំរះរបស់ព្រះជាម្ចាស់ចំពោះ

មនុស្សមានបាបត្រូវបានជនម្នាក់ទៀតទទួលរងជំនួស ។ ព្រះជាម្ចាស់បានបញ្ជូនព្រះយេស៊ូឲ្យមកទទួលទោសប្រហារជីវិត ហើយសុគតជំនួសអ្នកដទៃ ។ ព្រះអង្គគ្មានទោសទាល់តែសោះ ប៉ុន្តែទ្រង់ព្រមសុគតជំនួស មនុស្សមានបាប ។ ដោយហេតុថាព្រះយេស៊ូ ជាព្រះរាជបុត្រានៃព្រះ ការសុគតរបស់ទ្រង់ផ្តល់នូវការរងទារុណកម្មគ្រប់គ្រាន់សំរាប់អំពើបាបរបស់មនុស្សជាតិទាំងអស់ ។

ការសុគតនោះ មានប្រសិទ្ធិភាពចំពោះអស់អ្នកដែលកែប្រែចិត្ត និង ជឿតាមទ្រង់ប៉ុណ្ណោះ ។ ជំនឿលើព្រះយេស៊ូគ្រីស្ទ ដែលទាមទារ ការបែរចេញពីអំពើបាបមកដើរតាមទ្រង់ នោះពិតជានាំមកនូវការអត់ទោសអស់កល្បជានិច្ច អំពីព្រះជាម្ចាស់ ដោយសារព្រះគ្រីស្ទបានបង់ថ្លៃបាបជំនួសហើយ ។

**អេសាយ ៥៣:៤-៦, ម៉ាកុស ១០:៤៥, ២កូរិនថូស ៥:២១, រ៉ូម៣:៩-២៦**

ព្រះជាម្ចាស់ ជាព្រះ ដែលតែងតែអភ័យទោសឲ្យ ព្រះអង្គបានត្រាស់ហៅរាស្ត្រទ្រង់ម្នាក់ៗឲ្យត្រាប់តាមព្រះអង្គដែរ ។ ពេលខ្លះការនេះ ហាក់ដូចជាពិបាកមែន ប៉ុន្តែជានិច្ចកាលព្រះជាម្ចាស់ជួយដល់អ្នកណា ដែលសូមដល់ទ្រង់ឲ្យចេះអត់ទោសចំពោះអ្នក ដែលបានរំលោភបំពានមកលើខ្លួន ។ ការផ្តន្ទាទោសស្រេចលើព្រះជាម្ចាស់ ពោលគឺមិនមែនស្រេចលើយើងទេ ។ បើព្រះអង្គអភ័យទោសឲ្យអ្នកណាហើយ យើងក៏ត្រូវតែអភ័យទោសឲ្យអ្នកនោះដែរ ។

**រ៉ូម ១២:១៤, ១៧-២១, ម៉ាថាយ ៦:១២, ១៨:១៥-៣៥**

ការអភ័យទោសរបស់ព្រះជាម្ចាស់ មិនមែនមានន័យថា ជួយសង្គ្រោះឲ្យរួចពីផលវិបាកនៃពិរុទ្ធភាពនៅក្នុងជីវិតនេះបានទេ ។ បាបរបស់យើងជះឥទ្ធិពលដល់សុខភាព សម្ព័ន្ធភាព និង ការទទួលខុសត្រូវរបស់យើង ។ ជនណាក៏ដោយដែលជាឧក្រិដ្ឋជន ត្រូវតែទទួលការកាត់ទោសពីរដ្ឋាភិបាល ។ ក្នុងករណីនេះ ព្រះជាម្ចាស់មិនអនុញ្ញាតឲ្យឧក្រិដ្ឋជនណារួចខ្លួនពីចំពោះមុខច្បាប់រដ្ឋឡើយ ។ យ៉ាងណាមិញ អស់អ្នកទាំងឡាយណា ដែលបានប្រព្រឹត្តអំពើមនុស្សឃាត និង អំពើសាហាវយង់ឃ្នង ទោះបីជាគ្រីស្ទាន ឬ មិនមែនគ្រីស្ទានក្តី ចាំបាច់ត្រូវតែប្រឈមមុខនឹងការកាត់ក្តីរបស់តុលាការ ។ ព្រះជាម្ចាស់បានប្រគល់សិទ្ធិអំណាចឲ្យរដ្ឋាភិបាលផ្តន្ទាទោសដល់ឧក្រិដ្ឋជន និង ការពារប្រជាជនតាមច្បាប់ដ៏យុត្តិធម៌ និង តាមទំរង់ការដ៏សមស្របនានារបស់តុលាការ ។ ដូចគ្នានេះដែរ រដ្ឋាភិបាល ត្រូវតែទទួលខុសត្រូវចំពោះព្រះជាម្ចាស់ ពីរបៀបដែលគេអនុវត្តសិទ្ធិអំណាចនេះ ។ ព្រះ

ជាម្ចាស់មិនបណ្តោយឲ្យជនណាម្នាក់រួចពីប្រព័ន្ធច្បាប់ឡើយ ទោះបីជននោះ បានសារភាពបាប កែប្រែចិត្តគំនិត និង ទទួលការអភ័យទោសអំពីព្រះជាម្ចាស់រួចហើយក៏ដោយ ។ សាលក្រមរបស់តុលាការមិនអាចប៉ះពាល់ ដល់ការអត់ទោសបាបដ៏នៅអស់កល្បរបស់ព្រះជាម្ចាស់បានឡើយ ។

២សាំយ៉ូអែល ១២:១១-១៤, រ៉ូម ១៣:១-៧

រដ្ឋាភិបាលអាចសំរេចនូវប្រការណា ដែលប្រសើរបំផុតក្នុងការបំពេញតួនាទី ដែលព្រះជាម្ចាស់បានប្រគល់ជូន ដើម្បីទទួលខុសត្រូវលើការពិន័យទោសដល់ពិរុទ្ធជន ដែលច្បាប់កំណត់ថា បានប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ។ ទោះបីយ៉ាងណាក៏ដោយ បើសិនជាតុលាការយល់ឃើញថា ជនជាប់ចោទបានផ្លាស់ប្រែចិត្ត គំនិតពីអតីតកាលរបស់ខ្លួនពិតប្រាកដមែន ដោយមានភស្តុតាងបញ្ជាក់អំពីការផ្លាស់ប្តូរអាកប្បកិរិយាផ្ទុយពីមុខស្រឡះនោះ តុលាការអាចផ្អាកការចេញសាលក្រមក្នុងពេល ដែលកំពុងស្រាវជ្រាវបទល្មើសរបស់ជនជាប់ចោទ បាន ។ តុលាការត្រូវតែសំរេចប្រកបដោយគតិយុត្តិធម៌នូវប្រការណា ដែលខ្លួនយល់ឃើញថាប្រសើរបំផុត ក្នុងការជំនុំជំរះក្តី ដែលមានភាពវិសាមញ្ញបែបនេះ ។

១ពង្សាវតាក្សត្រ ២១:២០-២៩, ២របាក្សត្រ ៣៣:៩-១៣

ហេតុដូច្នេះ រដ្ឋាភិបាល ប្រើសិទ្ធិរបស់ខ្លួននៅពេលដែលគេដាក់ទោសដល់ឧក្រិដ្ឋជន សូម្បីតែជននោះ បានកែប្រែចិត្តហើយក៏ដោយ ។ តាមពិតទៅតុលាការអាចសំរាលទោស ឬ អត់ទោសចំពោះការកាត់ទោសដល់អ្នក ដែលបានកែប្រែចិត្តពិតប្រាកដ នឹកឃើញសំដី ផចៀ (Portia) នៅក្នុងរឿងរបស លោក សេក្សភា ឈ្មោះ Merchant of Venice ដែលថាអំណាចនៅដែនដីប្រហាក់ប្រហែលអំណាចរបស់ព្រះជាម្ចាស់ដែរ នៅពេលដែលសេចក្តីមេត្តាករុណាផ្តល់សរជាតិដល់សេចក្តីយុត្តិធម៌ ។ ប៉ុន្តែមិនថាឡើយមានផលវិបាកច្រើនយ៉ាងនៅលើផែនដីនេះ ដែលអាចកើតឡើងដោយសារសកម្មភាព ដែលប្រកបដោយអំពើបាបសូមឲ្យយើងម្នាក់ៗធ្វើតាមសេចក្តីទូន្មានរបស់ពួកសាវ័ក«ចូរឲ្យមានចិត្តសប្បុរស និង អាណិតអាសូរដល់គ្នាទៅវិញទៅមក អត់ទោសគ្នាទៅវិញទៅមក ដូចជាព្រះជាម្ចាស់អត់ទោសឲ្យអ្នករាល់គ្នាក្នុងព្រះគ្រីស្ទដែរ» ។

HONEYCOMB 1/1 (July 2000): 24–31

# Wholistic Ministry and Mission

*Graham CHIPPS*

Wholism and wholistic ministry (including mission) are about being servants of others—being concerned for the whole person and the whole of the context in which he or she lives. Each one of the following is true for every person in every country:

- Each person is created in the image of God, but each one has become self-serving and rebellious through a heart of sin. Each person is a sinner who has also been sinned against.
- Each person is a system of physical, intellectual, relational and social, spiritual, psychological and emotional, moral, volitional, and cultural dimensions. Each part of the system significantly influences all the others.
- Each person lives within a context of culture, family, politics, spiritual forces, society and nation, environment, economics, art, entertainment, law and education.
- Each person is designed to be in relationship with God and each is dysfunctional in everything whenever this relationship is weak or non-existent.
- Each person is condemned to eternal death by their sin, unless by God's grace she or he is joined to Jesus Christ through faith.

Wholistic ministry recognizes the importance of addressing all these areas of life if the well-being of persons and nations is to be increased beyond the superficial. Our understanding of what is and is not in the interests of this well-

being is determined by what God says is right and good in the Bible.

However, different reasons are given by people as to why wholistic ministry is good. There are three different approaches. The first is unethical, the second is good but limited, and the third is best because its focus is Christ and His supremacy rather than on the needs of people. These approaches are:

1) **Wholistic ministry as a means to an end.** Wholistic ministry has no value in and of itself except as a way to get easier access to people to then evangelize them. This is the motivation which sees everything else as just a way of influencing people to listen to the Gospel. This reason is deceitful, manipulative, unacceptable, contrary to Scripture and dishonouring to God.
2) **Wholistic ministry as an expression of love and a longing for justice and goodness in all of life.** Wholistic ministry is motivated by a desire to care for people. It addresses their needs and all the issues of life so that their well-being is increased, and they are less burdened by the failings of individuals and societies. This reason is good and Biblical, but it leaves out the more important motivations which focus on God's purposes as noted in approach 3) below.

   An example of this is the exhortation to do "good works." This expression in the first century emphasized the value of contributing to the local community. It could be as small as helping out a neighbour, or something much larger such as emergency relief or a development project which benefits the whole community.
3) **Wholistic ministry as a submission to the reign of Christ.** Wholistic ministry follows the recognition that as God's servants, we are called to seek after His will in all things as He works in the world. God is working out His purposes through the rule of His Son Jesus and His purposes involve the wholistic transformation of all creation (except for what He removes through judgment).

This reason is the strongest motivation because it starts and ends in God's will in Christ. The following points describe this wholistic work of God.

## The Very First Wholistic Ministry.

God has always been wholistic in His work. His creation includes all the ingredients of life noted above—except sin and its consequences. He created all things: the visible and the invisible, the personal and the impersonal, the material and the spiritual, each individual human being and the society in which he or she lives, the earthly and the heavenly, the psychological and the intellectual, the lowly things and the rulers and authorities. He created male and female, sky and sea, plants and animals in multiple species, wind and water, rocks and clouds. His creation is a living, breathing, changing work of art. This creative work of great beauty was perfect every moment of every day, and yet every moment it changed without losing any of its perfection. And God declared it to be very good (Genesis 1:31).

Since then, human sin and Satanic pollution have done all they could, but despite the damage they have done and the curse of God in judgment (Genesis 3), this creation still retains much of the goodness God created. The creation reflects God's glory and speaks to us of His character and power (e.g. Psalms 8, 19, 104, 148).

We need to appreciate how much the creation continues to bring God pleasure and how much He grieves when His work of art is treated with contempt. The human race has been given management responsibility for the creation and we have not done this at all well. When we disregard our responsibility to manage well all He has made, we have adopted an attitude in which God Himself is not respected.

## Sin, Society and Creation.

In Genesis 3–11, we read of the consequences of human sin. All of life was and still is affected—even the earth itself.

Human society grows in pride, evil, and corruption, and God's judgments then included a massive flood and the scattering people into different languages. Even brothers turned against brothers in murder.

The relationship between sin and the whole of creation is strongly expressed in the cursing of the ground and the major change in relationships and work when God's judgment came in Genesis 3:17–19. Likewise, Paul describes the liberation of the whole creation from the curse and decay of sin as being directly associated with the liberation from sin which God brings to His children. God is being quite wholistic in all this.

Furthermore we often read in the Mosaic Law, in the Psalms and in the Prophets of God's passion for the victims of sin: the poor, orphans, widows, the oppressed, the prisoners, refugees. Sin inevitably involves idolatry, injustice, greed, and immorality; as a result, many individuals are traumatized and nations become places of cruelty and violence. All of the consequences of individual and corporate sin are His concern. The whole of each person, the whole of every society and the whole of creation have all fallen short of perfectly displaying the glory of God. God's heart and mind often are described as deeply grieved by sin and all its consequences. God's passion and compassion are perfectly wholistic—as are His promises as to what He will do about His polluted and broken world.

### The Promises of God.

Even on the day on which the curse of judgment was first declared, God indicated that His promise was to overthrow the realm of evil. The child of the woman will crush the head of Satan (Genesis 3:15). To Abraham God promised blessing to all the nations of the earth. The law of Moses reflects the ideals of Godly society—holiness, compassion, and justice, with particular concern for the weak and vulnerable. All things in such a society are in harmonious relationship with all else (including the earth itself) in so far as all things are in harmonious relationship with God. This

law gives us much insight into the kind of society which will bring the blessing to all nations promised to Abraham.

The most central dimension to these promises of God is the promise of a Shepherd-King who is a descendent of King David and who is also Son of God (Psalm 2) and Son of Man (Daniel 7:9–14). He is Messiah, and it is through His rule over all nations that God will fulfill every promise. The prophets repeatedly speak of this Messiah (e.g., Isaiah 9:6–7, 11:1–5, 32:1–5, 42:1–7, 52–53, 61:1–9, Jeremiah 23:5–6, 33:15–16, Ezekiel 34:20–31, 37:24–28, Amos 9:11–15.) He will be the servant of God who will be the atoning sacrifice for sin (Isaiah 53).

Ezekiel and Jeremiah promise that God will purify and soften the human heart so that people incline towards God rather than against Him. Isaiah, Joel, and Ezekiel declare that God's Holy Spirit will be poured out to bring transformation—healing, purification, renewal. Isaiah emphasizes justice, peace, and righteousness for all the nations of earth. Several promise God's forgiveness. Those most victimized by sin will find God's freedom from poverty and oppression. Nations will cease to war against each other. Even amongst animals there will be harmony.

In short, the promise of God is to address the whole of life and bring changes to all things such that everything in heaven and earth is fully in accordance with His will. The Kingdom promised is global, wholistic and complete in every way. The inheritance promised to all who have faith as Abraham had faith is the whole earth fully transformed in accordance with God's Kingdom rule in Christ.

## The Coming of Messiah.

When Jesus commenced His ministry, He announced the beginnings of the rule of Messiah to fulfill God's promises. Regardless of how small the beginning, the work of God's Kingdom had begun. Jesus and the apostles are reported to have been constantly speaking of the Kingdom; it was central to their Gospel. Through the essential moments of His life, Jesus inaugurates the promised Kingdom. Birth and baptism, servant

ministry, suffering and death, resurrection and ascension, and finally Pentecostal pouring out: each one in some way plays a part in the beginnings of Christ's rule—with the cross being the pivotal event. In the cross, Jesus establishes His credentials to be confirmed as the supreme ruler over every nation and even over Satan, the archenemy of God. Furthermore, in the cross Jesus satisfies the Father's requirement of justice for sin by dying on behalf of sinners. God's forgiveness is for all who believe and through this faith the Kingdom promises begin to be experienced.

Nowhere in the New Testament do Jesus or the apostles challenge the wholistic nature of what the Messiah has come to do. Indeed, Jesus clearly demonstrates a concern for the whole person and the whole of the context in which each one lives. The only qualification is in size; there is no reduction in the agenda of the Messiah. Jesus says that the Kingdom has commenced very small but it will grow, and as it does it will impact upon more and more of the whole of life. How far it will develop before He returns to complete the work is never specified. The parable of the Wheat and the Weeds indicates that the world of evil will continue to grow even as the Kingdom grows.

In his first coming Jesus commenced His Kingdom reign in the smallest and humblest of ways. When He returns He will come with such majesty and glory and power that not one person will have any doubt as to who He is. At this time the work will be completed. The whole earth, the whole of every nation and society, the whole of the people of God, will be transformed into God's wholistic perfection.

It is important that we not forget that one of the necessary things for the fulfillment of God's promises is the judgment. The final judgment will be both punishment and cleansing. God will remove all persons who have chosen to follow other gods—themselves, idols, Satan, whatever. God will remove everything which is evil to the point of being beyond transformation. God will remove all the spiritual forces of evil from Satan himself to the lowliest of demons. This exclusion from everything that belongs to

God will be the most terrible of punishments: total absence of anything good.

## Some Important New Testament Statements.

In Ephesians, Paul writes strongly of the authoritative and supreme rule of Jesus over all other powers (1:20–23). He also says that one of the blessings of the Kingdom, which we already have received, is the revelation from God as to His purpose in Christ. All things in heaven and earth will eventually be brought under the headship or rule of Christ. This rule has commenced; when the time comes that God has designated, Jesus headship will be totally complete. Not that it is a wholistic rule; it is over all things in heaven and earth.

In Philippians 2:9–11, Paul describes Jesus as exalted by God to the place of supreme power and authority. In accordance with the promise of Isaiah 45:22–24, all creatures in heaven, on earth and under the earth will bow down to Jesus in acknowledgment of His Lordship. This is the purpose that God is working out in Christ.

Colossians 1:15–20 is a fascinating passage. Having stated that literally all that exists has been created by God in Christ, Paul speaks of reconciliation through the cross. The description of "all things" in verse 16–17 is wholistic in every way. And it is this wholistic collection of "all things" that are included in the reconciling work of God through Jesus. God is pleased to be wholistic! God's peace is wholistic! God's peace is the harmony of "all things" reconciled to Himself such that His relationship with "all things" is perfect. And when "all things" are reconciled to Himself, then "all things" can experience harmony with all other things.

Romans 8:19–21 likewise reflects the wholistic nature of God's work of liberation.

The central focus in any Christian understanding of wholism is the sovereignty of Jesus Christ. He alone is Lord and Messiah. He alone rules supremely over the whole creation. His will is to be implemented is every sphere of life. His Lordship

over all things to bring the changes promised by God is the point at which we begin to understand the wholistic nature of our work as His servants.

## How Then Shall We Serve?

We are to be servants of Christ before anything else. His rule is the basis for determining our ministry. His wholistic Kingdom agenda is ours. We are called to follow Him in the mission of wholistic transformation of all things. It is His work and He works through us.

Biblical wholistic ministry/mission has four components:

- **Word**—Gospel proclamation to call on all persons and nations to submit to Christ the Lord; His grace flows in abundance to all who do.
- **Deed**—Action in compassion for others and in obedience to the Lordship of Christ to address whatever is unacceptable to Him in every sphere of life in accordance with His Kingdom of God agenda.
- **Sign**—Evidence in our lives, words , deeds and prayers that Jesus is the Lord who alone is powerful.
- **Intercession**—Expressing total reliance on Jesus without which the other three are largely ineffective.

Each one of us can only do a little. At times it may feel like it is too small to be of use! But Jesus has a very large workforce; thousands upon thousands of servants. Each one has a part to play. He is perfectly capable to weave all these contributions together to bring about the completion of His wholistic Kingdom.

សំណុំឱកឃ្មុំ ១/១ (កក្កដា ២០០០): ៣២-៤២

# ព័ន្ធកិច្ច និង បេសកកម្មគ្រប់ជ្រុងជ្រោយ

ដោយ លោក ប្រ៉ាម ឈឹម

*******

ព័ន្ធកិច្ចគ្រប់ជ្រុងជ្រោយ (គឺគិតបញ្ចូលទាំងបេសកកម្ម) គឺមានន័យថា ការធ្វើជាអ្នកបំរើដល់អ្នកដទៃ ដែលគិតគូរដល់សេចក្តីត្រូវការរបស់មនុស្សទាំងស្រុង ហើយនិងគិតគូរដល់ស្ថានភាពរស់នៅទាំងស្រុងរបស់មនុស្សនោះ ។ ចំណុចនិមួយៗខាងក្រោមនេះគឺពិតជាត្រូវសំរាប់មនុស្សគ្រប់រូប នៅក្នុងគ្រប់ប្រទេសនានា ។

- មនុស្សគ្រប់រូបព្រះបានបង្កើតមកក្នុងរូបអង្គរបស់ព្រះជាម្ចាស់ ប៉ុន្តែមនុស្សម្នាក់ៗបានក្លាយទៅជាមនុស្សអាត្មានិយម និង បះបោរទាស់នឹងព្រះ ដោយសារតែអំពើបាបនៅក្នុងចិត្ត ។ មនុស្សម្នាក់ៗជាមនុស្សមានបាប ដែលបានប្រព្រឹត្តទាស់ទទឹងនឹងព្រះជាម្ចាស់ ។
- មនុស្សម្នាក់ៗមានប្រព័ន្ធរស់នៅផ្នែករូបកាយ ផ្នែកបញ្ញា ផ្នែកទំនាក់ទំនង ផ្នែកសង្គម ផ្នែកវិញ្ញាណ ផ្នែកចិត្តសាស្ត្រ ផ្នែកអារម្មណ៍ ផ្នែកសីលធម៌ ផ្នែកឆន្ទៈ និង ផ្នែកទំនៀមទំលាប់រៀងៗខ្លួន ។ ផ្នែកនិមួយៗនៃប្រព័ន្ធនេះ មានឥទ្ធិពលយ៉ាងសំខាន់ចំពោះប្រព័ន្ធដទៃផ្សេងទៀត ។
- មនុស្សម្នាក់ៗរស់នៅក្នុងស្ថានភាពរបស់ទំនៀមទំលាប់ គ្រួសារ នយោបាយ ពួកខាងឯវិញ្ញាណ សង្គមជាតិ បរិយាកាស សិល្បៈ ការកែកំសាន្ត ច្បាប់ ហើយនិង ការអប់រំ ។
- មនុស្សម្នាក់ៗ ព្រះបង្កើតមកតម្រូវឲ្យមានទំនាក់ទំនងជាមួយព្រះជាម្ចាស់ ហើយនិង ម្នាក់ៗមានដំណើរការមិនប្រក្រតី នៅពេលដែលទំនាក់ទំនងជាមួយព្រះជាម្ចាស់ចុះខ្សោយ ឬ មិនមានទំនាក់ទំនងនេះទេ ។

• មនុស្សម្នាក់ៗត្រូវជាប់ទោសដល់ស្លាប់អស់កល្បជានិច្ច ដោយសារអំពើបាបរបស់ខ្លួនបើមិនមានព្រះគុណព្រះជួយគេទេនោះ តែគេអាចចូលរួមជាមួយនឹងព្រះយេស៊ូបានដោយសារជំនឿ ។ ព័ន្ធកិច្ចគ្រប់ជ្រុងជ្រោយទទួលស្គាល់នូវសារៈសំខាន់នៃការលើកមកនិយាយ ចំពោះគ្រប់ផ្នែកទាំងអស់នៃជីវិតរស់នៅ បើមនុស្សគ្រប់រូប និង ប្រជាជាតិ មានសុភមង្គលបាននោះ ត្រូវបង្កើនការជួយនោះឲ្យហួសពីភាពសើរៗ ។ ការយល់ដឹងរបស់យើងមិនមែនចាប់អារម្មណ៍ និង មិនចាប់អារម្មណ៍ ចំពោះតែសុខមាលភាពប៉ុណ្ណោះទេ កំណត់ឲ្យឃើញនូវអ្វីដែលព្រះជាម្ចាស់មានបន្ទូល ត្រឹមត្រូវល្អ នៅក្នុងព្រះគម្ពីរ ។

ទោះជាយ៉ាងណាក៏ដោយ មានហេតុផលផ្សេងៗ ដែលមនុស្សបានលើកឡើងមកនិយាយថា ហេតុអ្វីបានជាព័ន្ធកិច្ចគ្រប់ជ្រុងជ្រោយល្អត្រឹមត្រូវ ។ មានរបៀបផ្សេងៗគ្នាបីយ៉ាង ។ របៀបទីមួយគឺមិនទាក់ទងលើផ្នែកសីលធម៌ របៀបទីពីរល្អ ប៉ុន្តែមានដែនកំណត់ ហើយនិងទីបីល្អបំផុត ពីព្រោះការផ្ដោតសំខាន់ គឺព្រះគ្រីស្ទ ហើយនិងភាពធំឧត្ដមរបស់ព្រះអង្គ ជាជាងការផ្ដោតទៅលើសេចក្ដីត្រូវការរបស់មនុស្ស ។

របៀបទាំងបីនៃព័ន្ធកិច្ចនេះគឺ:

១) ព័ន្ធកិច្ចគ្រប់ជ្រុងជ្រោយគឺជាមធ្យោបាយមួយរហូតដល់ចុងបំផុត។ ព័ន្ធកិច្ចគ្រប់ជ្រុងជ្រោយគ្មានតម្លៃអ្វីឡើយ លើកលែងតែជាមធ្យោបាយមួយដែលងាយស្រួលចូលទៅដល់មនុស្ស ទើបពេលនោះយើងអាចផ្សាយដំណឹងល្អដល់ពួកគេបាន ។

គំនិតបែបនេះ គឺមើលឃើញអ្វីៗគ្រប់យ៉ាងឯទៀត គ្រាន់តែជាមធ្យោបាយមួយ ដែលធ្វើឲ្យមនុស្សព្រមស្ដាប់ដំណឹងល្អតែប៉ុណ្ណោះ ។ ចំពោះហេតុផលបែបនេះ គឺជាការបោកបញ្ឆោត ដើរខ្សែលើ មិនអាចទទួលយកបាន ផ្ទុយពីព្រះបន្ទូល ហើយនិង មិនបានលើកសរសើរដល់ព្រះជាម្ចាស់ ។

២) ព័ន្ធកិច្ចគ្រប់ជ្រុងជ្រោយ គឺជាការស្ដែងចេញនៃសេចក្ដីស្រឡាញ់ ហើយនិង ការប្រាថ្នាចង់បានយុត្តិធម៌ និង ភាពសម្បូណ៌សប្បាយនៅក្នុងគ្រប់ផ្នែកនៃជីវិតរស់នៅ ។ ព័ន្ធកិច្ចគ្រប់ជ្រុងជ្រោយ គឺត្រូវមានការលើកទឹកចិត្ត ដោយការមានបំណងថែទាំដល់មនុស្សម្នាទាំងឡាយ ។ ព័ន្ធកិច្ចនេះបានលើសពីសេចក្ដីត្រូវការរបស់មនុស្ស ហើយនិង ដំណើររឿងទាំងឡាយនៃជីវិតរស់នៅ ដើម្បីឲ្យ

សុខមាលភាពរបស់មនុស្សទាំងឡាយមានភាពប្រសើរឡើង និង មនុស្សទាំងអស់នឹងបានរួចពីបន្ទុកធ្ងន់ ដោយសារតែការធ្លាក់ស្រុតចុះផ្នែកជីវភាពរស់នៅរបស់មនុស្សម្នាក់ៗ ហើយនិងការស្រុតចុះរបស់សង្គម ។ ហេតុផលនេះល្អ ហើយនិង ស្របតាមព្រះគម្ពីរទៀត ប៉ុន្តែវារំលងចំណុចសំខាន់ ដែលផ្តោតទៅលើព្រះរាជបំណងរបស់ព្រះ ដែលបានកត់ទុកនៅក្នុងយុទ្ធសាស្ត្រទី ៣ នៅខាងក្រោមនេះ ។ គំរូនេះ គឺជួយជំរុញឲ្យធ្វើ "អំពើល្អ" ។

ការបង្ហាញបែបនេះ កាលនៅក្នុងសតវត្សរ៍ទី ១ បានសង្កត់ធ្ងន់ទៅលើតម្លៃនៃការរួមបរិច្ចាគជួយទៅដល់សហគមន៍តាមតំបន់ ។ ព័ន្ធកិច្ចនោះអាចជាការងារតូចតាច ដែលជួយដល់អ្នកជិតខាង ឬ ការងារធំដុំដូចជាការផ្តល់ជំនួយសង្គ្រោះជាបន្ទាន់ ឬ ក៏គម្រោងការអភិវឌ្ឍន៍ ដែលផ្តល់ប្រយោជន៍ដល់សហគមន៍ទាំងមូល ។

៣) ព័ន្ធកិច្ចគ្រប់ជ្រុងជ្រោយ គឺជាការព្រមចុះចូលចំពោះការសោយរាជ្យរបស់ព្រះគ្រីស្ទ ។ ព័ន្ធកិច្ចគ្រប់ជ្រុងជ្រោយគឺដោយទទួលស្គាល់ថាក្នុងនាមជាអ្នកបំរើរបស់ព្រះជាម្ចាស់ យើងត្រូវធ្វើអ្វីៗតាមបំណងព្រះហឫទ័យរបស់ព្រះអង្គ ដូចដែលព្រះអង្គបានធ្វើការរស់នៅក្នុងលោកិយនេះដែរ ។ ព្រះជាម្ចាស់ធ្វើការសម្រេចព្រះរាជបំណងរបស់ព្រះអង្គតាមរយៈនេះ ក្រិត្យច្បាប់របស់ព្រះរាជបុត្រារបស់ព្រះអង្គ ព្រះយេស៊ូគ្រីស្ទ ហើយនិង ព្រះរាជបំណងរបស់ព្រះអង្គជាប់ទាក់ទងទៅនឹងការបំផ្លាស់បំប្រែគ្រប់ជ្រុងជ្រោយទាំងអស់នូវជីវិតទាំងឡាយដែលព្រះអង្គបង្កើតមក (លើកលែងតែអ្វីៗខ្លះ ដែលព្រះអង្គត្រូវលុបបំបាត់តាមរយៈការជំនុំជំរះ) ។

ហេតុផលនេះគឺជាសន្ទុះចិត្តដ៏ខ្លាំងក្លា ពីព្រោះតាំងពីចាប់ផ្តើមរហូតចប់ គឺនៅក្នុងព្រះរាជបំណងព្រះហឫទ័យ របស់ព្រះជាម្ចាស់នៅក្នុងព្រះគ្រីស្ទ ។ ចំណុចទាំងឡាយដូចតទៅនេះ រៀបរាប់ពីការងារគ្រប់ជ្រុងជ្រោយ របស់ព្រះជាម្ចាស់ ។

### ព័ន្ធកិច្ចគ្រប់ជ្រុងជ្រោយដើមដំបូងបង្អស់

ព្រះជាម្ចាស់ តែងតែគិតពីភាពគ្រប់ជ្រុងជ្រោយ នៅក្នុងកិច្ចការងាររបស់ព្រះអង្គ ។ ស្នាព្រះហស្តរបស់ព្រះអង្គ ដែលបានបង្កើតមកទាំងអស់គឺ គិតបញ្ចូលទាំងគ្រឿងផ្សំនៃជីវិតរស់នៅ ដែលបានបញ្ជាក់ជូនខាងលើ លើកលែងតែអំពើ

បាប ហើយនិងផលវិបាករបស់វា ។ ព្រះអង្គបង្កើតរបស់សព្វសារពើគឺៈ ទាំងរបស់មើលឃើញ និង របស់មើលមិនឃើញ ទាំងមនុស្សទាំងសត្វ ទាំងរបស់មានរូបរាងទាំងរបស់ខាងវិញ្ញាណ ទាំងមនុស្សផ្ទាល់ខ្លួនម្នាក់ៗ ទាំងសង្គមដែលមនុស្សត្រូវរស់នៅ ទាំងផែនដី និង ទាំងផ្ទៃមេឃ ទាំងផ្លូវចិត្ត និង ទាំងបញ្ញា ទាំងរបស់ទន់ទាប និង ទាំងអ្នកត្រួតត្រា និង ទាំងអ្នកមានសិទ្ធិអំណាច ។ ព្រះអង្គបង្កើតទាំងប្រុសទាំងស្រី ទាំងលំហអាកាស ទាំងដែនសមុទ្រ រុក្ខជាតិ និង សត្វគ្រប់ប្រភេទ ខ្យល់ និង ទឹក និង ពពក ។ ស្នាព្រះហស្តព្រះអង្គដែលបានបង្កើតមក មានជីវិតរស់នៅ មានដង្ហើម មានការផ្លាស់ប្តូរកិច្ចការផ្នែកសិល្បៈ ។ កិច្ចការច្នៃប្រឌិតដ៏មានសោភ័ណភាពប្រណិតនេះ គឺស្រស់បំព្រងឥតខ្ចោះជារៀងរាល់ថ្ងៃ ហើយនិងទោះជាយ៉ាងណាក៏ដោយ ប្រណីតភាពនេះគឺមានការផ្លាស់ប្តូររាល់ថ្ងៃ តែមិនបាត់បង់នូវភាពល្អឥតខ្ចោះនោះឡើយ ។ ព្រះជាម្ចាស់បានទតឃើញថាគ្រប់ទាំងអស់ល្អប្រពៃហើយ (លោកុប្បត្តិ ១:៣១) ។

តាំងពីនោះមក អំពើរបស់មនុស្ស និង ការបំផ្លាញរបស់អារក្សមានច្រើនតាមដែលអាចធ្វើបាន ប៉ុន្តែទោះបីជាអារក្សបានធ្វើឲ្យខូច និង ទទួលបណ្តាសារបស់ព្រះជាម្ចាស់ នៅក្នុងសេចក្តីជំនុំជំរះ (លោកុប្បត្តិ ៣) ក៏ដោយរបស់សព្វសារពើ នៅតែរក្សាភាពល្អប្រពៃ ដែលព្រះជាម្ចាស់បានបង្កើតមកនោះបានច្រើន។ របស់សព្វសារពើ បង្ហាញពីសិរីល្អរបស់ព្រះជាម្ចាស់ ហើយនិងនិយាយប្រាប់យើងពីព្រះរាជលក្ខណៈសម្បត្តិ និង អំណាចចេស្តារបស់ព្រះអង្គ (ឧទាហរណ៍ ទំនុកតម្កើង ៨, ១៩, ១០៤, ១៤៨) ។

យើងត្រូវអបអរសាទរដល់របស់សព្វសារពើ ដែលបន្តនាំឲ្យព្រះជាម្ចាស់មានសេចក្តីរីករាយ ហើយយើងត្រូវដឹងទៀតថា តើព្រះអង្គមានព្រះហឫទ័យព្រួយប៉ុណ្ណាទៅ នៅពេលដែលស្នាព្រះហស្តរបស់ព្រះអង្គទទួលរងនូវការប្រព្រឹត្តដោយមិនយកចិត្តទុកដាក់ ។ ព្រះជាម្ចាស់ផ្តល់នូវការទទួលខុសត្រូវផ្នែកចាត់ចែងមើលថែរបស់សព្វសារពើ និង យើងមិនបានធ្វើការនេះសោះឡើយ ។ នៅពេលដែលយើងមិនបានយកចិត្តទុកដាក់ចំពោះការទទួលខុសត្រូវរបស់យើង ដើម្បីចាត់ចែងឲ្យបានល្អនូវរបស់សព្វសារពើទាំងអស់ ដែលព្រះអង្គបានបង្កើតមក យើងបានប្រកាន់យកនូវឥរិយាបថ ដែលព្រះជាម្ចាស់ព្រះអង្គផ្ទាល់មិនទទួលយកបាន ។

**អំពើបាប សង្គម និង របស់សព្វសារពើដែលព្រះបានបង្កើត ។**

នៅក្នុងលោកុប្បត្តិ ៣-១១ យើងបានអានអំពីផលវិបាកទាំងឡាយ នៃអំពើបាបរបស់មនុស្ស ។ ជីវិតទាំងឡាយបាន និង កំពុងជាប់ឥទ្ធិពលរបស់អំពើបាប សូម្បីតែផែនដីផ្ទាល់នេះ ក៏ទទួលរងឥទ្ធិពលរបស់អំពើបាបដែរ ។ សង្គមមនុស្សរីកចំរើនឡើងដោយមានភាពអំនួត អំពើអាក្រក់ និង អំពើពុករលួយហើយនិង ពេលនោះ សេចក្តីជំនុំជំរះរបស់ព្រះជាម្ចាស់ក៏ជោរជន់ឡើង ដោយព្រះអង្គលាងផែនដីដោយទឹកជំនន់ និងកំចាត់កំចាយមនុស្សទៅគ្រប់ទីកន្លែង ទៅតាមភាសាផ្សេងៗ ។ សូម្បីតែបងប្អូនក៏បះបោរប្រឆាំងគ្នា ដោយកាប់សម្លាប់គ្នា ។

ទំនាក់ទំនងរវាងអំពើបាប ហើយនិងរបស់របរសព្វសារពើដែលព្រះបានបង្ហាញយ៉ាងច្បាស់ នៅក្នុងការដែលព្រះដាក់បណ្តាសាដល់ផែនដី ហើយនិងការដែលផ្លាស់ប្តូរក្នុងទំនាក់ទំនងនានា ហើយនិងកិច្ចការធំៗ នៅពេលដែលសេចក្តីជំនុំជំរះរបស់ព្រះជាម្ចាស់បានមកដល់ ក្នុងលោកុប្បត្តិ ជំពូក ៣:១៧-១៩ ។ ដូចដែលលោក ប៉ូល ពណ៌នាពីការរំដោះរបស់សព្វសារពើ ពីបណ្តាសា ហើយនិងភាពពុករលួយរបស់អំពើបាប គឺដោយទាក់ទងផ្ទាល់ជាមួយនិង ការរំដោះឲ្យរួចពីអំពើបាប ដែលព្រះជាម្ចាស់បាននាំមកឲ្យបុត្រាបុត្រីរបស់ព្រះអង្គ ។ ព្រះជាម្ចាស់គឺយកព្រះហឫទ័យទុកដាក់គ្រប់ជ្រុងជ្រោយទាំងអស់ ។

លើសពីនេះទៅទៀត យើងធ្លាប់បានអានជាញយៗមកហើយនៅក្នុងក្រិត្យវិន័យរបស់លោកម៉ូសេ នៅក្នុងទំនុកតម្កើង ហើយនិងនៅក្នុងទំនាយរបស់ពួកហោរា ដែលស្តីពីព្រះហឫទ័យរំជួលរបស់ព្រះជាម្ចាស់ចំពោះមនុស្ស ដែលរងគ្រោះដោយសារអំពើបាបគឺ: ភាពក្រីក្រ ក្មេងកំព្រា ស្ត្រីមេម៉ាយ ជនដែលត្រូវគេសង្កត់សង្កិន ទណ្ឌិត ជនភៀសខ្លួន ។ អំពើបាប ទាក់ទងនឹងការថ្វាយបង្គំរូបព្រះ ភាពអយុត្តិធម៌ អំពើលោភលន់ ហើយនិងភាពអសីលធម៌ ដែលជាលទ្ធផលនាំឲ្យមនុស្សផ្ទាល់ខ្លួនម្នាក់ៗរងទុក្ខលំបាក និង ប្រជាជាតិទាំងឡាយធ្លាក់ក្នុងអំពើព្រៃផ្សៃ ហើយនិង អំពើហឹង្សា ។ ផលវិបាកទាំងឡាយរបស់មនុស្សម្នាក់ៗ និង អំពើបាបនៃលោកិយទាំងមូល គឺជាការខ្វល់ខ្វាយរបស់ព្រះអង្គ ។ គ្រប់ផ្នែកទាំងអស់របស់មនុស្សគ្រប់រូប គ្រប់ផ្នែកទាំងអស់របស់សង្គម និង គ្រប់ផ្នែកទាំងអស់របស់សព្វសារពើ គឺខ្វះមិនដល់សិរីល្អរបស់ព្រះជាម្ចាស់ ។ ព្រះហឫទ័យរបស់ព្រះជាម្ចាស់ និង ព្រះតំរិះរបស់ព្រះអង្គបានបង្ហាញឲ្យយើងឃើញច្បាស់ថា ព្រះ

អង្គមានព្រះហឫទ័យទុក្ខព្រួយ ដោយព្រោះអំពើបាប និង ផលវិបាករបស់អំពើបាបនោះ ។ សេចក្តីរំដួល និង ការក្តួលអាណិតរបស់ព្រះជាម្ចាស់ គឺគ្រប់ជ្រុងជ្រោយឥតខ្ចោះ ដូចដែលសេចក្តីសន្យារបស់ព្រះអង្គទៅនឹងអ្វី ដែលព្រះអង្គនឹងធ្វើ ការជួយសង្គ្រោះដល់លោកិយ ដែលខូចបាក់បែកនេះ ។

### សេចក្តីសន្យារបស់ព្រះជាម្ចាស់

សូម្បីតែនៅថ្ងៃ ដែលបណ្តាសានៃការជំនុំជំរះរបស់ព្រះជាម្ចាស់បានប្រកាសជាមុនដំបូងក៏ដោយ ព្រះជាម្ចាស់បានបង្ហាញថា សេចក្តីសន្យារបស់ព្រះជាម្ចាស់គឺ ត្រូវផ្តួលរំលំដល់អាណាចក្ររបស់អារក្ស ។ កូនរបស់ស្ត្រីនឹងជាន់ក្បាលសាតាំង (លោកុប្បត្តិ ៣:១៥) ។ ចំពោះ អ័ប្រាហាំ ព្រះជាម្ចាស់សន្យានូវព្រះពរជូនដល់មនុស្សទូទាំងផែនដី ។ ក្រិត្យវិន័យរបស់ លោក ម៉ូសេ សញ្ជឹងគិតដល់សង្គមដែលកោតខ្លាចព្រះ បរិសុទ្ធ មានសេចក្តីអាណិតអាសូរ និង យុត្តិធម៌ ដោយគិតដល់អ្នកទន់ខ្សោយ និង អ្នកដែលងាយនឹងរងគ្រោះជាពិសេស ។ គ្រប់យ៉ាងទាំងអស់នៅក្នុងសង្គមបែបនោះ គឺមានទំនាក់ទំនងស៊ីចង្វាក់គ្នាទាំងអស់ (គឺគិតទាំងផែនដី) មកទល់ពេលនេះគ្រប់យ៉ាងទាំងអស់ គឺស៊ីចង្វាក់គ្នាក្នុងទំនាក់ទំនងជាមួយព្រះជាម្ចាស់ ។ ក្រិត្យវិន័យនេះ ផ្តល់ឲ្យយើងនូវចំណាប់អារម្មណ៍យ៉ាងច្រើនចំពោះប្រភេទនៃសង្គម ដែលនឹងនាំឲ្យមានព្រះពរធ្លាក់មកលើប្រជាជាតិទាំងអស់ ដែលព្រះជាម្ចាស់បានសន្យាដល់អ័ប្រាហាំ ។

ចំណុចសំខាន់ចំពោះ សេចក្តីសន្យារបស់ព្រះទាំងអស់នេះ គឺជាសេចក្តីសន្យានៃស្តេចគង្វាល ដែលជាពូជពង្សហ្លួងដាវីឌ ហើយនិង ដែលជាព្រះរាជបុត្រារបស់ព្រះជាម្ចាស់ (ទំនុកតម្កើង ២) ហើយនិង ជាកូនមនុស្ស (ដានីយ៉ែល ៧:៩-១៤) ។ ព្រះអង្គជាព្រះមេស្ស៊ី ហើយនិង តាមរយៈនៃការគ្រប់គ្រងរបស់ព្រះអង្គលើប្រជាជាតិទាំងអស់ ដែលថាព្រះជាម្ចាស់នឹងសម្រេចគ្រប់ទាំងសេចក្តីសន្យា ។ ពួកព្យាការី បាននិយាយម្តងហើយម្តងទៀត ពីព្រះមេស្ស៊ី នេះ ។ (ឧទាហរណ៍ អេសាយ ៩:៦-៧, ១១:១-៥, ៣២:១-៥, ៤២:១-៧, ៥២-៥៣, ៦១:១-៩, យេរេមា ២៣:៥-៦, ៣៣:១៥-១៦, អេសេគាល ៣៤:២០-៣១, ៣៧:២៤-២៨, អេម៉ូស ៩:១១-១៥) ។ ព្រះអង្គនឹងជាអ្នកបំរើរបស់ព្រះជាម្ចាស់ ដែលនឹងត្រូវធ្វើជាយញ្ញបូជា ចំពោះអំពើបាប (អេសាយ ៥៣) ។

អេសេគាល និង យេរេមា សន្យាថាព្រះជាម្ចាស់ នឹងសំអាត និង បន្ទន់ចិត្តរបស់មនុស្ស ឲ្យបានបរិសុទ្ធ ដើម្បីឲ្យមនុស្សបែរទៅរកព្រះជាម្ចាស់ ជាជាងប្រឆាំងនឹងព្រះអង្គ ។ អេសាយ យ៉ូអែល និង អេសេគាល បានប្រកាសថា ព្រះវិញ្ញាណបរិសុទ្ធរបស់ព្រះជាម្ចាស់ នឹងចាក់មកលើរាស្ត្ររបស់ព្រះអង្គ ដើម្បី នាំមកនូវការផ្លាស់ប្រែ ការប្រោសលោះ កាញែកជាបរិសុទ្ធ ការកែប្រែជាថ្មី ។ អេសាយបានសង្កត់ធ្ងន់លើភាពយុត្តិធម៌ មេត្រីភាព និង សេចក្តីសុចរិត សំរាប់ ប្រជាជាតិទាំងឡាយនៅលើផែនដី ។ សេចក្តីសន្យាខ្លះៗ នៃការអត់ទោសបាប របស់ព្រះជាម្ចាស់ ។ ចំពោះអស់អ្នកដែលរងគ្រោះ ដោយព្រោះអំពើបាបភាគ ច្រើននឹងប្រទះឃើញនូវសេរីភាពរបស់ព្រះជាម្ចាស់ ដែលបានរួចពីភាពក្រីក្រ ហើយនិងរួចពីការដែលគេសង្កត់សង្កិន ។ ប្រជាជាតិនានានឹងឈប់ធ្វើសង្គ្រាម ទាស់ទែងគ្នា ។ សូម្បីតែនៅក្នុងចំណោមសត្វ ក៏គ្មានការទាស់ទែងគ្នាដែរ ។

និយាយឲ្យខ្លីទៅ សេចក្តីសន្យារបស់ព្រះជាម្ចាស់ គឺត្រូវថ្លែងបញ្ជាក់ពី ជីវិតទាំងមូល (គ្រប់ជ្រុងជ្រោយ) ហើយនិងនាំមកនូវការផ្លាស់ប្រែដល់របស់សព្វ សារពើទាំងអស់ ទោះទាំងនៅលើស្ថានសួគ៌ និង លើផែនដី គឺត្រូវស្របនឹង បំណងព្រះហឫទ័យទាំងស្រុងរបស់ព្រះអង្គ ។ សេចក្តីសន្យារបស់អាណាចក្រ នោះគឺទូទៅ គ្រប់ជ្រុងជ្រោយ និង ពេញលេញនៅគ្រប់ផ្នែកទាំងអស់ ។ សេចក្តី សន្យាផ្តល់មត៌កដល់អស់អ្នកណា ដែលមានជំនឿដូចជាអ័ប្រាហាំ គឺផែនដីទាំង មូលនឹងបានផ្លាស់ប្រែស្របតាមព្រះរាជគ្រប់គ្រងរបស់អាណាចក្រព្រះនៅក្នុងព្រះ គ្រីស្ទ ។

**ការយាងមករបស់ព្រះមេស្ស៊ី**

នៅពេលដែលព្រះយេស៊ូចាប់ផ្តើម ព្រះរាជព័ន្ធកិច្ចរបស់ព្រះអង្គ ព្រះ ទ្រង់បានប្រកាសប្រាប់ពីដើមដំបូងនៃការគ្រប់គ្រងរបស់ព្រះមេស្ស៊ី ដែលបាន សម្រេចតាមសេចក្តីសន្យារបស់ព្រះជាម្ចាស់ ។ មិនថាឡើយការចាប់ផ្តើមនោះវា តូចប៉ុណ្ណានោះឡើយ កិច្ចការងាររបស់អាណាចក្ររបស់ព្រះជាម្ចាស់ បានចាប់ ផ្តើមឡើង ។ ព្រះយេស៊ូ ហើយនិងពួកសាវ័ក គេបានរាយការណ៍មកថា មាន បន្ទូល និង និយាយពីអាណាចក្រព្រះជានិច្ចរហូត គឺជាចំណុចសំខាន់នៃដំណឹង ល្អ ដែលពួកគេបានផ្សាយចេញទៅនោះ ។ តាមរយៈនៃឱកាសសំខាន់ៗ នៃព្រះ ជន្មរបស់ព្រះអង្គ ព្រះយេស៊ូបើកសម្តែងពីសេចក្តីសន្យារបស់អាណាចក្ររបស់

ព្រះជាម្ចាស់ ។ កំណើត និង ពិធីជ្រមុជទឹក ព័ន្ធកិច្ចជាអ្នកបំរើ ការរងឈឺចាប់ និង ការសុគត ការមានព្រះជន្មរស់ឡើងវិញ ហើយនិងការឡើងទៅស្ថានសួគ៌ និង ជាចុងក្រោយ ការចាក់ព្រះវិញ្ញាណនៅបញ្ចទសទិវា (ថ្ងៃទី ៥០) គឺថា: ម្នាក់ៗមានចំណែកក្នុងការចាប់ផ្តើមនៃការគ្រប់គ្រងរបស់ព្រះគ្រីស្ទ ដោយយកឈើឆ្កាងជាព្រឹត្តិការណ៍សំខាន់ ។ នៅលើឈើឆ្កាង ព្រះយេស៊ូបានបើកឲ្យមានភាពជាទីទុកចិត្តរបស់ព្រះអង្គ ដែលត្រូវបានគេបញ្ជាក់ថាជាអ្នកគ្រប់គ្រងដ៏ធំឧត្តម លើគ្រប់ប្រជាជាតិ ហើយនិងគ្រប់គ្រងសាតាំង ដែលជាមហាបច្ចាមិត្ររបស់ព្រះជាម្ចាស់។ លើសពីនេះទៅទៀតនោះ នៅលើឈើឆ្កាងព្រះយេស៊ូបានធ្វើឲ្យសម្រេចតាមតម្រូវការដ៏យុត្តិធម៌ របស់ព្រះបិតាចំពោះអំពើបាប ដោយការសុគតជំនួសមនុស្សមានបាបទាំងឡាយ ។ ការអត់ទោសបាបរបស់ព្រះជាម្ចាស់ គឺសំរាប់អស់អ្នកដែលជឿ និង តាមរយៈជំនឿនេះ សេចក្តីសន្យានៃអាណាចក្រស្ថានសួគ៌ អ្នកទាំងឡាយនោះនឹងចាប់ផ្តើមទទួលនូវបទពិសោធន៍ក្នុងជីវិតរបស់គេ ។

គ្មានកន្លែងណាមួយ នៅក្នុងព្រះគម្ពីរសញ្ញាថ្មី ដែលព្រះយេស៊ូ ឬ ពួកសាវ័ក មិនបានលើកមកនិយាយពីលក្ខណៈគ្រប់ជ្រុងជ្រោយរបស់ព្រះមេស៊ី ដែលត្រូវយាងមកធ្វើការនេះ ។ តាមពិតព្រះយេស៊ូ បានបង្ហាញយ៉ាងច្បាស់ពីការដែលព្រះអង្គយកព្រះហឫទ័យទុកដាក់ ចំពោះសេចក្តីត្រូវការទាំងអស់ របស់មនុស្ស ហើយនិង អ្វីៗគ្រប់យ៉ាង ដែលមនុស្សម្នាក់ៗត្រូវការ ដើម្បីរស់នៅ ។ គុណសម្បត្តិតែមួយគត់ គឺថាមានទំហំធំធេង មានន័យថា : គ្មានការបន្ថយចុះនៃកិច្ចការងាររបស់ព្រះមេស៊ីឡើយ ។ ព្រះយេស៊ូមានបន្ទូលថា នគរព្រះចាប់ផ្តើមឡើងតូចបំផុត ប៉ុន្តែនគរនោះនឹងរីកចំរើនធំឡើងៗ ហើយនិង មានឥទ្ធិពលលើជីវិតកាន់តែច្រើនឡើងៗ ។ តើការរីកចំរើនឡើង ដល់កំរិតណា មុនពេលព្រះយេស៊ូយាងត្រឡប់មកវិញ ដើម្បីបញ្ចប់ការងារនោះ មិនបានថែងប្រាប់ច្បាស់លាស់ឡើយ ។ រឿងប្រៀបប្រដូច ពីស្រូវសាឡី និង ស្រងែ បានបង្ហាញថា អំពើអាក្រក់របស់លោកីយ៍នៅតែបន្តរីកដុះដាល ទោះបីជានគរព្រះកំពុងរីកចំរើនលូតលាស់ក៏ដោយចុះ ។

នៅក្នុងដំណើរយាងមកផែនដីជាលើកទី ១ របស់ព្រះអង្គ ព្រះយេស៊ូបានតាំងរាជ្យទ្រង់ឡើង តាមរបៀបមួយតូច និង បន្ទាបខ្លួនជាទីបំផុត ។ នៅពេលដែលព្រះអង្គយាងត្រឡប់មកវិញ ព្រះអង្គនឹងយាងមកដោយព្រះតេជៈ សិរីរុង

រឿង និង ព្រះចេស្តា ដែលគ្មានមនុស្សណាម្នាក់ឆ្ងល់ថា តើព្រះអង្គជាអង្គណានោះឡើយ ។ នៅពេលនោះ ជាពេលវេលានឹងបានសម្រេចគ្រប់យ៉ាងទាំងអស់ ។ ផែនដីទាំងមូល ប្រជាជាតិនានា និង សង្គមទាំងមូល ព្រមទាំងប្រជារាស្ត្ររបស់ព្រះជាម្ចាស់ទាំងមូល នឹងបានផ្លាស់ប្រែ ទៅជាមានភាពល្អឥតខ្ចោះ ដ៏គ្រប់ជ្រុងជ្រោយរបស់ព្រះជាម្ចាស់ ។

វាជាការសំខាន់ណាស់ ដែលថា យើងមិនភ្លេចនូវរឿងដ៏សំខាន់ចាំបាច់មួយនៃសេចក្តីសន្យារបស់ព្រះជាម្ចាស់ គឺជាការជំនុំជំរះ ។ សេចក្តីជំនុំជំរះ ជាចុងក្រោយនោះ នឹងមានទាំងពីរ ទាំងការដាក់ទណ្ឌកម្ម និង ការសំអាតឲ្យបានស្អាត ។ ព្រះជាម្ចាស់នឹងញែក លុបបំបាត់មនុស្សទាំងឡាយណា ដែលដើរតាមព្រះដទៃ ពួកទុកចិត្តលើខ្លួនឯង ពួកថ្វាយបង្គំរូបព្រះ ពួកសាតាំង និង ពួកដទៃទៀត ដែលស្រដៀងគ្នានេះ ។ ព្រះជាម្ចាស់នឹងលុបបំបាត់ នូវរាល់អំពើអាក្រក់ទាំងឡាយរហូតដល់ចំណុចដែលហួសពីការផ្លាស់ប្រែ ។ ព្រះជាម្ចាស់នឹងលុបបំបាត់នូវពួកវិញ្ញាណអាក្រក់ ដែលមកពីសាតាំងផ្ទាល់ និង បរិវាររបស់វា ។ ការនេះមិនបានបូកបញ្ចូលរបស់គ្រប់យ៉ាង ដែលជារបស់ព្រះជាម្ចាស់ ដែលនឹងត្រូវនូវការដាក់ទណ្ឌកម្មដ៏ធ្ងន់ធ្ងរបំផុតនោះគឺ អស់អ្នកណាដែលមិនបានធ្វើការល្អសោះ ។

**សេចក្តីថ្លែងការណ៍សំខាន់ខ្លះៗនៅក្នុងគម្ពីរសញ្ញាថ្មី**

នៅក្នុង អេភេសូ លោកប៉ូលសរសេរសង្កត់ធ្ងន់លើ សិទ្ធិអំណាច និង ការគ្រប់គ្រងដ៏ធំឧត្តម របស់ព្រះយេស៊ូលើគ្រប់អំណាចទាំងអស់ដទៃទៀត (១:២០-២៣) ។ គាត់បាននិយាយផងដែរថាព្រះពរនៃស្ថានសួគ៌ ដែលយើងរាល់គ្នាបានទទួលហើយនោះគឺជាការបើកសម្តែង ពីព្រះជាម្ចាស់ ដូចបានបង្ហាញពីព្រះរាជបំណងរបស់ព្រះអង្គនៅក្នុងព្រះគ្រីស្ទ ។ គ្រប់របស់ទាំងអស់ ទាំងនៅលើស្ថានសួគ៌ និង ផែនដី ត្រូវស្ថិតនៅក្រោមការដឹកនាំ និង ការគ្រប់គ្រងរបស់ព្រះគ្រីស្ទ ។ ការគ្រប់គ្រងនេះ ចាប់ផ្តើមឡើងនៅពេល ដែលដល់ពេលវេលារបស់ព្រះមកដល់ គឺថាព្រះគ្រីស្ទគ្រប់គ្រងលើទាំងអស់ ។ មិនគ្រាន់តែជាការគ្រប់គ្រងគ្រប់ជ្រុងជ្រោយប៉ុណ្ណោះទេ គឺជាការគ្រប់គ្រងលើរបស់គ្រប់យ៉ាងទាំងអស់ ទាំងនៅលើស្ថានសួគ៌ និង ផែនដីផង ។

នៅក្នុង ភីលីព ២:៩-១១ លោកប៉ូលពណ៌នា ពីព្រះយេស៊ូថា បានលើកតម្កើងឡើងដោយព្រះជាម្ចាស់ ឲ្យមានអំណាចចេស្តា និង សិទ្ធិអំណាចដ៏ធំឧត្តម។

ស្របតាមសេចក្ដីសន្យានៅក្នុង អេសាយ ៤៥:២២-២៤ គ្រប់ទាំងអស់ ដែលនៅស្ថានសួគ៌ លើផែនដី ហើយនិង ក្រោមផែនដី នឹងត្រូវលុតជង្គង់ចុះ ចំពោះព្រះយេស៊ូ ដោយទទួលស្គាល់ពីភាពជាព្រះរបស់ព្រះអង្គ ។ នេះជាគោលបំណងរបស់ព្រះជាម្ចាស់ ដែលស្ដែងចេញឲ្យឃើញ នៅក្នុងព្រះគ្រីស្ទ ។

កូលុស ១:១៥-២០ គឺជាអត្ថបទគួរឲ្យចាប់អារម្មណ៍យ៉ាងខ្លាំង បទគម្ពីរនេះ បានចែងថា គ្រប់របស់ទាំងអស់កើតមកដោយសារព្រះជាម្ចាស់ លោកប៉ូលនិយាយពីការបានជានាជាមួយនឹងព្រះឡើងវិញ ដោយសារឈើឆ្កាង ។ ការពិពណ៌នានៃពាក្យ "គ្រប់របស់ទាំងអស់" នៅក្នុងខ ១៦-១៧ គឺមានន័យថាគ្រប់ជ្រុងជ្រោយទាំងអស់ ក្នុងគ្រប់ផ្នែក ។ ការប្រមូលផ្ដុំនៃភាពគ្រប់ជ្រុងជ្រោយនៃ "របស់គ្រប់យ៉ាង"ដែលក្នុងនោះគិតបញ្ចូលទាំងការជានារបស់ព្រះ តាមរយៈព្រះយេស៊ូ។ ព្រះជាម្ចាស់ គឺគាប់ព្រះហឫទ័យនៃការងារគ្រប់ជ្រុងជ្រោយ ! សេចក្ដីសុខសាន្តរបស់ព្រះជាម្ចាស់ គឺគ្រប់ជ្រុងជ្រោយ ! សេចក្ដីសុខសាន្តរបស់ព្រះជាម្ចាស់ គឺជាការស៊ីចង្វាក់គ្នា និង "របស់សព្វសារពើ" ដែលបានជានានឹងព្រះអង្គផ្ទាល់ ការជានាបែបនោះគឺថា ទំនាក់ទំនងរបស់ព្រះអង្គជាមួយនឹងរបស់គ្រប់យ៉ាងទាំងអស់" គឺបានល្អឥតខ្ចោះ ។ នៅពេលដែល "របស់គ្រប់យ៉ាង" បានផ្សះផ្សាជាមួយព្រះអង្គផ្ទាល់ ដូច្នេះ "របស់គ្រប់យ៉ាង" អាចទទួលនូវបាននូវភាពចុះសំរុងនឹងគ្នាជាមួយនឹងរបស់ផ្សេងៗទៀត ។

រ៉ូម ៨:១៩-២១ ឆ្លុះបញ្ចាំងឲ្យឃើញពីលក្ខណៈ គ្រប់ជ្រុងជ្រោយ ដូចគ្នានេះដែរ ពីការងារនៃការដោះឲ្យរួច មានសេរីភាព របស់ព្រះជាម្ចាស់ ។

ចំណុចសំខាន់ក្នុងការយល់ដឹងពីភាពគ្រប់ជ្រុងជ្រោយ របស់គ្រីស្ទបរិស័ទខ្លះ គឺជាអធិបតេយ្យភាពរបស់ព្រះយេស៊ូគ្រីស្ទ ។ ព្រះអង្គតែមួយគត់ ដែលជាព្រះអម្ចាស់ និង ព្រះមេស្ស៊ី ។ មានតែព្រះអង្គមួយ តែប៉ុណ្ណោះ ដែលគ្រប់គ្រងលើរបស់ទាំងអស់ដោយប្រកបដោយភាពធំឧត្តម ។ ព្រះរាជបំណងព្រះហឫទ័យរបស់ព្រះអង្គ ត្រូវយកមកអនុវត្តក្នុងគ្រប់ស្ថានភាពនៃជីវិតរស់នៅ ។ ភាពជាព្រះរបស់ព្រះអង្គ ដែលបានគ្រប់គ្រងលើរបស់សព្វសារពើ នាំមកនូវការផ្លាស់ប្រែដែលជាសេចក្ដីសន្យារបស់ព្រះជាម្ចាស់ គឺត្រង់ចំណុច ដែលថាយើងនឹងចាប់ផ្ដើមយល់ពីលក្ខណៈគ្រប់ជ្រុងជ្រោយនៃការងាររបស់យើង ក្នុងនាមយើងជាអ្នកបំរើព្រះអង្គ ។

**តើអ្វីចីទំយើងនឹងបំរើដោយរបៀបណា** ?

យើងត្រូវតែធ្វើជាអ្នកបំរើរបស់ព្រះគ្រីស្ទ មុនពេលយើងធ្វើការ អ្វីៗទាំងអស់ឯទៀត ។ ការគ្រប់គ្រងរបស់ព្រះអង្គ គឺជាមូលដ្ឋានសំខាន់ សំរាប់ការកំណត់ឲ្យដឹងពីការងាររបស់យើង ។ របៀបវារៈនៃអាណាចក្រគ្រប់ជ្រុងជ្រោយរបស់ព្រះអង្គគឺជារបស់យើង ។ ព្រះអង្គបានត្រាស់ហៅយើងមកឲ្យដើរតាមព្រះអង្គនៅក្នុងបេសកកម្ម នៃការបំផ្លាស់បំប្រែគ្រប់ជុងជ្រោយ នៃរបស់គ្រប់យ៉ាងទាំងអស់ ។ នេះជាការងាររបស់ព្រះអង្គ ដែលព្រះអង្គធ្វើការតាមរយៈយើង ។

ព័ន្ធកិច្ច/បេសកកម្មគ្រប់ជ្រុងជ្រោយនៅក្នុងព្រះគម្ពីរ មានបួន ផ្នែកគឺ:

- ព្រះបន្ទូល-ការប្រកាសដំណឹងល្អ ប្រាប់ដល់មនុស្សទាំងឡាយ និង ប្រជាជាតិនានា ដើម្បីឲ្យចុះចូលនឹងព្រះគ្រីស្ទជាអម្ចាស់ ព្រះគុណរបស់ព្រះអង្គហូរមកដ៏ពេញបរិបូណ៌ ដល់អស់អ្នកទាំងឡាយណា ដែលបានធ្វើការផ្សាយដំណឹងល្អនេះ ។
- ការប្រព្រឹត្ត-គឺជាសកម្មភាព ដោយមានសេចក្តីក្តួលអាណិត ចំពោះមនុស្សដទៃ ហើយនិង បង្ហាញពីការស្តាប់បង្គាប់ចំពោះភាពជាព្រះរបស់ព្រះគ្រីស្ទ ដោយលើកយកអ្វីៗ ដែលព្រះអង្គមិនអាចទទួលយកបាន មកថ្វាយដល់ព្រះអង្គ នៅក្នុងផ្នែកទាំងអស់នៃជីវិតរស់នៅ ឲ្យស្របជាមួយនឹងផែនការនៃរបៀបវារៈ របស់ព្រះជាម្ចាស់ នៃអាណាចក្ររបស់ព្រះអង្គ ។
- ទីសំគាល់-គឺជាភ័ស្តុតាងនៅក្នុងជីវិត ពាក្យសំដី សកម្មភាព និង សេចក្តីអធិស្ឋានរបស់យើង ដែលប្រកាសថា ព្រះយេស៊ូ ជាព្រះម្ចាស់តែមួយអង្គគត់ដែលមានអំណាចចេស្តាឧត្តមនោះ ។
- ការទូលអង្វរ-ដែលសម្តែងពីការទុកចិត្តទាំងស្រុង លើព្រះយេស៊ូ ដោយគ្មានចាត់ទុកផ្នែកទាំង បី ផ្សេងទៀតថា អត់ប្រសិទ្ធិភាពនោះឡើយ ។

យើងម្នាក់ៗអាចធ្វើបាន តែបន្តិចបន្តួចប៉ុណ្ណោះ ។ ជួនកាល វាហាក់ដូចជាតូចពេក ដែលយើងត្រូវយកមកប្រើ ! ប៉ុន្តែ ព្រះយេស៊ូ មានកងកម្លាំងការងារយ៉ាងច្រើនសំបើម គឺមានរាប់ពាន់នាក់នៃអ្នកបំរើរបស់ព្រះអង្គ ។ ម្នាក់ៗមានចំណែករៀងៗខ្លួនក្នុងការធ្វើការងារនោះ ។ ព្រះអង្គមានសមត្ថភាពដ៏ល្អឥតខ្ចោះក្នុងការវេញផ្តុំងជាមួយគ្នា ដើម្បីនាំមកនូវ ការសម្រេចបាននៃអាណាចក្រគ្រប់ជ្រុងជ្រោយរបស់ព្រះអង្គ ។

HONEYCOMB 1/1 (July 2000): 43–46

# Translating The Bible Into Khmer

*Arun SOK NHEP*

Almost two years ago a new translation of the Khmer Bible—the Khmer Common Language Version (or Today's Khmer Version)—was launched in a dedication service in Phnom Penh which gathered Christians from different denominations and confessions. A week later, one copy of the new Bible was presented to the King and the Queen of Cambodia. This celebration marked the successful completion of a translation project which began in 1985. But the new translation also marks the continuation of the long efforts of making available God's World to the Khmer people.

## The Pioneers

The very first effort was undertaken by a French priest, Marie-Joseph Guesdon, at the end of the 19th century. Guesdon translated passages from the gospels, epistles, and Psalms for the Catholic liturgy. In 1899, the Gospel of Luke was published, the result of a collaboration between a French government official and the King's interpreter. At almost the same time an agent of the American Bible Society residing in Bangkok asked a Cambodian Buddhist monk to translate Luke and Acts from Thai into Khmer. This translation was published in 1900. But it was not until 1923 that a systematic translation of the whole Bible was started. An American missionary with the Christian and Missionary Alliance, the Rev. Arthur L. Hammond, was tasked with this work. This translation, based on the American Standard Version, took 30

years, and the first ever Bible in the Khmer language was finally published in 1954.

At the beginning of 1970s, as the Cambodian churches experienced a rapid growth, Khmer Christians felt the need for a more modern translation. To meet this need, the United Bible Societies launched an interconfessional translation project in 1973, with four evangelical translators and a Roman Catholic priest. By 1975, the team had completed a first draft of the New Testament. Then the country was plunged into turmoil under the Khmer Rouge regime. The four Cambodian translators perished, and all the New Testament manuscripts were lost except the first four chapters of Matthew.

**The Khmer Language Translation**

A new interconfessional committee appointed by United Bible Societies began the new translation in 1985. The New Testament was published in 1993, and the whole Bible was completed in 1997 and published in 1998.

Although there is a similarity in name between the Today's Khmer Version (TKV) and the Today's English Version (or Good News Bible), the TKV is not a translation of the latter. Rather, the TKV used as its basic texts the Greek *Novum Testamentum Græce* (Nestle-Aland 26/UBS 4) and the Hebrew *Biblia Hebraica Stuttgartensia*. The Old Testament Greek *Septuaginta* (Rahlfs) was regularly consulted for variants or when the Hebrew text is corrupted or obscure. Besides the Greek and Hebrew Scriptures, major French and English translations, as well as UBS' translator handbooks and exegetical commentaries, were frequently consulted.

As for the translation method, the translators adopted the UBS's Common Language translation principles. The main objective was to communicate the Biblical message using as much as possible the everyday Khmer—without neglecting however serious Biblical exegesis.

A reader who knows both Khmer and English may find out that, whereas the TKV New Testament lies somewhere between the

New International Version and the Good News Bible, its Old Testament is more literal than NIV. This results from the linguistic features of the Khmer language. Hebrew expressions often allow the translators to translate the Old Testament more literally into Khmer. But the complexity of Greek grammar often pushed the translators to adopt the principle of dynamic equivalence.

The main concern of the translators was to provide the Khmer people not with a "religious dialect," but rather with a Bible which speaks the language they learn at school, the language they use in the workplace. During the working process, there was agreement among the translation team: "If we can keep the text literal we will do it; if not, we have to rely on dynamic equivalence. That is, we will translate sentences according to their original meanings. But above all we must pay attention to the Khmer grammar." One may notice that some grammatical features, such as tense, participle, and passive, do not occur in the new translation. The translators did not want to force an unfamiliar syntactic style unto the Khmer Bible text, which creates confusion for the readers more than helps them understand properly the Word of God. For instance, the passive form (which is not used in Khmer) was forced on the Bible text in some earlier translation work, and this rendered understanding extremely difficult for the reader. The new translation used only the active voice. In Mark 2:5 you cannot say in Khmer, "Your sins are forgiven," without rendering the text obscure. Therefore the TKV translators used the active form with Jesus saying, "I forgive your sins." With such a declaration, we understand better why the scribes reacted against him: "Why does this fellow speak in this way? It is blasphemy! Who can forgive sins but God alone?" (Mk 2:7)

The team was aware that translating the scriptures written in a Judeo-Greek setting into a language influenced by Hindu-Buddhist religious context—where the basic concepts of God, sin, life, love, heaven, salvation, etc., each have a semantically different dimension—is not an easy task. Therefore each word that has its origins in Pali or Sanskrit has been meticulously analyzed before using it in the Biblical text. By doing so, the translators don't want

to allow any possibility of syncretism. For instance, in the past the term *stan suor* has often been used for "heaven(s)." But in the Khmer cosmological worldview, *stan suor* is a place where all divinities live, and it is still related to the present sinful world. By saying "God dwells in *stan suor*" we make him, in the eyes of ordinary Khmer, imperfect and less than Buddha, because the latter has already reached Nirvana according to Buddhist belief. As we are ministering to a Buddhist audience, we must beware not to create misunderstandings. Therefore, the new translation has adopted a more neutral term *stan borom sokh* (the Most-Peaceful-Place).

## Motivation

While translating the Bible, the TKV translators always kept in mind that God communicates with humans through language—a language that can be understood by people—so that in turn people can perceive God through language. Late in the nineteenth century, the discovery of non-biblical Greek manuscripts of many kinds revealed that the New Testament was written in the everyday language of the first century, called *koinê* Greek. This is why the team adopted the Common Language principles, with hope that the Scripture will be accessible to all.

The TKV translators were also motivated by evangelistic commitment. The disciples were commanded to "go and make disciples of all nations." (Matt. 28:19) It is unimaginable to think about "go and make disciples" without providing the Scripture in a language they can understand. The Bible has a fundamental role to play in helping people discover God and recognize their need of God's redemption.

We are aware that no translation is perfect. But being convinced that the Word of God can bring healing and transformation to the Cambodian people and society, the translators continue to pray that the Holy Spirit works in the heart of those who read this Bible. If they understand God's message, and their spiritual life is transformed, the goal has been reached.

សំណុំឱកឃ្មុំ ១/១ (កក្កដា ២០០០): ៤៧-៥២

# ការបកប្រែព្រះគម្ពីរជាភាសាខ្មែរ

ដោយ លោក សុខ ញឹបអរុណ

*(បកប្រែពីភាសាអង់គ្លេសដោយ លោក អ៊ួនសិលា)*

*******

ស្ទើរតែពីរឆ្នាំកន្លងមកហើយ ដែលការបកប្រែថ្មីនៃព្រះគម្ពីរជាភាសាខ្មែរ - ភាសាខ្មែរសម្រាយ (ឬភាសាខ្មែរបច្ចុប្បន្ននេះ) ត្រូវបានបើកសម្ពោធឲ្យប្រើជាផ្លូវការ ដែលប្រារព្ធធ្វើនៅទីក្រុងភ្នំពេញ មានការចូលរួមនៃគ្រីស្ទបរិស័ទជាច្រើនមកពីនិកាយ និង ក្រុមផ្សេងៗ ។ មួយអាទិត្យ ក្រោយមកបន្ទាប់ពីពិធីសម្ពោធនោះ ព្រះគម្ពីរបកប្រែថ្មី នោះមួយក្បាលត្រូវបានគេ យកទៅថ្វាយដល់ព្រះមហាក្សត្រ និង ព្រះរាជអគ្គមហេសី នៃព្រះរាជាណាចក្រកម្ពុជា ។ ពិធីនេះបានបង្ហាញឲ្យឃើញពីការសម្រេចជោគជ័យ នៃការបកប្រែព្រះគម្ពីរ ដែលបានចាប់ផ្ដើមឡើងនៅក្នុងឆ្នាំ១៩៨៥ ។ ប៉ុន្តែការបកប្រែថ្មីនេះក៏បង្ហាញឲ្យឃើញពីការបន្តនូវការខំប្រឹងដ៏យូរអង្វែង ដើម្បីផ្ដល់នូវព្រះបន្ទូលរបស់ព្រះ ជូនដល់ជនជាតិខ្មែរផងដែរ ។

**ក្រុមអ្នកត្រួសត្រាយផ្លូវ**

កិច្ចខំប្រឹងប្រែងលើកដំបូងបំផុតនោះ គឺបានធ្វើឡើងដោយបូជាចារ្យជនជាតិបារាំងម្នាក់ ឈ្មោះម៉ារី-យ៉ូសែប ហ្គិសដិន Marie—Joseph Guedon)នៅចុងសតវត្សរ៍ទី១៩ ។ ហ្គិសដិន បានបកប្រែអត្ថបទនានាពីដំណឹងល្អទាំងអស់ សំបុត្រនានា និង ទំនុកតម្កើង សំរាប់ប្រើក្នុងពេលថ្វាយបង្គំរបស់កាតូលិក ។ នៅក្នុងឆ្នាំ ១៨៩៩ ដំណឹងល្អ តាមលោកលូកា ត្រូវបានគេបោះពុម្ព ដែលជាផលផ្លែនៃការ សហការរវាងមន្ត្រីជាន់ខ្ពស់នៅក្នុងរដ្ឋាភិបាលបារាំង និង អ្នកបកប្រែរបស់ព្រះមហាក្សត្រ ។ នៅក្នុងពេលប្រហាក់ប្រហែលគ្នានោះដែរ មានភ្នាក់ងារម្នាក់ពីសមាគមព្រះគម្ពីរអាមេរិកកាំង ដែលនៅក្នុងទីក្រុងបាងកក បានសុំឲ្យលោកសង្ឃ ខ្មែរមួយអង្គបកប្រែគម្ពីរ លូកា និង គម្ពីរកិច្ចការ ពី ភាសាថៃ មក

ភាសាខ្មែរ ។ ការបកប្រែនេះត្រូវបានគេបោះពុម្ពនៅក្នុងឆ្នាំ ១៩០០ ។ ប៉ុន្តែ រហូតមកដល់ឆ្នាំ ១៩២៣ ទើបការបកប្រែព្រះគម្ពីរទាំងមូលបានចាប់ផ្តើម។ បេសកជនអាមេរិកកាំង ម្នាក់ ជាមួយនឹងអង្គការ CAMA លោកគ្រូគង្វាល អាធូរ ហាម៉ុង បានទទួលភារៈចំពោះកិច្ចការនេះ ។ ការបកប្រែនេះ ផ្អែកលើព្រះគម្ពីរ អាមេរិកកាំង (American Standard Version) ជាមូលដ្ឋាន ត្រូវបានចំណាយពេល ៣០ ឆ្នាំ ហើយព្រះគម្ពីរជាភាសាខ្មែរដំបូងគេបង្អស់ ដែលមិនធ្លាប់មានពីមុនមកត្រូវបានគេបោះពុម្ព រួចជាស្ថាពរ នៅក្នុងឆ្នាំ ១៩៥៤ ។

នៅដើមឆ្នាំ ១៩៧០ នៅខណៈដែលក្រុមជំនុំខ្មែរលូតលាស់យ៉ាងលឿនបំផុត នោះគ្រីស្ទបរិស័ទខ្មែរ យល់ថាត្រូវការឲ្យមានការបកប្រែតាមបែបបទទំនើបថែមទៀត ។ ដើម្បីឲ្យបានសម្រេចនូវសេចក្តីត្រូវការសមាគមព្រះគម្ពីរសកលបានចាប់ផ្តើមការងារបកប្រែ ដែលមានចំរុះនិកាយចូលរួមនៅក្នុងឆ្នាំ ១៩៧៣ មានអ្នកបកប្រែបួននាក់ មកពី ក្រុមដំណឹងល្អ ហើយនិងអ្នកបកប្រែម្នាក់ទៀត ជាសង្ឃរ៉ូម៉ាំងកាតូលិក ។ នៅឆ្នាំ ១៩៧៥ ក្រុមអ្នកបកប្រែបានបញ្ចប់ពង្រាងនៃការបកប្រែលើកទីមួយ នៃព្រះគម្ពីរសញ្ញាថ្មី ។ កាលនោះប្រទេសកម្ពុជាបានស្ថិតនៅក្នុងភាពចលាចលនៅក្រោមរបបខ្មែរក្រហម ។ អ្នកបកប្រែទាំងបួននាក់បានវិនាសបាត់បង់នៅក្នុងពេលនោះទៅ ហើយនិង សំណេរទាំងឡាយរបស់ការបកប្រែព្រះគម្ពីរសញ្ញាថ្មីនោះក៏ត្រូវបាត់បង់គ្មានសល់ លើកលែងតែ ៨ ជំពូកដំបូង នៃព្រះគម្ពីរម៉ាថាយ ។

**ការបកប្រែជាភាសាខ្មែរសម្រាយ**

គណៈកម្មាធិការចំរុះនិកាយ / អន្តរនិកាយថ្មីមួយ ត្រូវបានរៀបចំឡើងដោយសមាគមព្រះគម្ពីរសកល បានចាប់ផ្តើមការបកប្រែថ្មីនៅក្នុងឆ្នាំ ១៩៨៥ ។ ព្រះគម្ពីរសញ្ញាថ្មីត្រូវបានគេបោះពុម្ពនៅក្នុងឆ្នាំ ១៩៩៣ ហើយនិង ការបកប្រែព្រះគម្ពីរទាំងមូលបានចប់សព្វគ្រប់នៅក្នុងឆ្នាំ ១៩៩៧ ហើយនិង ត្រូវបានបោះពុម្ពនៅក្នុងឆ្នាំ ១៩៩៨ ។

ទោះបីជាមានភាពស្រដៀងគ្នាក្នុងការដាក់ឈ្មោះរវាងព្រះគម្ពីរភាសាខ្មែរសម្រាយក៏ដោយ ហើយនិង ព្រះគម្ពីរអង់គ្លេស Good News Bible (ឬព្រះគម្ពីរដំណឹងល្អ) ក៏ដោយ ព្រះគម្ពីរសម្រាយមិនបានបកប្រែតាមគម្ពីរអង់គ្លេសសព្វថ្ងៃនេះនោះឡើយ ។ តែព្រះគម្ពីរខ្មែរសម្រាយ បានប្រើអត្ថបទភាសាក្រិក និង

ព្រះគម្ពីរភាសាហេប្រឺ ធ្វើជាគោលក្នុងការបកប្រែនោះ ។ ព្រះគម្ពីរសញ្ញាចាស់ជាភាសាក្រិក គឺត្រូវបានគេយកមកពិគ្រោះជាទៀងទាត់ ចំពោះភាពខុសគ្នាផ្សេងៗ ឬនៅពេលអត្ថបទជាភាសាហេប្រឺ ដែលខូចខាតទៅ ឬក៏មិនសូវច្បាស់ ។ ក្រៅពីបទគម្ពីរជាភាសាក្រិក និង ហេប្រឺ ការបកប្រែជាភាសាអង់គ្លេស និង បារាំងសំខាន់ៗជាច្រើនទៀត ព្រមទាំងយកសៀវភៅរបស់សមាគមគម្ពីរសកល និង សៀវភៅពន្យល់នៃព្រះគម្ពីរផងដែរ មកធ្វើការផ្ទៀងផ្ទាត់ជាញឹកញាប់ ។

តាមវិធីសាស្ត្រនៃការបកប្រែ ពួកអ្នកបកប្រែប្រកាន់យកភាសាសាមញ្ញជាគោលការណ៍របស់សមាគមព្រះគម្ពីរសកល ។ គោលដៅចំបងនោះគឺថា ធ្វើការទាក់ទង ព្រះរាជសារនៅក្នុងព្រះគម្ពីរ ដោយប្រើភាសាខ្មែរសាមញ្ញតាមដែលអាចធ្វើបាន តែទោះជាយ៉ាងណាក៏ដោយ ក៏មិនបានខ្ជីខ្ជារលើសេចក្ដីពន្យល់របស់ព្រះគម្ពីរឡើយ ។

ចំពោះអ្នកអាន ដែលចេះទាំងខ្មែរទាំងអង់គ្លេសអាចយល់ថា ព្រះគម្ពីរសញ្ញាថ្មីជាភាសាខ្មែរសម្រាយ វាប្រហាក់ប្រហែលនឹងព្រះគម្ពីរជាភាសាអង់គ្លេស NIV និង Good News Bible ដែរ តែព្រះគម្ពីរសញ្ញាចាស់វិញមានលក្ខណៈដូចគម្ពីរដើមជាង NIV ។ លទ្ធផលនេះមកពីលក្ខណៈពិសេសនៃភាសាខ្មែរ ។ សំណួនវោហារស័ព្ទជាភាសាហេប្រឺ ជារឿយៗបានអនុញ្ញាតឲ្យពួកអ្នកបកប្រែអាចបកប្រែព្រះគម្ពីរសញ្ញាចាស់មកជាភាសាខ្មែរបានចំៗពាក្យច្រើនជាង ។ ប៉ុន្តែដោយមានបញ្ហាស្មុគ្រស្មាញផ្នែកវេយ្យាករណ៍នៃភាសាក្រិកជារឿយៗ ធ្វើឲ្យក្រុមអ្នកបកប្រែបង្ខំចិត្តប្រកាន់យកគោលការណ៍រក្សាអត្ថន័យ ដែលស្មើគ្នានឹងបទគម្ពីរដើម ។

ការខ្វល់ខ្វាយសំខាន់របស់ក្រុមអ្នកបកប្រែ គឺត្រូវផ្ដល់ឲ្យជនជាតិខ្មែរនូវភាសាមួយ ដែលមិនមែនជាភាសា “សាសនា” ប៉ុន្តែចង់ឲ្យព្រះគម្ពីរប្រើភាសាមួយដែលរៀននៅឯសាលា និង ភាសាដែលគេប្រើនៅឯកន្លែងធ្វើការ ។ នៅក្នុងកំឡុងពេលដែល យើងកំពុងធ្វើការនេះ មានការយល់ព្រមគ្នាមួយ នៅក្នុងចំណោមក្រុមអ្នកបកប្រែគឺថា: “បើសិនជាយើងអាចរក្សាអត្ថបទដើមបាន យើងនឹងទុក បើយើងទុកមិនបានទេ យើងត្រូវពឹងផ្អែកលើអត្ថន័យដែលស្មើគ្នា ។ គឺបានសេចក្ដីថា យើងនឹងបកប្រែប្រយោគទាំងឡាយនោះ ឲ្យស្របគ្នានឹងអត្ថន័យដើមរបស់ប្រយោគទាំងនោះ ។ ប៉ុន្តែពិសេសជាងនេះទៅទៀតនោះ យើងត្រូវផ្ដោតលើវេយ្យាករណ៍របស់ភាសាខ្មែរ” ។ គេអាចសំគាល់ឃើញថាលក្ខណៈ

ពិសេសរបស់វេយ្យាករណ៍ដូចជា កាលផ្សេងៗ ហើយនិងបែប Passive មិនឃើញនៅក្នុងការបកប្រែថ្មីឡើយ ។ ក្រុមអ្នកបកប្រែមិនចង់បង្ខំឲ្យអ្វីដែលជាការកសាងប្រយោគចម្លែកឲ្យមាននៅក្នុងអត្ថបទព្រះគម្ពីរជាភាសាខ្មែរ ដែលជាហេតុនាំឲ្យ អ្នកអានច្រឡំច្រើនជាងជួយឲ្យគេយល់ពីព្រះបន្ទូលរបស់ព្រះបានត្រឹមត្រូវ ។ ឧទាហរណ៍ បែបជា Passive គឺមានន័យថា ប្រធានជាអ្នករងអំពើ ដែលមិនធ្លាប់មានក្នុងភាសា ខ្មែរត្រូវបានគេបង្ខំឲ្យប្រើនៅក្នុងអត្ថបទព្រះគម្ពីរ នៅក្នុងការងារបកប្រែពីមុនខ្លះៗ ហើយនិងការនេះបណ្ដាលឲ្យមានការពិបាកយល់ចំពោះអ្នកអាន ។ គម្ពីរបកប្រែថ្មី ប្រើតែ ប្រយោគដែលប្រធានធ្វើអំពើ (Active Voice) ប៉ុណ្ណោះ ។ នៅក្នុងម៉ាកុស ២:៥ លោកអ្នកមិនអាចនិយាយជាភាសាខ្មែរថា "អំពើបាបរបស់អ្នកត្រូវបានអត់ទោសឲ្យហើយ ដោយមិនមានការពិបាកយល់អត្ថន័យនៃអត្ថបទចម្លែកនេះបានឡើយ ។ ហេតុដូច្នេះហើយបានជាក្រុមអ្នកបកប្រែគម្ពីរភាសាខ្មែរសម្រាយប្រើទម្រង់ប្រយោគបែបប្រធានធ្វើអំពើដោយ ប្រើថា ព្រះយេស៊ូមានបន្ទូល "ខ្ញុំបានអត់ទោសបាបឲ្យអ្នករួចហើយ" ។ ដោយមានការប្រកាសបែបនោះយើងយល់ប្រសើរជាង ហេតុអ្វីបានជាអ្នកសរសេរមានប្រតិកម្មប្រឆាំងនឹងព្រះអង្គទៅវិញដែលថាៈ "ហេតុអ្វីបានជាមនុស្សនេះនិយាយបែបនេះទៅវិញ? វាជាការមើលងាយដល់ព្រះ! តើនរណាអាចអត់ទោសបាបបាន មានតែព្រះជាម្ចាស់តែ ប៉ុណ្ណោះ? (ម៉ាកុស ២:៧) ។

ក្រុមអ្នកបកប្រែបានដឹងច្បាស់ នូវការបកប្រែបទគម្ពីរ ដែលបាន សរសេរជាភាសា Judeo—Greek រៀបឲ្យទៅជាភាសាមួយ ដែលមានឥទ្ធិពលដោយពុទ្ធសាសនា បែបហិណ្ឌូត្រង់កន្លែងដែលផ្អែកលើគំនិតជាចម្បង ចំពោះអំពើបាប ជីវិត សេចក្ដីស្រឡាញ់ ស្ថានសួគ៌ សេចក្ដីសង្គ្រោះ ជាដើម ។ ពាក្យនិមួយៗមានអត្ថន័យផ្សេងៗគ្នា0វាមិនមែនជាការងាយស្រួលឡើយ ។ ហេតុដូច្នេះហើយ ពាក្យនិមួយៗមានប្រវត្តិដើម ក្លាយមកពីបាលី និង សំស្ក្រឹត ត្រូវយកមកកែញែកឲ្យបានល្អិតល្អន់ជាមុនសិន មុននឹងប្រើនៅក្នុងអត្ថបទព្រះគម្ពីរ។ ចំពោះការធ្វើបែបនោះ ក្រុមអ្នកបកប្រែមិនផ្ដល់ឱកាសដល់លទ្ធិឆ្វេងនិយមណាមួយកើតមានឡើយ ។ ឧទាហរណ៍ កាលពីដើម ស្ថានសួគ៌ ជារឿយៗគេ ប្រើសំរាប់ "ឋានសួគ៌" ។ ប៉ុន្តែនៅក្នុងភាសាខ្មែរ តាមគំនិតលោកបែប អវកាសវិទ្យា ស្ថានសួគ៌ គឺជាកន្លែង ដែលពួកអាទិទេពរស់នៅ ហើយនិង វានៅតែ ជាប់

ទាក់ទងមកពីលោកីយ៍ ដែលពោរពេញដោយអំពើបាបបច្ចុប្បន្នដដែល ។ ដោយការ និយាយថា "ព្រះជាម្ចាស់គង់នៅឯស្ថានសួគ៌" តាមក្រសែភ្នែករបស់ជនជាតិខ្មែរសាមញ្ញ យើងបានបង្អាប់ព្រះអង្គទ្រង់ឲ្យទន់ទាបជាងព្រះពុទ្ធទៅវិញ ពីព្រោះថាអ្នកចុងក្រោយបានទៅដល់និព្វានរួចទៅហើយ យោងតាមជំនឿរបស់ពុទ្ធសាសនិកជន ។ នៅក្នុងខណៈ ដែលយើងផ្សាយដំណឹងល្អដល់ពុទ្ធសាសនិកជន យើងត្រូវតែដឹង មិនត្រូវធ្វើឲ្យមានការយល់ច្រឡំឡើយ ។ ហេតុដូច្នេះហើយ គម្ពីរបកប្រែថ្មីបានជ្រើសរើសយកពាក្យកណ្តាលមួយ គឺស្ថានបរមសុខ (កន្លែងដែលសុខបំផុត) ។

**ការលើកទឹកចិត្ត**

នៅក្នុងខណៈបកប្រែព្រះគម្ពីរ ក្រុមអ្នកបកប្រែគម្ពីរភាសាខ្មែរសម្រាយតែងតែ ចាំនៅក្នុងគំនិតជានិច្ចថា ព្រះជាម្ចាស់ទាក់ទងមកមនុស្សតាមរយៈភាសា គឺជាភាសា ដែលមនុស្សអាចយល់បាន ដើម្បីឲ្យមនុស្សអាចទាក់ទងព្រះជាម្ចាស់វិញតាមរយៈភាសានោះ ។ នៅចុងសតវត្សរ៍ទី ១៩ ការស្វែងរកឃើញសំណេរជាភាសាក្រិក ដែលមិនមែន ជាព្រះគម្ពីរ ជាច្រើនប្រភេទ ដែលបង្ហាញឲ្យឃើញថា ព្រះគម្ពីរសញ្ញាថ្មី កាលជំនាន់គេសរសេរដោយប្រើភាសាប្រចាំថ្ងៃ នៃសតវត្សរ៍ ទី១ ដែលគេឲ្យឈ្មោះថា ក័ញនេ ក្រិក (Koiné Greek) ។ ហេតុដូច្នេះ ទើបក្រុមអ្នកបកប្រែប្រកាន់យកភាសាសាមញ្ញជាគោលការណ៍ ដោយមានសេចក្តីសង្ឃឹមថាបទគម្ពីរនឹងអាច បំពេញសេចក្តីត្រូវការដល់មនុស្ស គ្រប់ស្រទាប់ជាន់ថ្នាក់ ។

ក្រុមអ្នកបកប្រែព្រះគម្ពីរសម្រាយក៏មានសន្ទុះចិត្តផងដែរ ដោយកាប្តេជ្ញាចិត្ត ក្នុងការផ្សាយដំណឹងល្អ ។ ព្រះជាម្ចាស់បានបង្គាប់ដល់ពួកសិស្ស "ចូរចេញទៅហើយនិងបង្កើតសិស្សនៅគ្រប់ទាំងសាសន៍ ។ " (ម៉ាថាយ ២៨:១៩) វាជាការមួយមិនអាចស្រមើស្រមៃបានសោះ ដែលគិតថា "ចេញទៅហើយបង្កើតសិស្ស" ដោយមិនបានផ្តល់ព្រះគម្ពីរតាមភាសាមួយ គេអាចយល់បាននោះ ។ ព្រះគម្ពីរមានតួនាទីសំខាន់យ៉ាង មុតមាំ ក្នុងការជួយឲ្យមនុស្សស្វែងរកព្រះជាម្ចាស់ និងទទួលស្គាល់ថា គេត្រូវការ ការប្រោសលោះពីព្រះជាម្ចាស់ ។

យើងក៏ដឹងថាគ្មានការបកប្រែណាមួយដែលត្រូវឥតខ្ចោះនោះឡើយ ។ ប៉ុន្តែយើងដឹងច្បាស់ថា ព្រះបន្ទូលរបស់ព្រះជាម្ចាស់អាច នាំមកនូវការប្រោស ឲ្យជា និងការបំផ្លាស់បំប្រែជនជាតិខ្មែរនិងសង្គមខ្មែរ ក្រុមអ្នកបកប្រែ បន្ត

អធិស្ឋានសូមឲ្យព្រះវិញ្ញាណបរិសុទ្ធ ធ្វើការក្នុងចិត្តចំពោះអ្នកដែលបានអានព្រះគម្ពីរនេះ ។ បើគេយល់ ព្រះរាជសារ របស់ព្រះជាម្ចាស់នោះ ជីវិតខាងវិញ្ញាណរបស់គេបានផ្លាស់ប្រែ ហើយទិសដៅ របស់យើងក៏សម្រេចបានដែរ ។

HONEYCOMB 1/1 (July 2000): 53–58

# Cambodian Youth in the New Millennium

*Brian MAHER*

A well-worn cliché assures us that "Christian young people are leaders of the future church." Like all clichés, this one is dangerous because the half-truth it contains comes to be believed and acted upon if repeated enough.

The truth is that young people are the leaders in church *today* as well as tomorrow. Christian young people are leaders just by virtue of being Christian. Many of Cambodia's urban churches are filled with believers between the ages of 15 and 25. How did this happen? It came about through Christian young people telling their friends about their experiences with Jesus Christ, and allowing them to observe how He changed them. Is this not true leadership?

Cambodia over the last seven years has seen numerous groups from outside wanting to train church leaders through short seminars. (Too often these groups come uninvited, and know little about the people, culture, or church history of Cambodia.) Over all those years I can't remember many groups coming to lead seminars for youth, except for an occasional David C. Cook seminar to develop their writing skills. Youth ministry has not seen much foreign input except for strictly denominational events. There has been little interest from overseas to help Christian young people as a whole. More encouragement has come from within the national church and the international Christian community here in country. For example, EFC Youth Commission's annual youth conference is financed largely by the international Christian community in Cambodia and the national church. Youth ministry does not seem

to loom large in the vision of overseas missions in general. Even my own supporters take care of my personal needs but rarely contribute specifically to youth work.

The Cambodian churches who will still be around in the next twenty years will be those with a sustainable vision for youth. For example, Open Gate Fellowship in Phnom Penh encourages this generation of Christian young people to take part in all its programs and planning. This church has been discipling and using its young people as participants in ministry, in contrast with others where the pastor holds all the power and spends a lot of energy protecting and consolidating that power. Open Gate thrives because it grasps the value and potential of youth—a necessary ingredient for the health and growth of any church.

My first trip to Cambodia was in September 1990, with Kong Chhon and Sithan Lee. Sithan and Chhon held training sessions with national church leaders (pastors and elders) on the third floor of Pastor Im Chhrorn's church, then called Psa Tmei 1, while I taught young people from Santho Mok, Psa Tmei 1, Toul Tom Poong Church, Tonle Basaac Church, Tom Nop Tek Church, Takmau Church, Solomon and some others. There were nine churches in the Phnom Penh area in that time. On that trip Muth Bunthy and Sar Paulerk served as my translators.

I remember meeting Eang Chhun, Bin David, Ngin Sacrowar, Khieu Vanlorn, Taing Nary, Lav Houn, Yorng Soth, Ung Sophal, Ngeth Sambo, Em Sithan and Heng Cheng. I also met a lot of young people as well. Some of the orphans that Ngin Sacrowvar worked with in Orphanage #1 were Christians in their late- and mid-teens. They attended Muth Bunthy's church, which was meeting in his house at the time, near the orphanage on the river road, just this side of the Chreuy Changvar Bridge. I clearly remember spending time with Srey Rot, Chan Remey, Srey Chenda, Song Sol Molly, Mr. Son Tha and Mr. Oun Chan Sinat. Sao Volek, Srey Heim, Somaly, and scores of others also made my acquaintance.

On a 1992 trip I met Uong Vibol, Uy Pheara, Heng Borin, Suy Visal, Sileng Sumanea, Chan Dara, Wattanah Lo, and Pastor

Uong Rein, who was pastoring Psa Tmei 3 Church at the time. There are many I have left out, but if we stop to wonder what these particular young people of ten years ago are doing now you would be pleasantly surprised to find that most of them are still actively pursing the Christian faith and are indeed involved as "leaders" in churches, Christian organizations, Christian NGO's, businesses, public schools, and the like.

Because of people like Chhon Kong, Ngin Sacrovar, Bin David, Muth Bunthy, Uong Rein, and other pastors who realized the value of Cambodian young people early on, and who nurtured and encouraged them along the way, we now have a small solid cross section of church leadership with close to ten years of experience in the faith and ministry.

In 1992–93, with the influx of Christian NGO's and missionaries, and with Christians returning from the border, the church got an additional boost and continued to grow numerically. In the urban areas, many lower-middle to middle class youth were attracted to gospel. This generation of youth had seen how communism and their traditional religious beliefs had failed them. They were sick of corruption, war, exploitation, and a succession of governments which only served themselves at the expense of the people. Through the lives of Christian young people, the new Cambodian youth got a glimpse of the Good News being practically worked out. And they saw hope.

The instability of the early and mid 90's seemed to encourage the growth of the Kingdom of God, as young peopl pondered their philosophies of life and religion, and the influence of these on their personal and national lives. With the coming of UNTAC in 1993, a whole new world opened to Cambodian youth. The west introduced both its often seamy popular culture, as well as its more positive science and technology. A majority of middle class, educated youth rejected former ties to traditional beliefs and communism, and put their hope science, technology, and democracy as their new gods. So the challenge here, at least in the city, is not so much to unravel the mysteries of Buddhism, animism, or the worship of ancestors in order to learn how to make

Christianity more applicable. The challenge is not to become expert rational apologists who can effectively answer academic claims of naturalistic materialism, secular humanism, and evolution (although on occasion this would be helpful). The real challenge is make our faith existentially relevant.

Many youth leaders have told me that they cannot get people to come their youth programs anymore. They are afraid of *reung sahsnah*—anything smacking of religion. They suspect it is something religious and politely decline the offer. Proclamation and confrontational styles of evangelism used for youth are hardly effective these days. Christian organizations that use such models are finding the return on their efforts next to nil. Even the tried-and-true "ambush" method of evangelism—where you invite unbelievers to a seemingly "normal" event at church and then sneak up and give both barrels—is failing.

It is time to move out of the program mode. We cannot expect our audience to come to us; we must go to them. This is what Jesus did. He went to where the people were. Today what we offer the world is seen as irrelevant. When we offer them the "liberating truth of the Gospel," we are often perceived as being arrogant or pushing a particular religious agenda. We Christians are not seen as meeting the perceived needs of the people of this world. The youth, as salt, need to get out of shaker and into the world. Christian youth need to earn the right to be heard by their peers by meeting both the real and perceived needs of the community, whether it be caring for the environment, ministering to AIDS patients, engaging in emergency relief, or serving poor or displaced people. Through such relevant and biblical ministry, youth can have a powerful impact on their peers by serving in a natural rather than contrived contexts.

Another challenge for young Cambodian Christians is to develop a valid, biblical theology, and to understand the world. To many, "the world" is anywhere one finds rock'n roll, sex, alcohol, gambling, or smoking. To much of the Cambodian church, a mature Christian is someone who doesn't *puk, see, srey nee, oun-bong* (sex, drugs, and rock & roll). If you have cut these things

from your life, then according to some Christian circles you have arrived. Influence from traditional beliefs and some of our more conservative foreign missionaries reenforced this unhealthy concept. In many cases it leaves sins of the heart unaddressed. While the obvious observable sins have been purged, prejudice, wife beating, hatred, discrimination against women, jealousy, control, and lust for power continue to live on in the heart. What happens is that we have sanctified bodies with a secular worldview. An understanding of Romans 12:2 and how the renewing of mind is critical in becoming like Christ is sorely needed.

There are few who are engaging the world as Jesus did. The majority embrace a theology of retreat from the world. In reality, "the world" is a "worldview"—a thought and value system—which opposes Kingdom values. There is no place for God in this system. Man is lifted up rather than God. The drinking, gambling, use of prostitutes, etc., are simply observable symptoms of a person whose worldview is "worldly." The challenge here is for youth not to retreat from the world, but to engage it like Jesus did. Jesus was perceived by "sinners" as being relevant to their needs. Cambodian Christian young people need to learn how to be real salt and real light, living in the world while not being contaminated by its value system. We, as disciplers need to make 'holistic' disciples. That is, we need take to heart Matthew 28, especially the verse where Jesus exhorts us to "[teach] them to obey everything I have commanded you." Jesus showed his disciples how to live in the world in all areas. Our obligation in discipleship goes beyond sitting down with a young person and going through a Navigators study. It entails teaching him or her how to interpret "the world," and how to live in it victoriously in all areas of life—life-style, courtship, family life, Christian response to social problems, stewardship of finances, citizenship, etc.

There is further confusion among youth about the value of the roles they choose. Many are taught that the highest calling is to become a pastor, missionary, full-time church worker, or staff in a Christian NGO. So, whether "called" or not, they pursue the

ministry out of misguided direction. The highest calling is not to become a pastor; it is to use one's talents and gifts **wherever** God calls. If God calls a young person to be soldier, he needs to be a soldier. If God calls a person to be a business person, she needs to do that. God calls people into every facet of vocational life in order for the church to be salt and light that is evenly distributed. "Full-time Christian workers" are no more valuable for the Kingdom than Christians who live out their faith as doctors, lawyers, journalists, dentists, foresters, geologists, business people, etc. Cambodian Christian youth need to understand the value of a role outside the church, in order to enter all levels of society to be salt and light. Neither Joseph nor Daniel were pastors, yet they transformed society from within. Cambodian Christian young men and women entering the system as professionals will not only thus acquire a natural context for Christian witness, but may also effect policy changes which result in Cambodian society resembling the Kingdom of God in one area a bit more than it did before. When this repeatedly happens, the Cambodian church will be effectively working with Jesus to "reconcile all things to himself"—souls and systems alike (Col 1:19, 20).

A tall order for Cambodian Christian youth? Not at all. They have the heart; they have mind; they have the potential. And, unlike some of their spiritual fathers, they are flexible. They are more interested in unity, have fewer problems working side by side with foreigners, and exercise a more global perspective. This generation of Cambodian Christian young men and women will really make an impact on this country. But a lot of that will depend on what kind of guidance, teaching, and encouragement the Cambodian church leaders give them, as well as what kind of guidance the Christian expatriate community gives both youth and national church leaders. In many ways, it is also up to us. So, let us stop for minute and consider the situation of Cambodian Christian youth. Who will walk with them side by side, teaching them to take initiative and use their creativity to address new dilemmas the church will face?

សំណុំឌីកឃ្មុំ ១/១ (កក្កដា ២០០០): ៥៩-៦៧

# ជំរុញលើកទឹកចិត្តចំពោះយុវជនកម្ពុជានាសហស្សវត្សរ៍ថ្មី

ដោយ លោក ប្រាយអិន ម៉ាហ៊ីរ៍

*******

ប្រយោគចាស់គំរិលមួយឃ្លា ដែលគេតែងតែអះអាងចំពោះយើងថា "យុវជនគ្រីស្ទបរិស័ទ គឺជាអនាគតនៃអ្នកដឹកនាំក្រុមជំនុំ" ។ ប្រយោគទាំងអស់ដែលស្រដៀងនឹងប្រយោគនេះ ជាការមួយគ្រោះថ្នាក់ណាស់ ពីព្រោះមានការពិតតែពាក់កណ្តាលដែលត្រូវឲ្យគេជឿបាននិងប្រព្រឹត្តតាម បើសិនជាបានរំលឹកឡើងវិញគ្រប់គ្រាន់ល្មម ។

ការពិតគឺថា យុវជនគឺជាអ្នកដឹកនាំក្រុមជំនុំ នាពេលបច្ចុប្បន្ននេះរួចទៅហើយ ព្រមទាំងនាពេលអនាគតផងដែរ ។ យុវជនគ្រីស្ទបរិស័ទ គឺជាអ្នកដឹកនាំដោយគ្រាន់តែក្លាយជាគ្រីស្ទបរិស័ទប៉ុណ្ណោះ ។ ក្រុមជំនុំកម្ពុជាជាច្រើននៅទីក្រុងមានអ្នកជឿដែលមានអាយុពី១៥ ទៅ ២៥ឆ្នាំ ។ តើប្រការនេះកើតឡើងយ៉ាងម៉េច? គឺកើតឡើងតាមរយៈយុវជនគ្រីស្ទបរិស័ទ ដែលបានប្រាប់ទៅមិត្តភក្តិរបស់ខ្លួន អំពីបទពិសោធន៍ទាំងឡាយរបស់ខ្លួន ដែលគេមានជាមួយព្រះយេស៊ូគ្រីស្ទ ហើយនិងធ្វើឲ្យគេសង្កេតមើលពីរបៀប ដែលទ្រង់បំផ្លាស់បំប្រែពួកគេ។ តើនេះមិនមែនជាការដឹកនាំពិតទេឬ?

នៅក្នុងប្រទេសកម្ពុជា ជាង ៧ ឆ្នាំ ចុងក្រោយក្នុងសហវត្សរ៍ចាស់ ឃើញមានក្រុមផ្សេងៗជាច្រើនមកពីក្រៅ ដែលចង់ហ្វឹកហ្វឺនអ្នកដឹកនាំក្រុមជំនុំតាមរយៈសិក្ខាសាលាខ្លីៗ ។ (ជាញឹកញាប់ ក្រុមទាំងនោះ មកដោយគ្មានការអញ្ជើញ ហើយនិងស្គាល់ជាតិខ្មែរ វប្បធម៌ ឬ ក៏ប្រវត្តិក្រុមជំនុំខ្មែរបានបន្តិចបន្តួច) ។ ក្នុងប៉ុន្មានឆ្នាំនោះ ខ្ញុំចាំមិនបានថាមានក្រុមចំនួនប៉ុន្មាន ដែលធ្វើសិក្ខាសាលាសំរាប់យុវជនទេ លើកលែងតែវគ្គសិក្ខាសាលារបស់ David C. Cook ស្តីពីការពង្រឹងជំនាញផ្នែកវិជ្ជានិពន្ធរបស់គេ ។ ព័ន្ធកិច្ចយុវជនមិនសូវឃើញ

មានចំណែករបស់បេសកកម្ម មកពីបរទេសច្រើនណាស់ណាទេ លើកលែងតែព្រឹត្តិការណ៍ផ្សេងៗ របស់និកាយនានាប៉ុណ្ណោះ ។ មានការចាប់អារម្មណ៍ដ៏តិចតួចចំពោះអ្នក ដែលនៅក្រៅប្រទេស ក្នុងការជួយយុវជនគ្រីស្ទបរិស័ទជាទូទៅ ។ ការលើកទឹកចិត្តខ្លាំងក្លាគឺចេញពីក្រុមជំនុំជាតិ និង ក្រុមជំនុំគ្រីស្ទបរិស័ទអន្តរជាតិដែលនៅក្នុងប្រទេស ។ ឧទាហរណ៍ សន្និបាតយុវជនប្រចាំឆ្នាំ/បោះជំរំយុវជនរបស់ គណៈកម្មការយុវជនប្រិយសម្ពន្ធគ្រីស្ទបរិស័ទកម្ពុជា បានទទួលថវិកាផ្គត់ផ្គង់ជាច្រើន ដោយក្រុមជំនុំគ្រីស្ទបរិស័ទអន្តរជាតិ ដែលនៅក្នុងប្រទេស និង ក្រុមជំនុំក្នុងស្រុក ។ ព័ន្ធកិច្ចយុវជនមើលទៅដូចជាមិនលេចឡើងធំធេងក្នុងទស្សនៈ របស់បេសកកម្មខាងក្រៅប្រទេសជាទូទៅឡើយ ។ សូម្បីតែពួកអ្នកដែលជាអ្នកផ្គត់ផ្គង់ខ្ញុំផ្ទាល់ គេយកចិត្តទុកដាក់ ចំពោះសេចក្តីត្រូវការផ្ទាល់ខ្លួនរបស់ខ្ញុំមែន ប៉ុន្តែគេកម្រនឹងផ្តល់វិភាគទាន ពិសេសលើការងារយុវជនសោះឡើយ ។

ចំពោះក្រុមជំនុំកម្ពុជា ដែលនៅតែមានដំណើរការក្នុងអំឡុងពេល ២០ ឆ្នាំ ខាងមុខ គឺជាពួកជំនុំមានទស្សនៈផ្តោតជាប់ទៅលើយុវជន ។ ឧទាហរណ៍ ពួកជំនុំទ្វារស្ថានសួគ៌ចំហាក្នុងទីក្រុងភ្នំពេញ បានលើកទឹកចិត្តគ្រីស្ទបរិស័ទជំនាន់នេះឲ្យរួមចំណែកក្នុងគ្រប់កម្មវិធីទាំងអស់ និង ការរៀបចំផែនការទាំងឡាយរបស់ក្រុមជំនុំ ។ ព្រះវិហារនេះបាន និង កំពុងអប់រំ ហើយនិង ប្រើប្រាស់ពួកយុវជនរបស់ខ្លួន ឲ្យចូលប្រឡូកក្នុងព័ន្ធកិច្ចនានា ផ្ទុយទៅវិញចំពោះអ្នកផ្សេងនៅកន្លែងដទៃ ដែលគ្រូគង្វាលក្តោបអំណាច ហើយនិង ចំណាយកម្លាំងយ៉ាងច្រើនក្នុងការការពារ ហើយនិងពង្រឹងអំណាចឲ្យរឹងមាំឡើង ។ ទ្វារស្ថានសួគ៌ចំហាបានរីកចំរើនលូតលាស់ ដោយសារតែបានឈោងចាប់យកតម្លៃ និង សក្តានុពលរបស់យុវជន ដែលជាគ្រឿងផ្សំដ៏ចាំបាច់ សំរាប់សុខភាព និង ការរីកចំរើនលូតលាស់របស់ ក្រុមជំនុំ ។

ខ្ញុំបានធ្វើដំណើរមកកម្ពុជាជាលើកដំបូងនៅខែកញ្ញា ឆ្នាំ ១៩៩០ ជាមួយនឹងលោក គង់ ឆុន និង លោក ស៊ីថាន លី ។ ស៊ីថាន លី និង លោក ឆុន បានរៀបចំបើកវគ្គហ្វឹកហ្វឺនដល់អ្នកដឹកនាំក្រុនជំនុំជាតិ (គ្រូគង្វាល និង ពួកចាស់ទុំ) នៅជាន់ទីបីនៃព្រះវិហារ លោក អ៊ឹម ជ្រេន ដែលកាលនោះគេគេហៅថា ព្រះវិហារផ្សារថ្មីទី១ នៅពេលនោះដែរ ខ្ញុំបានបង្រៀនដល់យុវជន ដែលមកពី

ក្រុមជំនុំសន្ធរម៉ុក ផ្សារថ្មីទី១ ទួលទំពូង ទន្លេបាសាក់ ទំនប់ទឹក តាខ្មៅ សាឡូម៉ូន និង មកពីក្រុមជំនុំផ្សេងៗទៀត ។ មានព្រះវិហារចំនួន ៩ កន្លែងនៅក្នុងភ្នំពេញនាពេលនោះ ។ ក្នុងដំណើរលើកនោះ លោក មុត ប៊ុនធី និង លោក សរ ពលៈ ជាអ្នកបកប្រែភាសាឲ្យខ្ញុំ ។

ខ្ញុំនៅនឹកចាំនូវការដែលបានជួបលោក អៀង ឈុន, ប៊ិន ដាវីឌ, ងិន ស័ក្ររ៉ា, ខៀវ វ៉ាន់ឡុង, តាំង ណារី, ឡាវ ហឿន, យ៉ង់ សុទ្ធ, អ៊ួង សុផល, ង៉ែតសម្បូរ, អែម សីថាន និង លោកហោង ចេង ។ ខ្ញុំក៏បានជួបយុវជនជាច្រើនទៀតផងដែរ ។ ក្មេងកំព្រាខ្លះ ដែលលោក ងិន ស័ក្ររ៉ា ដែលធ្វើការនៅមជ្ឈមណ្ឌលកុឡាបទី១នោះ ជាគ្រីស្ទបរិស័ទមានវ័យជំទង់ និង វ័យចំណាស់ជាងនោះបន្តិច ។ ពួកគេបានចូលរួមក្នុងព្រះវិហារលោក មុត ប៊ុនធី ដែលមានការជួបជុំគ្នានៅផ្ទះរបស់គាត់ក្នុងពេលនោះ នៅក្បែរមជ្ឈមណ្ឌលកុមារកំព្រានៅតាមផ្លូវមាត់ទន្លេ គឺនៅត្រើយខាងលិចស្ពានជ្រោយចង្វា ។ ខ្ញុំនៅចាំច្បាស់ថា បានចំណាយពេលនិយាយជាមួយ ស្រីរ័ត្ន, ចាន់ រស្មី, ស្រីចិន្តា, សុង សុលម៉ូលី, លោក សន ថា និង លោក អ៊ុន ចាន់ស៊ីណាត, សារ វលៈ, ស្រីហែម សូម៉ាលី និង មនុស្សមួយចំនួនទៀតដែលខ្ញុំស្គាល់ តែចាំឈ្មោះមិនបាន ។

ក្នុងការធ្វើដំណើរមកស្រុកខ្មែរ នាឆ្នាំ ១៩៩២ ខ្ញុំបានជួបលោក អ៊ួង វិបុល, អ៊ុយ ភារ៉ា, ហោង បូរិន, ស៊ុយ វិសាល, ស៊ីឡេង សូម៉ានា, ចាន់ តារា, វឌ្ឍនា ឡូ និង លោកគ្រូ អ៊ួង វៀន ដែលជាគ្រូគង្វាលនៅព្រះវិហារផ្សារថ្មីទី ៣ នាពេលនោះ ។ មានអ្នកផ្សេងទៀតជាច្រើននាក់ ដែលខ្ញុំមិនបានរាប់ឈ្មោះ ប៉ុន្តែបើបិទភ្នែកមួយភ្លែត ហើយពិចារណាមើលដល់យុវជនទាំងនោះ ថាតើមកពីអ្វីដែលជាលក្ខណៈពិសេសនៃយុវជនទាំងនេះ បានធ្វើក្នុងពេល ១០ ឆ្នាំ កន្លងមកទៅរហូតមកពេលនេះ លោកអ្នកនឹងមានការចម្លែកចិត្តយ៉ាងខ្លាំង ដោយឃើញថា ពួកគេស្ទើរតែទាំងអស់នៅតែសកម្មស្ទូទ្រាំក្នុងជំនឿគ្រីស្ទបរិស័ទ ព្រមទាំងពិតជាចូលរួមក្នុងតួនាទីជា "អ្នកដឹកនាំ" ក្នុង ក្រុមជំនុំអង្គការគ្រីស្ទបរិស័ទ អង្គការគ្រីស្ទបរិស័ទក្រៅរដ្ឋាភិបាល ហាងជំនួញផ្សេងៗសាលាសាធារណៈផ្សេងៗជាដើម ។

ដោយហេតុតែមានមនុស្សមួយចំនួនដូចជា លោក គង់ ឆុន និង ងិន ស័ក្ររ៉ា, ប៊ិន ដាវីឌ, មុត ប៊ុនធី, អ៊ួង រៀង និង គ្រូគង្វាលផ្សេងទៀត បានយល់ពីតម្លៃរបស់យុវជនកម្ពុជា តាំងពីដំបូង ហើយនិងបានបណ្តុះបណ្តាលព្រមទាំងលើកទឹកចិត្តពួកគេរៀងមក បច្ចុប្បន្នយើងមានយុវជនចំរុះនិកាយមួយក្រុមដែលរឹងមាំមួយចំនួនតូច ដែលមានបទពិសោធន៍ជិត ១០ ឆ្នាំ ក្នុងជំនឿ និង ព័ន្ធកិច្ចបំរើព្រះ ។

ក្នុងឆ្នាំ ១៩៩២-១៩៩៣ ដោយមានការហូរចូលមកនៃអង្គការគ្រីស្ទបរិស័ទក្រៅរដ្ឋាភិបាល និង បេសកជន និងដោយមានគ្រីស្ទបរិស័ទត្រលប់ពីព្រំដែនមកវិញ ក្រុមជំនុំត្រូវបានលើកស្ទួយថែមទៀត ហើយមានការរីកដុះដាលគួរឲ្យជាទីកត់សំគាល់ ។ នៅក្នុងតំបន់ទីក្រុង យុវជនដែលមានវណ្ណៈទាប រហូតដល់វណ្ណៈកណ្តាល បានទទួលការចាប់អារម្មណ៍លើដំណឹងល្អ ។ យុវជនជំនាន់នេះបានឃើញពីរបៀប ដែលលទ្ធិកុម្មុយនីស្ត និង លទ្ធិសាសនាតាមទំនៀមទម្លាប់ធ្វើឲ្យគេអន់ថយ ។ ពួកគេមានការធុញទ្រាន់នឹងអំពើពុករលួយ សង្គ្រាមអំពើកេងប្រវ័ញ្ច និង ការទទួលជោគជ័យរបស់រដ្ឋាភិបាល ដែលគ្រាន់តែបំរីប្រយោជន៍ផ្ទាល់ខ្លួន ដោយកម្លាំងញើសឈាមប្រជាពលរដ្ឋ ។ តាមរយៈការរស់នៅនៃយុវជនគ្រីស្ទបរិស័ទ យុវជនកម្ពុជាជំនាន់ថ្មីមានពន្លឺចែងចាំងនៃដំណឹងល្អ ដែលកំពុងធ្វើការក្នុងជីវិតគេ ។ ពួកគេបានមើលឃើញសេចក្តីសង្ឃឹម ។

កំឡុងពេលអស្ថេរភាព នៅដើម និង ពាក់កណ្តាលទសវត្សរ៍ទី ៩០ មើលទៅដូចជាជួយលើកទឹកចិត្តឲ្យមានសន្ទុះរីកចំរើននៃនគរព្រះដូចដែលយុវជនមានការសញ្ជឹងគិតទស្សនៈនៃជីវិតរស់នៅ និង សាសនា ព្រមទាំងឥទ្ធិពលនៃប្រការទាំងនោះចំពោះខ្លួនគេផ្ទាល់ និង ចំពោះអាយុជីវិតរបស់ប្រជាជាតិខ្លួន ។ ដោយមានការចូលមករបស់ អ៊ុនតាក់ (UNTAC) ក្នុងឆ្នាំ ១៩៩៣ ពិភពលោកថ្មីទាំងមូលបានបើកចំហ ចំពោះយុវជនកម្ពុជា ។ ទំនៀមទម្លាប់ដ៏ពេញនិយមរបស់លោកខាងលិច ដែលជារឿយៗគួរខ្ពើមផងនោះ បាននាំចូលមកបង្ហាញឲ្យខ្មែរបានស្គាល់ តែក្នុងនោះក៏មាន ចំណុចល្អខ្លះដែរ ដូចជាផ្នែកវិទ្យាសាស្ត្រ និង បច្ចេកវិទ្យា ។ វណ្ណៈថ្នាក់កណ្តាលភាគច្រើនបានអប់រំយុវជនឲ្យបដិសេធលើចំណងទាក់ទងពីមុនរបស់លទ្ធិពុទ្ធសាសនា និង លទ្ធិកុម្មុយនីស្ត

ចោលចេញ និង ដាក់សេចក្ដីសង្ឃឹមរបស់គេលើវិទ្យាសាស្ត្រ បច្ចេកវិទ្យា និង លទ្ធិប្រជាធិបតេយ្យទុកជាព្រះថ្មីរបស់គេ ។ ដូចនេះការជំរុញលើកទឹកចិត្តត្រង់នេះ យ៉ាងហោចណាស់ក៏នៅតែមិនសូវមានការស្រាយបំភ្លឺអំពីអាថ៌កំបាំងនៃពុទ្ធសាសនា ការជឿលើអារុក្ខអារក្សអ្នកតា ការបន់ស្រន់ដូនតា ដើម្បីរៀនឲ្យដឹងពីរបៀប ដែលត្រូវអនុវត្តជំនឿគ្រីស្ទបរិស័ទកាន់តែប្រសើរឡើង ។ ការជំរុញលើកទឹកចិត្តនេះ គឺមិនបានក្លាយជាអ្នកជំនាញ ផ្នែកតវ៉ាវែកញែកសមហេតុផលលើជំនឿគ្រីស្ទបរិស័ទ ដែលអាចឆ្លើយប្រកបដោយមានប្រសិទ្ធិភាព នៃសំភារៈនិយម បែបធម្មជាតិមនុស្សនិយម ដែលមិនទាក់ទងនឹងសាសនា និង ទ្រឹស្ដីនៃការវិវត្តន៍ (ទោះបីពេលខ្លះការនេះ វាមានប្រយោជន៍ក៏ដោយ) ។ ការជំរុញលើកទឹកចិត្តពិតប្រាកដគឺបង្ហាញជំនឿរបស់យើង ឲ្យទាក់ទងនឹងជីវិតពិត ដែលកំពុងរស់នៅ ។

អ្នកដឹកនាំយុវជនជាច្រើន បានប្រាប់ខ្ញុំថា គេមិនអាចនាំយុវជនឲ្យចូលរួមក្នុងកម្មវិធីយុវជនទៀតបានឡើយ ។ ពួកគេមាន ការភ័យខ្លាចរឿងសាសនា គឺអ្វីៗដែលជាការប៉ុនប៉ងផ្សាយសាសនា ។ គេមានការសង្ស័យថាជារឿងរ៉ាវផ្នែកសាសនា និង គេប្រកែកមិនព្រមចូលរួមដោយសុភាព ។ បែបបទនៃការប្រឈមមុខ នឹងការប្រកាសដំណឹងល្អ ដែលបានប្រើប្រាស់សំរាប់ យុវជន ពិបាកធ្វើឲ្យមានប្រសិទ្ធិភាពណាស់សព្វថ្ងៃនេះ ។ អង្គការគ្រីស្ទបរិស័ទ ទាំងឡាយធ្លាប់ប្រើជាគំរូបែបនេះ ដែលលទ្ធផលត្រលប់មកវិញ ចំពោះការប្រឹងប្រែងពួកគេស្ទើរអត់បានអ្វីសោះ ។ ទោះបើការព្យាយាម និង បង្ហាញការពិត ដោយវិធី "វាយឆ្មក់" ក្នុងការផ្សាយដំណឹងល្អ ដែលគេបានអញ្ជើញអ្នកមិនទាន់ជឿព្រះឲ្យមកហាក់បីដូចជាការប្រជុំថ្វាយបង្គំព្រះ "ធម្មតា" នៅក្នុងព្រះវិហារ ហើយ បន្ទាប់មកក៏លបផ្សាយដំណឹងល្អ ក្នុងពេលជាមួយគ្នា ក៏អត់បានផលដែរ ។

នេះជាពេលដែលត្រូវផ្លាស់ប្ដូររបៀបហើយ ។ យើងមិនត្រូវរង់ចាំតែអ្នកស្ដាប់មករកយើងទេ គឺយើងត្រូវទៅរកពួកគេ ។ នេះជារបៀប ដែលព្រះយេស៊ូបានធ្វើ ។ ព្រះអង្គបានយាងទៅកន្លែងណាដែលមានមនុស្សនៅ ។ សព្វថ្ងៃនេះដែលយើងផ្សាយដំណឹងល្អ ប្រាប់ដល់លោកិយឃើញថា ដូចជាមិនសូវស៊ីគ្នាសោះ ។ នៅពេលដែលយើងផ្សាយប្រាប់គេនូវ "សេចក្ដីបែបសេរីនិយមនៃដំណឹងល្អ" យើងតែងតែសង្កេតឃើញថាមានភាពគ្រអឺតគ្រទម ឬក៏បញ្ចូល

ការបង្រៀនផ្នែក សាសនាណាមួយ ។ យើងជាគ្រីស្ទបរិស័ទ សម្រេចឲ្យដល់ទិស ដៅនៃសេចក្តីត្រូវការដល់មនុស្សទាំងអស់ក្នុងលោកិយនេះឡើយ ។ យុវជនជា អំបិល ត្រូវការចេញទៅក្នុងលោកិយនេះ ។ យុវជនគ្រីស្ទបរិស័ទ ត្រូវមានសិទ្ធិ ក្នុងការពុពីមិត្តភក្តិរបស់ខ្លួន ដោយការជួបជុំគ្នា ដើម្បីឆ្លើយតបទៅនឹងសេចក្តី ត្រូវការដ៏ពិត ប្រាកដរបស់សហគមន៍ មិនថាឡើយការងារនោះជាការថែរក្សា បរិស្ថាន ជួយអ្នកជំងឺអេដស៍ ជួយដោះទុក្ខក្នុងការងារសង្គ្រោះបន្ទាន់ ឬ ក៏បំរើអ្នក ក្រីក្រ ឬ អ្នកដែលគ្មានទីជំរក ។ តាមរយៈអ្វីដែលអាចជួយបាន និង ពន្ធកិច្ច ដែលស្របតាមព្រះគម្ពីរ យុវជនអាចមានឥទ្ធិពលលើមិត្តភក្តិរបស់គេ ដោយការ បំរើធម្មតាជាជាងការខំបង្កើតកម្មវិធីផ្សេងៗ ។

ការជំរុញលើកទឹកចិត្តផ្សេងទៀតដល់យុវជនគ្រីស្ទបរិស័ទកម្ពុជា គឺ បង្កើនសុពលភាព(យកជាការបាន) ផ្នែកទេវសាស្ត្រ និង យល់ពីជីវិតក្នុង លោកិយនេះ ។ ចំពោះមនុស្សជាច្រើនគេយល់ថា "ជីវិតក្នុងលោក" គឺជាកន្លែង ដែលគេអាចរាំវែក រកស្រី ផឹកស៊ី លេងល្បែងស៊ីសង ការជក់គ្រឿងញៀន ។ ក្រុមជំនុំកម្ពុជាជាច្រើន ដែលជាគ្រីស្ទបរិស័ទចាស់ចិត្ត ចាស់គំនិត ផ្នែកព្រលឹង វិញ្ញាណ គឺអស់អ្នកដែលមិនផឹកស៊ីស្រីញីអូនបង (លេងស្រី, ថ្នាំញៀន និង រាំវែក) ។ បើសិនអ្នកកាត់ផ្តាច់ប្រការទាំងនោះ ចេញពីជីវិតរបស់អ្នក អ៊ីចឹងដោយ សារតែរង្វង់ នៃគ្រីស្ទបរិស័ទដែលនៅហ៊ុំព័ទ្ធនោះ លោកអ្នកអាចមកដល់ចំណុច នេះបាន ។ ឥទ្ធិពលពីពុទ្ធសាសនា និង ពួកបេសកជនបរទេសរបស់យើងខ្លះ ដែលប្រកាន់ គំនិតអភិរក្សនោះ បានគាំទ្រគំនិតដែលគ្មានផលល្អនេះ ។

នៅក្នុងករណីជាច្រើន បានមើលរំលងអំពើបាបនៅក្នុងចិត្ត ។ នៅខណៈ ដែលអំពើបាប ដែលមើលឃើញត្រូវបានគេសំអាតចេញ ការថ្កោលទោស វាយ ប្រពន្ធ សំអប់ ប្រកាន់ពូជសាសន៍ ការរើសអើងចំពោះស្ត្រីភេទ ការច្រណែន ឈ្នានីស ការត្រួតត្រា និង ស្រេកឃ្លានអំណាច បន្តសម្ងំនៅក្នុងចិត្តទៅវិញ ។ តើ មានអ្វីកើតឡើង ដែលថាយើងត្រូវញែកខ្លួនជាបរិសុទ្ធចេញពីផ្នត់គំនិតលោកិយ។ (រ៉ូម ១២:២) យើងអាចយល់បានពីរបៀបផ្លាស់ប្រែ ដោយគំនិតបានកែជាថ្មីឡើង នោះ ជាការចាំបាច់ដើម្បីឲ្យក្លាយដូចជាព្រះគ្រីស្ទ ដែលល្អស្រួលទទួល ហើយ គ្រប់លក្ខណ៍ផង ។

មានមនុស្សតិចតួចណាស់ ដែលទាក់ទងផ្ទាល់ទៅនឹងលោកិយ ដូចព្រះយេស៊ូបានធ្វើ ។ ភាគច្រើនគេប្រកាន់យកទេវវិទ្យាមួយ ដែលកាត់ខ្លួនចេញពីលោកិយ ។ តាមពិត "លោកិយ" គឺជា "គតិលោក" គំនិត និង ប្រព័ន្ធឲ្យតម្លៃដែលផ្ទុយនឹងតម្លៃនៃនគរព្រះ ។ គឺគ្មាន កន្លែងណាសោះសំរាប់ព្រះជាម្ចាស់នៅក្នុងប្រព័ន្ធនេះឡើយ ។ មនុស្សត្រូវបានគេលើកតម្កើងជាជាងព្រះជាម្ចាស់ ។ ស៊ីផឹកល្បែងស៊ីសង ស្រីញី ជាដើម ។ល។ គឺគ្រាន់តែជាសញ្ញា ដែលបានសង្កេតឃើញនៅក្នុងមនុស្ស ដែលមានគតិលោកបែប "លោកិយ" ។ ការលើកទឹកចិត្តនៅចំណុចនេះ ចំពោះយុវជនមិនត្រូវដកថយពីលោកិយឡើយ តែផ្ទុយទៅវិញត្រូវផ្សាភ្ជាប់នឹងលោកិយ ដូចព្រះយេស៊ូបានធ្វើ ។ ព្រះយេស៊ូត្រូវបានទទួលស្គាល់ពីពួកអ្នកមានបាបថាព្រះអង្គបានឆ្លើយតបនឹងសេចក្តីត្រូវការរបស់គេ ។ យុវជនគ្រីស្ទ បរិស័ទកម្ពុជាត្រូវការរៀនពីរបៀបក្លាយជាអំបិលពិតប្រាកដ និង ពន្លឺពិតប្រាកដ រស់នៅក្នុងលោកិយ ដែលមិនត្រូវឲ្យឆ្លងនូវប្រព័ន្ធឲ្យតម្លៃរបស់លោកិយឡើយ ។ យើងជាសិស្សត្រូវការបង្កើតសិស្ស "ដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ" ។ គឺថាយើងត្រូវចងចាំនៅក្នុងចិត្ត នូវខគម្ពីរម៉ាថាយ ២៨ ជាពិសេសនៅត្រង់ខ ដែលថា ចូរបង្រៀនគេគ្រប់យ៉ាងដើម្បីឲ្យស្តាប់តាមនូវអ្វី ដែលខ្ញុំបង្គាប់មកអ្នករាល់គ្នា"។ ព្រះយេស៊ូបង្ហាញដល់សិស្សរបស់ទ្រង់ពីរបៀបរស់នៅលើលោកិយទៅគ្រប់ផ្នែកទាំងអស់ ។ នៅក្នុងការបង្កើតសិស្ស គឺធ្វើហួស ពីការដែលគ្រាន់តែអង្គុយជាមួយយុវជន និង ការរៀនព្រះគម្ពីរតាមក្បួន គឺវាទាមទារឲ្យយើងបង្រៀនគេឲ្យចេះពីរបៀបបកស្រាយ "ពីប្រព័ន្ធលោកិយនេះ" ហើយនិង ពីរបៀបរស់នៅក្នុងលោកិយ ដែលប្រកបដោយជោគជ័យនៅគ្រប់ផ្នែកនៃការរស់នៅដំណើរជីវិតរស់នៅ ការចែចង់ស្រី ជីវិតរស់នៅក្នុងគ្រួសារគ្រីស្ទបរិស័ទឆ្លើយតបទៅនឹង បញ្ហាសង្គមចេះថែទាំ សំចៃប្រាក់កាស ជាពលរដ្ឋល្អត្រឹមត្រូវ ។ល។

មានការភាន់ច្រឡំកាន់តែខ្លាំងថែមទៀត ក្នុងចំណោមយុវជនអំពីតម្លៃនៃតួនាទី ដែលគេជ្រើសរើសយកពួកគេជាច្រើនទទួល ការបង្រៀនថា ការត្រាស់ហៅរបស់ព្រះដែលសំខាន់ជាងគេនោះគឺ គ្រូគង្វាល បេសកជន អ្នកធ្វើការពេញពេលក្នុងព្រះវិហារ ឬ ក៏ជាបុគ្គលិកនៅក្នុងអង្គការគ្រីស្ទបរិស័ទក្រៅរដ្ឋាភិបាល ។ ដូច្នេះមិនថាឡើយ "ការត្រាស់ហៅ" ឬ មិនត្រាស់ហៅនោះឡើយ

គឺពួកគេដេញតាមរកធ្វើការងារនោះ ដោយគ្មានទិសដៅច្បាស់លាស់ ។ ការត្រាស់ហៅ ដែលសំខាន់ជាងគេនោះ មិនមែនក្លាយជាគ្រូគង្វាលនោះទេ តែវាជាការប្រើអំណោយទាន និង ទេព្យកោសល្យ ដែលព្រះជាម្ចាស់បានត្រាស់ហៅឲ្យមកបំរើព្រះអង្គ ។ បើព្រះត្រាស់ហៅយុវជនម្នាក់ឲ្យធ្វើជាទាហាន គាត់ត្រូវតែធ្វើទាហាន ។ បើព្រះត្រាស់ហៅឲ្យធ្វើជាអ្នកជំនួញ គេត្រូវតែធ្វើការនោះ ។ ព្រះបានហៅមនុស្សឲ្យមកមានវិជ្ជាជីវៈគ្រប់ជ្រុងទាំងអស់នៃការរស់នៅ ដើម្បីឲ្យពួកជំនុំក្លាយជាអំបិល និង ពន្លឺ ដែលបានរាយគ្រប់ទីកន្លែង ។ បុគ្គលិកគ្រីស្ទបរិស័ទពេញពេល គឺគ្មានតម្លៃ លើសពីគ្រីស្ទបរិស័ទធម្មតា ដែលរស់នៅក្នុងជំនឿរបស់ខ្លួន ឋានៈជាវេជ្ជបណ្ឌិត មេធាវី អ្នកកាសែត ទន្តពេទ្យ មេព្រៃ អ្នកស្រាវជ្រាវផ្នែកធរណីសាស្ត្រ អ្នកជំនួញ ។ល។ យុវជនគ្រីស្ទបរិស័ទកម្ពុជាត្រូវយល់ពីតម្លៃតួនាទី នៅខាងក្រៅក្រុមជំនុំ ដើម្បីបោះជំហានចូលទៅគ្រប់ស្រទាប់ក្នុងសង្គម ដើម្បីធ្វើជាអំបិល និង ពន្លឺ ។ ទាំងយ៉ូសែប និង ដានីយ៉ែល មិនមែនជាគ្រូគង្វាលឯណា ប៉ុន្តែគេបំផ្លាស់បំប្រែ សង្គមពីខាងក្នុងមកវិញបាន ។ យុវជនគ្រីស្ទបរិស័ទកម្ពុជា ទាំងពីរភេទដែលបានប្រឡូកចូលទៅក្នុងប្រព័ន្ធជាអ្នកមានអាជីព និង មិនគ្រាន់តែទទួលបានការធ្វើទី បន្ទាល់យ៉ាងងាយប៉ុណ្ណោះទេ តែអាចនឹងមានប្រសិទ្ធិភាពទៀតផង ក្នុងការកែប្រែសង្គម ដែលហុចលទ្ធផលឲ្យសង្គមកម្ពុជា បានចូលក្នុងនគរព្រះជាម្ចាស់មួយផ្នែក ធំ គ្រាន់បើជាងពីមុន ដែលការងារនេះកាន់តែធ្វើឡើងជារឿយៗ ក្រុមជំនុំខ្មែរកាន់តែបានធ្វើការដ៏មានប្រសិទ្ធិភាពជាមួយព្រះយេស៊ូ ដើម្បី "ឲ្យបានផ្សះផ្សាគ្រប់ទាំងអស់ឲ្យជានឹងព្រះអង្គទ្រង់" -មានន័យថាទាំងព្រលឹង និង គ្រប់ព្រព័ន្ធក្នុង លោកផងដែរ (កូលុស ១:១៩,២០) ។ តើការនេះវាធ្ងន់ពេក សំរាប់យុវជនគ្រីស្ទ បរិស័ទកម្ពុជាមែនទេ? មិនមែនជាការលំបាកសោះឡើយ ។

ពួកគេមានចិត្ត គំនិត ហើយនិងមានសក្តានុពល ។ មិនមែនដូចជាឪពុកខាងជំនឿរបស់គេខ្លះ ដែលប្រកាន់ជំហរតឹងរឹងពេក ។ តែយុវជនអាចប្រែប្រួលបាន ពួកគេចាប់អារម្មណ៍ក្នុងការរួបរួមមានបញ្ហាតិចតួចប៉ុណ្ណោះ ក្នុងការធ្វើស្របគ្នាជាមួយបរទេស និង ប្រើទស្សនៈទូលំទូលាយជាច្រើនជាងអស់លោកទាំងនោះ។ យុវជនគ្រីស្ទបរិស័ទកម្ពុជាជំនាន់នេះ ពិតជាមានឥទ្ធិពលលើប្រទេសនេះមែន ។ ប៉ុន្តែភាគច្រើន វាអាស្រ័យលើការនាំផ្លូវបែបណា ការបង្រៀនបែបណា

និង ការលើកទឹកចិត្តបែបណា ដែលអ្នកដឹកនាំក្រុមជំនុំខ្មែរ ត្រូវផ្តល់ឲ្យពួកគេ ក៏មិនខុសគ្នា នឹងការនាំផ្លូវបែបណាមួយដែលសហគមន៍គ្រីស្ទបរិស័ទ មកពីក្រៅប្រទេសត្រូវ ផ្តល់ឲ្យយុវជន និង អ្នកដឹកនាំគ្រីស្ទបរិស័ទថ្នាក់ជាតិផងដែរនោះ ។ វាមានច្រើនវិធីណាស់ វាស្រេចតែយើងទេ ។ ដូច្នេះសូមយើងឈប់មួយភ្លែត ដើម្បីគិត ពិចារណាពីស្ថានភាពនៃយុវជនគ្រីស្ទបរិស័ទខ្មែរ ។ តើនរណាជាអ្នកដើរជាមួយគេ បង្រៀនគេ ដើម្បីផ្តួចផ្តើម ហើយនិងប្រើគំនិតច្នៃប្រឌិតរបស់គេ ដើម្បីលើកយកការសម្រេចចិត្តថ្មីៗ ដែលក្រុមជំនុំនឹងជួបប្រទះនោះ?

HONEYCOMB 1/1 (July 2000): 68–72

# Meet Samoeun Intal

*UON Seila*



*Mrs. Samoeun Intal*

My father was a favorite son to his mom and family. His mother sent him to the temple to become a monk. But he left the monkhood and migrated to Vietnam to enlist as a soldier, where he was trained by the French military. Then he returned back to serve Cambodia. From there he was sent to fight in World War II. As a soldier, my father kept moving from one place to another to train soldiers.

I was the youngest of six children in my family. Whenever my father traveled about, I was the one who always traveled with him. On one occasion I attended a soldier's funeral and saw a military parade to honor the dead. Many people and high-ranking officials attended the funeral. My heart was so thrilled at this spectacle that I wanted to became a soldier to use my life in a valuable way. I'll never forget what my father told me: "Life is more precious than anything else. If you have everything and don't have life, everything is nothing."

In 1975, when the Khmer Rouge gradually surrounded Phnom Penh (the country was so dark by war that I wished to get away at that time), a family friend introduced me to a young Filipino who became my friend. He worked as an aircraft mechanic. I went with him to Kampong Som during the Khmer New Year but we never returned back to Phnom Penh as Cambodia fell to the Khmer Rouge. We fled to Thailand by boat with a lot of foreigners. In Thailand I married him and then moved on to the Philippines. When I first arrived there, I began to ask myself: "How will I use this precious gift called life?" One day I felt a strong call from the Lord to serve other precious lives by sharing with them the hope I had in the Lord Jesus.

My first contact with Christianity had been in a private English class in Cambodia during the early 70's when I was in junior high school. One day a girl I did not know came into my class and asked if she could sit in the vacant seat next to me. I had never seen her before, but I didn't object. She began to tell me about Jesus, his power and who he was. Although I understood little of what she said, I was interested and a seed was planted. I never saw that girl again.

In 1976, a year after coming to the Philippines, while studying English I began to feel lonely and detached. I longed for someone who really cared, for some real love, like the unconditional type of love some people receive from their parents. I had yet to know anything close to real love. The people in the world didn't care. They only cared about themselves. If you wanted to get their attention you had to have something to offer

them, not like the loving parents who always gave without expecting much in return.

During this lonely and depressing time, I watched a television evangelist preaching the gospel, but could only understand some of what he said. One evening in my English class my teacher, who was a missionary with Summer Institute of Linguistics, told me about a Khmer woman who worked for the Far East Broadcasting Company. At the same time, my teacher told her about me. This lady reached me and I went to visit her at the FEBC headquarters.

She shared for over an hour the good news of Jesus' work on the cross for the forgiveness of sins. But once again I understood little. She asked me if I realized that I was a sinner. This infuriated me. How could she presume anything about me? She didn't know me. She didn't know that our parents were devoted Buddhists who taught us always to do good! She then turned in the Bible to Romans 3:23 which read, "All have sinned and come short of the glory of God." That scripture penetrated to the depths of my heart, and I began to question myself. Am I clean, holy, and righteous? I thought about it for a while and somehow I couldn't say that I was really righteous or sinless. I had to acknowledge that I was a sinner of sorts. So right there in that office, with the other Khmer woman, I called on the name of the Lord for forgiveness of my sins. Somehow, I know very clearly that I would come back and work for that radio station.

God was carefully nurturing the seed he had planted in my heart, and as it grew I began to get a clear picture of God's plan for Cambodia. Over the next seventeen years that seed blossomed into a mature vision for my people that included establishing a facility inside Cambodia.

Cambodia was a prioritized nation from which to apply for immigration to a third country such as the United States, Australia, Canada, or France. But I turned down my application for immigration to one of these countries because I wanted to serve Cambodia instead of going abroad.

FEBC started Khmer language shortwave broadcasts from the Philippines in 1957. My own work with radio began nearly two decades later as a language assistant. My main responsibility was to edit scripts written by missionaries who had been forced to flee Cambodia when the Khmer Rouge came to power. These scripts were then broadcast from the Philippines into Cambodia. After four years of editing and broadcasting, I began to produce script myself. Although I had been able to escape physically from Cambodia, I could not escape mentally and emotionally from what my brothers and sisters were experiencing there during the twenty-five years of war. Although this could help me write heart-to-heart, it was often too painful and I wanted to quit. God always helped me to see what great opportunities there were in the radio ministry. This helped carry me through the difficult times.

In 1993, the Cambodian government granted FEBC permission to open an office and studio in Phnom Penh. When we first applied for a permission we did not volunteer our identity as Christians. Later that same year, our family pulled up stakes and relocated to Phnom Penh in order to train Khmer nationals to produce programs inside the country. But we still broadcast from the Philippines.

In 1995 we made clear to the government our identity as Christians. We established good contacts with the government and gained favor from them. FEBC submitted an application for setting up a radio station inside the country. The government offered us a station, but implementation of that offer was delayed due to the military clashes of July 1997. So we proceeded to bring in equipment to set up an AM radio station.

At last our radio equipment arrived at the port, but we could not clear customs to bring it in. We went back and forth with the Ministries of Information, Telecommunication, and Finance, but they said the government was not allowed to license a private AM station. After long negotiations, the government hinted that they wanted to have our AM equipment in exchange for granting us an FM frequency. Finally we yielded and agreed to apply for an FM frequency.

There have been further delays while we wait for the government to assign us a FM frequency. We want a high frequency, and they would rather give us a low one. We need God's wisdom to deal with such negotiations. We prayed to God for our patience to wait for God's timing on that issue. The Lord is good. He strengthens me when I felt weak.

One day I felt so frustrated. I asked myself, "Why did I choose radio ministry?" I sat on the porch of my office and watched a coconut palm tree moving. A question arose in my mind: "What makes the coconut palm tree move back and forth? The WIND! The wind is powerful. How much more powerful is the word of God in the air?" The word of God can prove itself strong if we put it on the air. It has power that can change lives. Life is very important!

Once the FM station goes on air, it will broadcast nine hours per day to a potential audience of six million people. We plan to broadcast in English in the future to help meet the English educational needs of this generation. After building trust with the government we also want to broadcast in Chinese and ethnic tribal languages in Rattakiri and Stung Treng.

We plan to set up substations in Kompong Thom, Kompong Chhang (working with Rev. K. P. Chhon), and other provinces as the Lord's will and blessing us. Please remember us in your prayers, and ask for God's provision as we serve Him.

*[Editor's note: Two days before this journal went to the printer, Rubledo and Samoeun's oldest son Abraham drowned in a tragic accident at Kampong Som. We dedicate this first issue of* Honeycomb *to Abraham's memory, and encourage our readers to remember the Intal family in their prayers.]*

សំណុំទឹកឃ្មុំ ១/១ (កក្កដា ២០០០): ៧៣-៧៨

# ការជួបជាមួយ លោកស្រី សាមឿន អ៊ីនតាល់

ដោយលោក អ៊ួន សិលា

*******



*លោកស្រី សាមឿន អ៊ីនតាល់*

ឪពុករបស់ខ្ញុំ ជាកូនដែលម្ដាយគាត់ស្រឡាញ់ពេញចិត្ត ហើយម្ដាយរបស់គាត់បានឲ្យគាត់ទៅបួសជាលោកសង្ឃ ដើម្បីសងគុណម្ដាយ ។ ប៉ុន្តែឪពុករបស់ខ្ញុំបានលាចាកសិក្ខាបទ ហើយបានរត់ទៅប្រទេសវៀតណាម ដើម្បីចូលធ្វើជាទាហាននៅទីនោះ គាត់ទទួលនូវការហ្វឹកហ្វឺន ពីកងយោធាបារាំង រួចគាត់ក៏បានវិលមកបំរើប្រទេសជាតិវិញ ។ គេបានបញ្ជូនគាត់ទៅប្រយុទ្ធក្នុងសង្គ្រាមលោកលើកទី ២ ។ ដោយសារតែឪពុកខ្ញុំជាទាហាន គាត់ផ្លាស់ពីកន្លែងមួយទៅកន្លែងមួយទៀត ដើម្បីហ្វឹកហ្វឺនដល់ពួកទាហាន ។

ខ្ញុំមានបងប្អូន ៦ នាក់ ហើយខ្ញុំជាប្អូនគេបង្អស់នៅក្នុងគ្រួសារ ។ នៅពេលដែលឪពុករបស់ខ្ញុំធ្វើដំណើរទៅណាមកណា គាត់តែងយកខ្ញុំទៅជាមួយ

គាត់ជានិច្ច ។ ខ្ញុំនៅចាំបាន ពេលមួយនោះខ្ញុំបានចូលរួមក្នុងពិធីបុណ្យសពរបស់ទាហានម្នាក់ ហើយខ្ញុំបានឃើញដំណើរហែរក្បួនរបស់ទាហាន ដើម្បីសម្តែងការគោរពដល់អ្នកដែលបានពលីជីវិតនោះ ។ មានមនុស្សជាច្រើន និង នាយទាហានដែលមាន ឋានន្តរសក្តិខ្ពង់ខ្ពស់ក៏បានចូលរួមដែរ ។ ខ្ញុំមានសេចក្តីរំភើបក្នុងចិត្តជាខ្លាំងចំពោះទិដ្ឋភាពនោះ ដែលធ្វើឲ្យខ្ញុំចង់ធ្វើជាទាហាន គឺចង់ប្រើជីវិតរបស់ខ្ញុំក្នុងផ្លូវមួយ ដែលមានតម្លៃបំផុតនោះ ។ ខ្ញុំនៅចាំមិនភ្លេចពីសំដីរបស់ឪពុករបស់ខ្ញុំបាននិយាយ មកកាន់ខ្ញុំថា : "ជីវិតមានតម្លៃលើសអ្វីៗទាំងអស់" ។ បើកូនមានអ្វីគ្រប់យ៉ាង ហើយគ្មានជីវិតនោះ គ្រប់យ៉ាងនឹងឥតប្រយោជន៍ទទេ" ។

នៅក្នុងឆ្នាំ ១៩៧៥ នៅពេលដែលពួកខ្មែរក្រហមហ៊ុំព័ទ្ធទីក្រុង ភ្នំពេញបន្តិចម្តងៗ ។ ខ្ញុំមានបំណងចង់ចាកចេញពីភាពងងឹតនៃប្រទេសជាតិ ពេលនោះខ្ញុំបានត្រូវញាតិមិត្តគ្រួសារ ណែនាំឲ្យស្គាល់បុរសម្នាក់ ដែលជាជនជាតិហ្វីលីពីនជាអ្នកជួសជុលយន្តហោះ ខ្ញុំក៏បានទៅជាគាត់ ក្នុងរយៈពេលចូលឆ្នាំថ្មី តែយើងមិនអាចវិលត្រលប់មកភ្នំពេញបានទេ ដោយប្រទេសខ្មែរបានធ្លាក់ទៅក្នុងកណ្តាប់ដៃខ្មែរក្រហម ។ យើងក៏បានចាកចេញពីកំពង់សោម ទៅប្រទេសថៃ ជាមួយជនជាតិបរទេសមួយចំនួនធំ តាមផ្លូវទឹក ។ នៅក្នុងប្រទេសថៃ ខ្ញុំបានរៀបការជាមួយមិត្តហ្វីលីពីន រួចបន្ទាប់មក ក៏មករស់នៅក្នុងប្រទេសហ្វីលីពីនវិញ ។ នៅពេលដែលខ្ញុំទៅដល់ប្រទេសភីលីពីន ដំបូងខ្ញុំចាប់ផ្តើមសួរខ្លួនឯងថា៖ "តើខ្ញុំត្រូវប្រើអំណោយដ៏មានតម្លៃ ដែលគេហៅថាជីវិតនេះ ដោយរបៀបណា?" ថ្ងៃមួយខ្ញុំបានដឹងយ៉ាងជាក់ច្បាស់ថា ព្រះជាម្ចាស់ត្រាស់ហៅខ្ញុំ ឲ្យបំរើជីវិតដ៏មានតម្លៃ ដទៃទៀតដោយការផ្សាយពីសេចក្តីសង្ឃឹម ដែលខ្ញុំមានក្នុងព្រះជាម្ចាស់យេស៊ូ ចែកដល់ពួកគេ ។

ខ្ញុំបានដឹងពុពីជំនឿគ្រីស្ទបរិស័ទដំបូងបង្អស់ នោះគឺនៅពេលដែល ខ្ញុំកំពុងតែរៀនភាសាអង់គ្លេសនៅក្នុងសាលាឯកជនមួយនៅក្នុងស្រុកខ្មែរកាលពីឆ្នាំ ១៩៧៣ កាលនោះខ្ញុំនៅរៀនអនុវិទ្យាល័យនៅឡើយ ។ ថ្ងៃមួយនោះ មានយុវនារីម្នាក់ ដែលខ្ញុំមិនដែលស្គាល់សោះ បានមកថ្នាក់រៀនរបស់ខ្ញុំ ហើយបានសួរខ្ញុំថាតើនាងអាចចូលអង្គុយនៅក្នុងកន្លែងទំនេរនៅជាប់នឹងខ្ញុំបានទេ ។ ខ្ញុំមិនដែលបានជួបមិនដែលបានឃើញនាងពីមុនមកសោះ ប៉ុន្តែខ្ញុំមិនបានប្រកែកអ្វីឡើយ ។ នាងក៏ចូលមកអង្គុយ ហើយចាប់ផ្តើមនិយាយប្រាប់ខ្ញុំពីព្រះយេស៊ូ ពីព្រះចេស្តា

និង ពីបុគ្គលិកលក្ខណៈរបស់ព្រះអង្គ ។ ទោះបីជាខ្ញុំមិនយល់អ្វីបន្តិចសោះ នូវអ្វីដែលនាងព្យាយាមប្រាប់ខ្ញុំក៏ដោយ ខ្ញុំមានការចាប់អារម្មណ៍ ហើយពេលនោះគ្រាប់ពូជមួយគ្រាប់បានដាំនៅក្នុងចិត្តរបស់ខ្ញុំ ។ តាំងពីនោះមកខ្ញុំមិនបានជួបនាងម្នាក់នោះឡើយ ។

នៅក្នុងឆ្នាំ ១៩៧៦ មួយឆ្នាំក្រោយពីខ្ញុំបានមកដល់ប្រទេស ភីលីពីន នៅដែលខ្ញុំកំពុងរៀនភាសាអង់គ្លេស ខ្ញុំចាប់ផ្ដើមមានអារម្មណ៍ធុញថប់ ត្រម៉ង់ត្រម៉ោចឯកោម្នាក់ឯង ។ ខ្ញុំចង់ឲ្យមានអ្នកណាម្នាក់ពិតជាថែរក្សា ផ្ដល់សេចក្ដីស្រឡាញ់ពិតប្រាកដ គឺជាសេចក្ដីស្រឡាញ់ឥតលក្ខ័ណ ដែលគេបានទទួលពីឪពុកម្ដាយ ។ ខ្ញុំមិនទាន់បានស្គាល់នូវសេចក្ដីស្រឡាញ់ ដែលដូចនឹងសេចក្ដីស្រឡាញ់ពិតប្រាកដនោះនៅឡើយ ។ មនុស្សនៅក្នុងលោកីយ៍នេះ គេមិនខ្វល់អ្វីឡើយ ចំពោះសេចក្ដីស្រឡាញ់ពិតនោះ ។ គេខ្វល់ខ្វាយតែពីខ្លួនគេផ្ទាល់ ។ បើយើងចង់ឲ្យគេយកចិត្តទុកដាក់នឹងយើង ទាល់តែយើងមានអ្វីឲ្យគេ ទើបគេយកចិត្តទុកដាក់នឹងយើង មិនដូចជាការស្រឡាញ់របស់ឪពុកម្ដាយ ដែលផ្ដល់មកដោយគ្មានសង្ឃឹមចង់បានការតបស្នងអ្វីទាំងអស់ ។

នៅក្នុងកំឡុងពេលដែលខ្ញុំនៅឯកោ និង ធ្លាក់ទឹកចិត្ត ខ្ញុំបានបើកទូរទស្សន៍ មើលកម្មវិធីផ្សាយដំណឹងល្អ ប៉ុន្តែខ្ញុំយល់បានតិចតួចណាស់នូវដែលអ្នកផ្សាយដំណឹងល្អនោះបាននិយាយ ។ នៅល្ងាចមួយនៅក្នុងថ្នាក់រៀនភាសាអង់គ្លេស លោកគ្រូរបស់ខ្ញុំ ដែលជាបេសកជនធ្វើការនៅក្នុង Summer Institute of Linguistics បានប្រាប់ខ្ញុំថា មានស្ត្រីខ្មែរម្នាក់ធ្វើការនៅប៉ុស្តិ៍វិទ្យុ FEBC ។ នៅពេលជាមួយគ្នានោះ លោកគ្រូរបស់ខ្ញុំបានប្រាប់ដល់ស្ត្រីម្នាក់នោះអំពីរូបខ្ញុំ ដល់គាត់ម្នាក់នោះដែរ ។ ស្ត្រីម្នាក់នោះបានទាក់ទងខ្ញុំ ហើយខ្ញុំក៏បានទៅលេងគាត់ដល់ការិយាល័យ FEBC ។

គាត់បានជជែកជាមួយខ្ញុំប្រហែលមួយម៉ោង អំពីដំណឹងល្អនៃព្រះយេស៊ូដែលព្រះអង្គបានធ្វើ នៅលើឈើឆ្កាង ដើម្បីអត់ទោសបាប ។ តែម្ដងនេះខ្ញុំនៅតែយល់បានបន្តិចបន្តួច ។ គាត់បានសួរខ្ញុំថា តើខ្ញុំដឹងថាខ្ញុំជាមនុស្សមានបាបដែរឬទេ សំណួរបែបនេះធ្វើឲ្យខ្ញុំខឹងនឹងគាត់ ។ យ៉ាងម៉េចបានជាគាត់នេះអាចសន្និដ្ឋាន អំពីខ្ញុំបាន ? គាត់មិនដែលស្គាល់ខ្ញុំទេសោះ ។ គាត់មិនដឹងថា ឪពុកម្ដាយរបស់ខ្ញុំជាអ្នកកាន់សាសនាព្រះពុទ្ធដ៏ស្មោះស្ម័គ្រ ដែលតែងតែបង្រៀនដល់ខ្ញុំឲ្យធ្វើតែអំពើ

ល្អ ! ។ ក្រោយមកគាត់បានបើកព្រះគម្ពីរត្រង់ រ៉ូម ៣:២៣ ដែលចែងថា "គ្រប់គ្នាបានធ្វើបាប ហើយខ្វះមិនដល់សិរីល្អនៃព្រះ" ។ បទគម្ពីរនោះបានជ្រាបចូលទៅក្នុងជម្រៅចិត្តរបស់ខ្ញុំ ហើយខ្ញុំចាប់ផ្តើមសួរខ្លួនឯងថា តើខ្ញុំស្អាតបរិសុទ្ធ ឬសុចរិតឬទេ ? ខ្ញុំបានគិតមួយស្របក់ ហើយខ្ញុំមិនអាចនិយាយអ្វីបានសោះ ដែលថាខ្ញុំពិតជាសុចរិត ឬ គ្មានបាបសោះនោះឡើយ ។ ខ្ញុំព្រមទទួលស្គាល់ថា ខ្ញុំជាមនុស្សមានបាប ។ ស្រាប់តែពេលនោះឯង ខ្ញុំព្រមថ្វាយខ្លួនដល់ព្រះអម្ចាស់ជាមួយនឹងស្ត្រីម្នាក់នោះ ដោយយាងព្រះអង្គមកក្នុងចិត្ត ឲ្យព្រះអង្គអត់ទោសបាបឲ្យខ្ញុំ ។ ទោះជាយ៉ាងណាក៏ដោយ ខ្ញុំដឹងយ៉ាងច្បាស់ថា ខ្ញុំនឹងត្រលប់មកវិញនឹងធ្វើការនៅក្នុងស្ថាប័នវិទ្យុ ។

ព្រះជាម្ចាស់បានថែគ្រាប់ពូជ ដែលបានដាំក្នុងចិត្តរបស់ខ្ញុំដោយប្រុងប្រយ័ត្ន ហើយនៅពេលដែលគ្រាប់ពូជនោះដុះឡើង ខ្ញុំបានដឹងច្បាស់ថា ជាផែនការរបស់ព្រះជាម្ចាស់សំរាប់ប្រទេសកម្ពុជា ។ អស់រយៈពេល ១៧ ឆ្នាំ ក្រោយមកគ្រាប់ពូជនោះបានដុះដាលឡើងជានិមិត្តដ៏ធំមួយ សំរាប់ប្រជាជនរបស់ខ្ញុំ ដែលការនោះគិតទាំងការបើកឲ្យមានការបង្កើតការផ្សាយនៅក្នុងប្រទេសកម្ពុជា ។

ប្រទេសកម្ពុជា គឺជាប្រទេសមានអាទិភាពជាងប្រទេសនានា ក្នុងការដាក់ពាក្យទៅសុំការតាំងទីលំនៅក្នុងប្រទេសទី ៣ ដូចជាប្រទេសអាមេរិក អូស្ត្រាលី កាណាដា ឬ ក៏ប្រទេសបារាំង ។ ប៉ុន្តែខ្ញុំបានបោះបង់ចោលចំពោះការដាក់ពាក្យសុំទៅចូលទៅតាំងទីលំនៅក្នុងប្រទេសទាំងនោះ ពីព្រោះខ្ញុំចង់ទៅបំរើប្រទេសខ្មែរជាជាងចេញទៅបរទេស ។

FEBC ចាប់ផ្តើមផ្សាយជាភាសាខ្មែរ តាមរលកធាតុអាកាសខ្លីពីប្រទេសភីលីពីន នៅក្នុងឆ្នាំ ១៩៥៧ ។ ការងាររបស់ខ្ញុំជាមួយវិទ្យុចាប់ផ្តើមជិតពីទសវត្សរ៍ក្នុងឋានៈជាអ្នកជំនួយផ្នែកភាសា ។ ការទទួលខុសត្រូវសំខាន់របស់ខ្ញុំ គឺពិនិត្យមើលអត្ថបទរបស់ពួកបេសកជន ដែលត្រូវពួកខ្មែរក្រហមបង្ខំឲ្យចាកចេញពីប្រទេសខ្មែរ កាលកំឡុងពេលខ្មែរក្រហមកាន់អំណាចនោះ បានសរសេរមកឲ្យយើង ។ អត្ថបទនេះបានផ្សាយមកក្នុងស្រុកខ្មែរ ចេញពីប្រទេសភីលីពីន ។ បន្ទាប់ពីធ្វើការកាត់ត អត្ថបទ និង ការផ្សាយអស់រយៈពេល ៤ ឆ្នាំ ក្រោយមកខ្ញុំក៏ចាប់ផ្តើមផលិតកម្មវិធីនោះ ដោយខ្លួនឯង ។ ទោះបីជាខ្ញុំបានរត់គេចរួចខ្លួនមែនពីប្រទេសកម្ពុជា តែខ្ញុំមិនគេចឲ្យរួចពីការនឹកគិតដល់បងប្អូនប្រុសស្រីរបស់ខ្ញុំ ដែល

ឆ្លងកាត់សង្គ្រាមជាង ២៥ ឆ្នាំ នោះឡើយ ។ ទោះបីជាយ៉ាងណាក៏ដោយ ក៏ការនេះអាចជួយឲ្យខ្ញុំអាចសរសេរ ចេញពីចិត្តរបស់ខ្ញុំ ដែលសម្តែងពីការរងឈឺចាប់ដែលបងប្អូនមាននៅក្នុងស្រុក ខ្ញុំមានការឈឺចាប់ណាស់ ហើយពេលខ្លះ ខ្ញុំចង់ឈប់ពីការងារនេះ ។ ព្រះជាម្ចាស់តែងតែជួយខ្ញុំ ឲ្យឃើញនូវឱកាសដ៏ធំធេងនៅក្នុងព័ន្ធកិច្ចវិទ្យុ ។ ព្រះជួយខ្ញុំឲ្យឆ្លងកាត់នូវការលំបាកជាច្រើនដងច្រើនលើក ។

នៅក្នុងឆ្នាំ ១៩៩៣ រាជរដ្ឋាភិបាលកម្ពុជា បានផ្តល់ឲ្យច្បាប់ដល់ FEBC ដើម្បីឲ្យបើកការិយាល័យ និង បន្ទប់ថតសម្លេងមួយនៅក្នុងទីក្រុង ភ្នំពេញ ។ នៅពេលដែលយើងដាក់ពាក្យសុំច្បាប់ជាលើកដំបូង យើងមិនបង្ហាញពីអត្ត-សញ្ញាណរបស់យើងឲ្យរដ្ឋាភិបាលស្គាល់ថា យើងជាគ្រីស្ទបរិស័ទទេ ។ ក្រោយមកក្នុងឆ្នាំដដែលនោះ គ្រួសាររបស់យើងផ្លាស់ទីលំនៅពី ភីលីពីន មកនៅក្នុងប្រទេសកម្ពុជា នាទីក្រុងភ្នំពេញ ដើម្បីហ្វឹកហ្វឺនជនជាតិខ្មែរ ឲ្យផលិតកម្មវិធីផ្សាយនៅក្នុង ប្រទេស។ ប៉ុន្តែយើងនៅតែផ្សាយចេញពីប្រទេស ភីលីពីន ដដែល ។

នៅក្នុងឆ្នាំ ១៩៩៥ យើងបានបង្ហាញពីអត្តសញ្ញាណរបស់យើងឲ្យរដ្ឋាភិបាលស្គាល់យើងច្បាស់ថា យើងជាគ្រីស្ទបរិស័ទ ។ យើងបានរីតចំណងទាក់ទងដ៏ប្រសើរជាមួយរាជរដ្ឋាភិបាល ។ FEBC បានដាក់ពាក្យសុំបើកស្ថានីយវិទ្យុផ្សាយសម្លេងនៅក្នុងប្រទេស ។ រាជរដ្ឋាភិបាលបានផ្តល់ឲ្យយើងបើកស្ថានីយវិទ្យុមួយ ប៉ុន្តែការផ្តល់ច្បាប់នោះត្រូវអាក់ខាន ដោយសារមានព្រឹត្តិការណ៍ប៉ះទង្គិចគ្នាផ្នែកយោធា កាលពីខែ កក្កដា ១៩៩៧ ។ ដូច្នេះយើងបានចាប់ផ្តើមដំណើរការនាំសម្ភារៈចូលមក ដើម្បីតម្លើងស្ថានីយវិទ្យុ AM ។

ទីបំផុតសម្ភារៈវិទ្យុរបស់យើង បានមកដល់កំពង់ផែ ប៉ុន្តែគយមិនអនុញ្ញាតឲ្យយើងនាំចូលមកឡើយ ដោយមានបញ្ហាខ្លះៗដោះស្រាយមិនរួច ។ យើងបានចុះឡើង ទាក់ទងគ្រប់ក្រសួងដែលពាក់ព័ន្ធ ដូចជាក្រសួងពត៌មានទូរគមនាគមន៍ និង ក្រសួងហិរញ្ញវត្ថុ ប៉ុន្តែរដ្ឋាភិបាលបានប្រាប់យើងថា គេមិនអាចអនុញ្ញាតច្បាប់ឲ្យអាជ្ញាប័ណ្ណឲ្យបើកស្ថានីយវិទ្យុ AM ជាឯកជនឡើយ ។ បន្ទាប់ពីចរចារយ៉ាងយូរ រដ្ឋាភិបាលបានប្រលយពាក្យឲ្យយើងដឹងថា រដ្ឋាភិបាលចង់បានសម្ភារៈស្ថានីយ៍ AM របស់យើង ដើម្បីប្តូរនឹងការផ្តល់ច្បាប់បើកស្ថានីយ៍ FM ។ ទីបំផុតយើងក៏ព្រមប្រគល់ឲ្យ ហើយយល់ព្រមដាក់ពាក្យសុំបើកស្ថានីយ៍ FM ជំនួសវិញ ។

មានការយឺតយ៉ាវយ៉ាងយូរ យើងរង់ចាំរដ្ឋាភិបាលផ្ដល់ស្ថានីយ៍ FM ឲ្យយើង ។ យើងចង់បានកម្លាំងខ្លាំង តែរដ្ឋាភិបាលឲ្យយើងផ្សាយកម្លាំងខ្សោយ ។ យើងត្រូវការប្រាជ្ញាពីព្រះជាម្ចាស់ក្នុងការចរចារបែបហ្នឹង ។ យើងបានអធិស្ឋានឲ្យយើងខ្ញុំមានការអត់ធ្មត់ រង់ចាំពេលរបស់ព្រះជាម្ចាស់ចំពោះការងារនេះ ។ ព្រះអង្គទ្រង់ល្អ ! ព្រះអង្គផ្ដល់កម្លាំងឲ្យខ្ញុំនៅពេលដែលខ្ញុំខ្សោយ ក្រោយមកគេក៏ឲ្យកម្លាំងដ៏ខ្លាំងល្អឲ្យយើង ។

ថ្ងៃមួយខ្ញុំមានអារម្មណ៍ខ្វល់ខ្វាយយ៉ាងខ្លាំង ។ ខ្ញុំបានសួរខ្លួនថា: "ហេតុអ្វីបានជាខ្ញុំជ្រើសរើសព័ន្ធកិច្ចវិទ្យុ ? " ខ្ញុំបានអង្គុយនៅរានហាលនៃការិយាល័យរបស់ខ្ញុំ ហើយខ្ញុំបានសម្លឹងមើលធាងដូងបក់ចុះបក់ឡើង ។ ខ្ញុំឆ្ងល់នៅក្នុងគំនិតរបស់ខ្ញុំ : " តើអ្វីដែលធ្វើឲ្យធាងដូងបក់ចុះបក់ឡើង ? ខ្យល់ ! ខ្យល់មានអំណាចណាស់ ។ តើព្រះបន្ទូលមានអំណាច ចេស្ដា ប៉ុណ្ណាទៅ បើយើងដាក់ព្រះបន្ទូលនោះ ទៅក្នុងខ្យល់ ? " ព្រះបន្ទូលរបស់ព្រះជាម្ចាស់បង្ហាញយ៉ាងច្បាស់ថា នឹងមានអំណាចចេស្ដា បើយើងដាក់ព្រះបន្ទូលនោះបញ្ជូលតាមរលកធាតុអាកាស ។ ព្រះបន្ទូលអាចបំផ្លាស់បំប្រែជីវិត ។ ជីវិតគឺជារបស់សំខាន់បំផុត !

នៅពេលដែលស្ថានីយ៍ FM ចេញផ្សាយ គឺផ្សាយ ៩ ម៉ោង ក្នុងមួយថ្ងៃ កម្លាំងវិទ្យុនោះអាចធ្វើឲ្យមនុស្ស ៦ លាន នាក់ស្ដាប់ឮ យើងមានគម្រោងផែនការផ្សាយជាភាសាអង់គ្លេស នៅថ្ងៃអនាគត ដើម្បីជួយអប់រំផ្នែកភាសាអង់គ្លេសដល់មនុស្សជំនាន់នេះ ។ បន្ទាប់ពីបង្កើនការទុកចិត្តជាមួយរដ្ឋាភិបាលរួចហើយ យើងចង់ផ្សាយជាភាសាចិន និង ភាសាជនជាតិភាគតិចនៅខេត្ត រតនៈគីរី និង ស្ទឹងត្រែង ។

យើងមានផែនការបង្កើតសាខាស្ថានីយ៍ នៅតាមបណ្ដាខេត្តដូចជាខេត្តកំពង់ធំ កំពង់ឆ្នាំង (ធ្វើការជាមួយលោកគ្រូ គង់ ផនធុន ) ហើយនិង បន្តទៅខេត្តផ្សេងៗទៀត តាមតែព្រះទ្រង់ប្រទានពរ និង ដឹកនាំ ។

សូមជួយអធិស្ឋានដល់យើងខ្ញុំ សូមឲ្យព្រះជាម្ចាស់ផ្គត់ផ្គង់យើងខ្ញុំ ក្នុងការដែលយើងបំរើព្រះអង្គ ។

*(សេចក្ដីបន្ថែមរបស់បណ្ណាធិការ: ពីរថ្ងៃមុនព្រឹត្តិប័ត្របានបោះពុម្ព កូនច្បងរបស់លោក រូប៉េដូ និង លោកស្រី សាមឿន អ៊ិនតាល់ ឈ្មោះ អាប្រាហាម បានលង់ទឹកស្លាប់នៅក្នុងឧប្បត្តិហេតុមួយគួរអោយសង្វេគនៅសមុទ្រក្រុងកំពង់សោម ។ យើងសូមឧទ្ទិសការចេញផ្សាយរបស់ព្រឹត្តិប័ត្រសំណុំទឹកឃ្មុំទី១ នេះ ទុកជាការចងចាំដល់អាប្រាហាម ហើយនិងសូមលើកទឹកចិត្តដល់អ្នកអានរបស់យើង នឹកចាំពីគ្រួសារ សាមឿន អ៊ិនតាល់ នៅក្នុងសេចក្ដីអធិស្ឋានរបស់យើងផង ។)*

HONEYCOMB 1/1 (July 2000): 79–84

# Book Review

Davis, John R., *Poles Apart: Contextualizing the Gospel in Asia*, rev. ed. Bangalore, India: Theological Book Trust, 1998. 285 pp.

Reviewed by: *Darell CALDWELL*

*Poles Apart* by John R. Davis should be considered a classic among those who seek to meaningfully and courageously contextualize the gospel in Buddhist Asia. Davis, now retired, generously shares his gleanings of experience as a missionary in Thailand. He has thoughtfully ruminated upon its Theravada Buddhist cultural setting to the extent that he proposes some specific and radical changes to the strategy for missions in this cultural milieu. He also encourages us to own those mistakes made by missionaries in the past, to critique our approach, and then to rethink our strategy from the bottom up. Although the first edition, published in 1993, is decidedly specific to the Thai scene, in the revised edition "the author seeks to make suitable application to the peoples and contexts of the Asian continent. He has also added a new chapter dealing with church structure and leadership in the [Asian] church today."

Despite the large number of monographs written on missions strategy, it is Davis's opinion that evangelicals have yet to appreciate or demand scholarly works on this subject. The need is felt more and more intensely as grassroots missionaries confront the complex folk Buddhism with its admixture of animistic and Hindu concepts. And yet many still minister with some exasperation, whether they be expatriates or national leaders, as they encounter a people seemingly impervious to the "Good News." They have come to realize that it is not enough to know

the concepts of Theravada Buddhism as taught in some classroom; rather one must be able to relate to that specific cultural expression of folk Buddhism and animism which actually is found in the markets, villages, and streets of Asia. Davis has spent over thirty years reflecting upon the actual belief system with the view to solve the crisis of resistance. Thailand remains approximately 99.9% Buddhist.

A poignant illustration of Thailand introduces *Poles Apart.* Most good missionaries would have memorized John 3:16 not only in his heart language but also in the adopted language. He or she may feel encouraged at the friendly smile in response to quoting John 3:16 to his or her new acquaintance. But what has the hearer actually heard? Davis states, "With all due respect to the missionary's enthusiasm, he is in fact communicating unintelligible gobbledygook. Words with contradictory concepts." If we perceive the problem from a Buddhist's perspective, the God who so loved the world "in Buddhist cosmology can mean any number of things, [such as] the sun, moon, stars, members of the royal family, members of the Buddhist priesthood, Hindu mythological gods, special sacred places—or images of Buddha; all use the same designation." From the beginning the recipient hearer is confused because he would never think of using the word "god" (*Pra Jao*) in the exclusive Christian way. Then his confusion is compounded by hearing that this god loves him. To him love connotes weakness, since "all desire, good or bad, in Buddhism is by definition bad—it presupposes relationships and attachments." The goal of the devout Buddhist, of course, is to escape all passion and attachments. The smiling hearer is thinking, "This God lacks something; He is inadequate in Himself." Why else would he love the world and the people in it? Davis continues the illustration showing that at every major point in the most famous verse of all, there is basic and profound misunderstanding. So what are we to do?

In essence, I hear Davis saying: we must do our homework, review the irreducible components of a biblical church, analyze our own culture, avoid cramming our Western context

down the throats of Asians, and respond to the real heart and mind issues of folk Buddhists. This includes knowing one's own culture and the critique of scripture upon it; otherwise we merely import Western or other corrupting cultural values. Equally important is a correct understanding of contextualization without syncretism (covered in chapters 1 & 2). Thai Buddhism, basically eclectic, can accommodate Christ as a "cosmic Christ" in long line of a pantheon, but not as King of kings and Lord of lords.

In chapter 3 Davis boldly tackles the problem of the radically divergent world views, i.e. Western naturalism versus Asian supernaturalism. "In any society which holds a supernaturalistic world view there is an unseen 'other world' all around, above, and below, which pervades everything and which relates to and engages with 'supernatural phenomena', such as inexplicable disease, plagues, ... crisis in families, accidents ... the return of the 'living dead' to cause calamity...." However, he observes further, "Western theologies seem to have no answers to Eastern problems and values...." This lack of understanding is the main reason why "[t]he whole theological package Thai people have been given has only penetrated into their world-view skin-deep." Thus, there remains a critical need to "develop holistic theology and practice where solutions will be found to answer the [real problems] of the 'supernaturalistic' world-view."

To the foregoing discussion in chapter 3, Davis has added in his revised edition valuable material illustrating this daily interaction with the 'other world.' For example, in Southeast Asia the construction of a house entails many elaborate preparations. Various ceremonies are considered essential to ensure the peace and prosperity of the new residents. "First, an astrologer will be consulted to ascertain the most auspicious time for construction and the exact location of the house.... [W]hen the site has been cleared it will be necessary to engage the expertise of a 'ritual specialist'.... [I]f the practitioner is a monk, Pali mantras will be chanted, if a layman, gifts will be offered, sacral water, incense candles and flowers will be placed on the earth...." Several steps remain such as the selection of the correct wood type favorable to

the local spirits (some tree types attract spirits, others less so), the selected trees must be felled in the correct direction, precise depths of the pole holes must be determined according to what the unseen world says, the first hole will receive an offering coin from the ritual specialist, other rituals follow (construction has not yet really begun), with a final step being that "a piece of red and white cloth upon which magical signs have been inscribed" is placed on the first pole. From this example one can see that in everyday life, "folk Buddhists see nothing as 'secular' or unrelated to the unseen world." Davis additionally illustrates by describing the ubiquitous spirit houses and shrines considered as the local spirit-land-lords. Furthermore, above this is another hierarchy of the 'Spirit Lords of the Towns.' Davis has added much new information to his second edition of chapter 3.

Both chapter 4, "Local Theologies," and chapter 5 "The Nature of Suffering" (no serious book on Buddhism could overlook this subject) have been greatly revised and re-researched. For the Buddhist, life is suffering. The only way to escape it is to have right knowledge (enlightenment), that is, to see that suffering "ceases when desire ceases." Chapter 5 in the revised edition lists 68 footnotes. Beginning with chapter 6, the author gives us the beef with insight into how we might contextualize aright. He is most helpful in saying, "All rites, rituals and ceremonies should be carefully examined as potential vehicles for Christian truth."

But the plethora of rituals fall into many categories, beginning with "if not adhered to or neglected, society would regard as 'sin'" to a descending order of importance as perceived by the people. Some ceremonies are directly Buddhist while others are strictly cultural. Having discerned this (no easy process), the missionary may encourage the use of the form of the ceremony as a container into which new content is poured. This Davis calls "reloading" the local ritual with Christian content and meaning. For example, some Thai Christians have taken the Lotus Float ceremonial form of asking forgiveness and doing merit (as the lighted candle floats away down the river on a lotus leaf, it symbolizes "all that the sender wanted to get rid of"), and have

reloaded this ceremony by employing it as a means of asking forgiveness and giving thanks, not to a river god, but to the God of the Universe. Believers who have learned to reload their cultural forms are "dynamically equivalent churches," according to Davis and to other missiologists such as William Smalley. Such believers "live out their life, including their socialized Christian activity, in the patterns of the local society...."

Chapter 7, "Power Encounter," challenges us to be students of the various manifestations of spiritual power in Southeast Asia, since most of us "do not have all the facts nor do we have an adequate theology that gives us the answers!" But Davis also says let us be hopeful and expect for God "to pour out His Spirit ... all the signs and wonders promised ... have not yet been fulfilled—let us look keenly for them and opt for nothing less."

The final chapters, 8 to 10, are brim full of practical information. We are encouraged to make liberal use of the dramatic arts in both live performances as well as the electronic media. Contextualized radio dramas have recently been greeted with "an amazing change in response." The use of ancient stories and epics can provide an entry point into the culture. Davis' discussion of redemptive analogies or "the Eye-Opener" is particularly germane to our context in Cambodia. Especially so is his treatment of the prophesy regarding "the one Messiah who is foremost in Buddhists' aspirations and prayer," Pre Sayamitray (Metteya), which is usually translated "Prince of Peace." Davis reports that Dr. W. C. Dodds, a missionary to Thailand over 100 years ago, discovered the other name of Metteya, Ariya, comes from Sanskrit and means "high born." Dodd "proceeded to show that Jesus is Highest born of all who ever came to earth, and that he is all merciful." Davis observes, "It is highly probable that many of the early Christians in Thailand became Christian because they saw Christ, as the fulfillment of this ancient prophesy."

Chapter 10, a new addition to the revised edition, contains an excellent review of leadership structures found in the church today. It comprises an articulate and poignant critique of worldly leadership styles which have crept into many churches, especially

Asian congregations. Finally, Davis helps us to review our hermeneutics; he does so via a clear outline of the five "irreducible components" which should be found in every truly New Covenant Church regardless of culture.

សំណុំឌីកឃ្មុំ ១/១ (កក្កដា ២០០០): ៨៥-៩២

# ពិនិត្យមើលឡើងវិញក្នុងសៀវភៅ

*Davis, John R. Poles Apart?*

*Rev. Bangalore, India: Theological Trust, 1998, 285 pp.*

*******

Poles Apart by John R. Davis គួរត្រូវបានគេពិចារណាថាជាសៀវភៅពី បូរាណ នៅក្នុងស្រទាប់អស់អ្នកដែលបានស្វែងរកនូវរបៀបផ្សាយដំណឹងល្អដល់ពួកអ្នកកាន់ពុទ្ធសាសនាក្នុងទ្វីបអាស៊ី ដើម្បីឲ្យស៊ីនឹងស្ថានការណ៍ និងមានន័យ គ្រប់គ្រាន់ចំពោះការងារនោះ ។ Davis ឥឡូវនេះចូលនិវត្តន៍ហើយគាត់បានចែក រំលែកនូវបទពិសោធន៍របស់គាត់ដ៏ស្ដួចស្ដើង យ៉ាងសទ្ធាជាទីបំផុតក្នុងនាមគាត់ ជាបេសកជន នៅក្នុងប្រទេសថៃ ។ គាត់បានសញ្ជឹងគិតយ៉ាងអស់ពីចិត្តអំពីទំនៀមទំលាប់ផ្នែកហិនយាន ពុទ្ធសាសនា/ទេវតា ពុទ្ធសាសនាដើម្បីឲ្យកាន់តែយល់ច្បាស់លាស់ថែមទៀត គាត់បានលើកជាសំណើឲ្យមានការ កែប្រែដ៏ជាក់លាក់ខ្លះៗ ចំពោះយុទ្ធសាស្ត្រសំរាប់បេសកកម្ម នៅក្នុងផ្នែកដែលមានទំនៀមទំលាប់បែបនេះ ។ គាត់ក៏បានលើកទឹកចិត្តយើង ឲ្យទទួលយកនូវកំហុសទាំងឡាយ ដែលបេសកជនបានធ្វើខុស កាលពីជំនាន់ដើម ឲ្យគិតរិះគន់ពីរបៀបធ្វើការងាររបស់យើង ហើយនិង ឲ្យគិតឡើងវិញ ពីយុទ្ធសាស្ត្ររបស់យើងពីក្រោមឡើងទៅ ។ ទោះបីជាការងារបោះពុម្ពលើកទីមួយ បានបោះពុម្ពផ្សាយនៅក្នុងឆ្នាំ ១៩៩៣ ក៏ដោយ សៀវភៅនោះ បានផ្ដោតសំខាន់ទៅលើសង្គមថៃ តែនៅក្នុងការបោះលើកទី ២ ដែលមានការកែសម្រួលឡើងវិញខ្លះៗ "អ្នកនិពន្ធស្វែងរកនូវការអនុវត្តន៍ដ៏សមរម្យមួយ សំរាប់ជនជាតិ និង ស្ថានការណ៍ទាំងឡាយនៃទ្វីបអាស៊ីទាំងមូល ។ គាត់បានបន្ថែមជំពូកថ្មី ដែលទាក់ទងនឹងរចនាសម្ព័ន្ធ និង ការដឹកនាំក្រុមជំនុំនៅក្នុងទ្វីបអាស៊ីសព្វថ្ងៃនេះ" ។

ទោះបីជាអត្ថន័យមួយចំនួនធំ ដែលសរសេរផ្ដោតលើតែយុទ្ធសាស្ត្របេសកកម្មក៏ដោយ តាមយោបល់របស់ Davis គាត់ថា ការផ្សាយដំណឹងល្អមិន

ទាន់បានទទួលនូវការអបអរសាទរ ឬ ទាមទារឲ្យមានការសិក្សាឲ្យបានល្អិតល្អន់ចំពោះផ្នែកនេះឡើយ ។ សេចក្តីត្រូវការកាន់តែមានច្រើនឡើងៗ ផ្នែកបេសកជនជួរមុខ ដែលកំពុងប្រឈមមុខនឹងក្រុមអ្នកកាន់លទ្ធិពុទ្ធនិយម ដែលមានគំនិតលាយឡំគ្នា និងជំនឿលើអារុក្ខអារក្សអ្នកតា ព្រមទាំងជំនឿហិណ្ឌូ ។ ទោះជាយ៉ាងណាក៏ដោយ មានមនុស្សជាច្រើននៅតែមានកំហឹងនៅឡើយ នៅពេលដែលគេធ្វើការងារ មិនថាឡើយអ្នកដឹកនាំនោះ ជាជនបរទេស ឬ ជាអ្នកស្រុកឡើយ នៅពេលដែលគេពើបប្រទះជាមួយមនុស្ស ដែលទំនងដូចជារឹងទទឹង "ដំណឹងល្អ" ។ ពួកគេត្រូវតែយល់ថា ការរៀនពីពុទ្ធសាសនាផ្នែកហិនយាន នៅក្នុងថ្នាក់នោះ វាមិនគ្រប់គ្រាន់ឡើយ តែការសំខាន់នោះគឺថា គេអាចរៀនពីរបៀប ដែលត្រូវទាក់ទងជាមួយក្រុមអ្នកកាន់ពុទ្ធសាសនា និង ព្រហ្មញ្ញសាសនាតាមទំនៀមទំលាប់របស់គេបានច្បាស់ជាង ដែលតាមពិតទៅយើងប្រទះឃើញទៅតាមផ្សារ តាមភូមិនានា និង តាមផ្លូវនៃប្រទេសក្នុងទ្វីបអាស៊ី ។ លោក Davis ចំណាយពេលជាង ៣០ ឆ្នាំ ក្នុងការសញ្ជឹងគិតលើប្រព័ន្ធជំនឿពិតប្រាកដ ដោយមានទស្សនៈដោះស្រាយនូវវិបត្តិនៃការប្រឆាំងតបតមកវិញនោះ ។ ប្រទេសថៃ ជាប្រទេសកាន់ពុទ្ធសាសនាប្រហែល ៩៩,៩% ។

ការគូសបញ្ជាក់គួរឲ្យសោកស្តាយមួយនៃប្រទេសថៃ ផុសចេញពីសេចក្តីផ្តើមរបស់ Pole Apart ។ បេសកជនល្អៗ ភាគច្រើនបានទន្ទេញ យ៉ូហាន ៣:១៦ មិនមែនគ្រាន់តែចាំនៅក្នុងចិត្តប៉ុណ្ណោះទេ តែក៏ចាំទាំងភាសាមួយ ដែលអាចស្តាប់បានទៀតផង ។ គាត់អាចមានការលើកទឹកចិត្ត ដោយញញឹមតបយ៉ាងរាក់ទាក់ ដាក់មិត្តភក្តិថ្មីរបស់ខ្លួនដោយស្រង់យក យ៉ូហាន ៣:១៦ ។ ប៉ុន្តែ តើអ្នកស្តាប់យើងនោះពិតជាបានឮយើងនិយាយមែនឬ? Davis ថ្លែងថា "ដោយមានការគោរពដល់ចិត្តសាទររបស់បេសកជន តាមពិតទៅបេសកជនទាក់ទងដោយមិនសូវប៉ិនប្រសប់សោះ ។ ដោយប្រើពាក្យសំដីផ្ទុយពីគំនិតទាំងឡាយ ។ " បើយើងឃើញបញ្ហា ដែលចេញពីការយល់ឃើញរបស់ពួកអ្នកជឿពុទ្ធសាសនាចំពោះព្រះជាម្ចាស់ ដែលស្រឡាញ់មនុស្សដល់ម្ល៉េះ តាមអ្នកកាន់ពុទ្ធសាសនាអាចមានច្រើន ពាក្យដែលថា ព្រះ នេះ ដូចជា ព្រះអាទិត្យ ព្រះច័ន្ទ ផ្កាយព្រះអង្គារ ព្រហស្បតិ៍ នៅក្នុងរាជវង្សស្តេចក៏ប្រើពាក្យ ព្រះ ដែរ លោកសង្ឃក៏ប្រើពាក្យ ព្រះ ដែរ តាមសាសនាហិណ្ឌូក៏ប្រើពាក្យ ព្រះ កន្លែងពិសិដ្ឋនានា ឬក៏ រូបសំណាក

ព្រះពុទ្ធទាំងអស់នោះសុទ្ធតែប្រើពាក្យ ព្រះ ដូចគ្នា ។" កាលពីដំបូងអ្នកស្តាប់ ច្រឡំ ដោយព្រោះថា គាត់មិនគិតដល់ការប្រើពាក្យ "ព្រះ" (ព្រះថៅ) នៅក្នុង របៀបមួយ ដែលប្លែកពីគេ ។ អ៊ីចឹងការយល់ច្រឡំរបស់គាត់ គឺកាន់តែកើនឡើង ទៀត ដោយការដែលពួថា ព្រះ នេះហើយ ដែលស្រឡាញ់គាត់ ។ ចំពោះគាត់ សេចក្តីស្រឡាញ់កាន់តែធ្វើឲ្យមានភាពទន់ខ្សោយថែមទៀត ដោយហេតុថា "គ្រប់ទាំងការប៉ងប្រាថ្នាទាំងអស់ ទោះល្អ ឬ អាក្រក់ក្តី ក្នុងពុទ្ធនិយម គឺសុទ្ធតែអាក្រក់ទាំងអស់ ទាំងទំនាក់ទំនង និងការសេពគប់នោះគឺសន្មតិថាមិនល្អរួចទៅហើយ"។ តាមពិតទៅទិសដៅរបស់អ្នកកាន់សាសនាព្រះពុទ្ធដ៏ស្មោះស្ម័គ្រនោះគឺថា ខំគេចឲ្យផុតពីកិលេសនៃការប៉ងប្រាថ្នា និង ការសេពគប់នានា ។ អ្នកស្តាប់ ដែលមានទឹកមុខញញឹមនោះកំពុងគិតថា "ព្រះជាម្ចាស់នេះ ព្រះអង្គខ្វះអ្វីម្យ៉ាង ព្រះអង្គមានអ្វីៗមិនគ្រប់គ្រាន់ឡើយ" ។ ហេតុអ្វីចាំបាច់ឲ្យព្រះអង្គស្រឡាញ់លោកិយ និង មនុស្សធ្វើអ្វីទៀត? Davis គូសបញ្ជាក់បង្ហាញទៀតថា ចំណុចសំខាន់ៗ ដែលល្បីជាងគេបង្អស់នោះ គឺថាការមិនយល់ពីមូលដ្ឋានគ្រឹះ ។ ដូច្នេះតើយើងត្រូវធ្វើអ្វី?

ចំណុចសំខាន់នោះគឺថា ខ្ញុំបានឮ Davis និយាយថា៖ យើងត្រូវតែធ្វើការងាររបស់យើង រំលឹកឡើងវិញពីផ្នែកទាំងឡាយ ដែលមិនអាចបង្រួញឲ្យតូចបាននៃការផ្តើមឡើងនៃពួកជំនុំ ដែលស្របតាមគម្ពីរ ធ្វើការវិភាគលើទំនៀមទម្លាប់របស់យើង ជៀសវាងការញាត់គំនិតបែបផែនលោកខាងលិចរបស់យើង ទៅក្នុងបំពង់កនៃជនជាតិអាស៊ី ហើយនិង ចូរឆ្លើយតបទៅនឹងបញ្ហា ដែលទាក់ទងនឹងចិត្តគំនិតពិតៗរបស់ពួកអ្នកពុទ្ធនិយម ។ ចំពោះការនេះយើងត្រូវគិតទាំងការយល់ដឹងពីទំនៀមទម្លាប់របស់គេ ហើយនិងការរិះគន់នៃបទគម្ពីរចំពោះបញ្ហានេះ បើពុំនោះទេ មានសេចក្តីថាយើងនឹងគ្រាន់តែនាំចូលនូវរបៀបរបបនៃលោកខាងលិច ឬ ការឲ្យតម្លៃនៃទម្លាប់មិនល្អតែប៉ុណ្ណោះ សំខាន់ដូចគ្នានោះគឺការយល់ដឹងដ៏ត្រឹមត្រូវនៃការសម្រេចតាមស្ថានការណ៍ ដោយគ្មានរិះគន់ច្រើន (បកស្រាយនៅក្នុងជំពូក ១ និង ២) ។ លទ្ធិពុទ្ធនិយមរបស់ជនជាតិថៃ អាចផ្តល់ឲ្យព្រះគ្រីស្ទជា "ព្រះអង្គដ៏ធំ" នៅក្នុងចំណោមព្រះទាំងឡាយ ប៉ុន្តែមិនបានទទួលស្គាល់ព្រះអង្គជា ស្តេចលើអស់ទាំងស្តេច ហើយនិងជាព្រះអម្ចាស់លើព្រះអម្ចាស់ឡើយ ។

នៅក្នុងជំពូក ៣ Davis ដោះស្រាយនូវបញ្ហា ដែលមានគតិលោក ដោយប្លែកពីគ្នាហួសហេតុពេក ដោយក្លាហាន គឺថា អ្វីៗដែលលោកខាងលិចជឿលើធម្មជាតិនោះ វាផ្ទុយគ្នានឹងការជឿលើផ្នែកសៃយសាស្ត្ររបស់ពួកនៅអាស៊ី ។

នៅក្នុងសង្គមណាក៏ដោយ ដែលប្រកាន់យក គតិលោកផ្នែកសៃយសាស្ត្រនោះ គឺមើលមិនឃើញ "ពិភពផ្សេង" ឡើយ ទោះនៅជុំវិញខ្លួន ខាងលើ និង ខាងក្រោម គតិលោកបែបនេះ ជ្រាបចូលគ្រប់ស្រទាប់ទាំងអស់ ដែលទាក់ទងនឹង "ការដ៏អស្ចារ្យ" ដូចជាជម្ងឺ ដែលគេយល់មិនបាន ឧបទ្រពចង្រៃនានា វិបត្តិនៅក្នុងគ្រួសារ គ្រោះថ្នាក់ផ្សេងៗ ការវិលត្រឡប់មកវិញចំពោះអ្នកដែលស្លាប់ហើយ ងើបមកវិញ បណ្តាលឲ្យមានគ្រោះមហន្តរាយផ្សេងៗ . . ." ។ ទោះបីជាយ៉ាងណាក៏ដោយ គាត់បានសង្កេតឃើញជាបន្តទៀត "ផ្នែកវេជ្ជសាស្ត្រពួកលោកខាងលិច ហាក់បីដូចជាមិនមានចម្លើយទៅនឹងបញ្ហា និង ការវាយតម្លៃរបស់ពួកខាងកើតឡើយ . . ." ការនេះមកពីការយល់មិនដល់នូវហេតុផល សំខាន់ដែលថាហេតុអ្វីបាន "ជាផ្នែកទេវសាស្ត្រទាំងមូល ដែលបានផ្តល់ឲ្យជន ជាតិថៃអាចជ្រាបចូលបានតែសើរៗតែប៉ុណ្ណោះ" ។ ហេតុដូច្នេះ ទើបត្រូវការយ៉ាងចាំបាច់ដើម្បី "បង្កើតទេវសាស្ត្រ និង ការអនុវត្តន៍ តាមបែបគ្រប់ជ្រុងជ្រោយមួយឡើង ដែលរកដំណោះស្រាយមួយឡើងបាន ចំពោះបញ្ហាពិតប្រាកដនៃគតិលោកបែបសៃយសាស្ត្រនោះ" ។

ដើម្បីពិភាក្សាគ្នា បន្ថែមទៀតនៅក្នុងជំពូក ៣ Davis បានបន្ថែមនូវមេរៀនមួយដ៏មានតម្លៃ លើការកែប្រែលើអត្ថបទបោះពុម្ពរបស់គាត់ ដែលគូសបង្ហាញពីការប្រាស្រ័យទាក់ទងជាប្រចាំថ្ងៃជាមួយនឹង "ពិភពដទៃ" ។ ឧទាហរណ៍ នៅក្នុងការសាងសង់ផ្ទះនៅក្នុងបណ្តាប្រទេស ក្នុងភូមិភាគអាស៊ីអាគ្នេយ៍ មានការទាក់ទងនឹងការប្រុងប្រៀបយ៉ាងល្អិតល្អន់ជាច្រើន ។ មានការរៀបចំធ្វើពិធីផ្សេងៗ ដើម្បីធានាឲ្យមានសេចក្តីសុខសាន្ត និង សេចក្តីចំរុងចំរើនដល់អ្នក ដែលត្រូវមកតាំងទីលំនៅថ្មីនោះ ។ "ដំបូងគ្រូមើលរាសី ត្រូវរកវេលាល្អ សំរាប់ការសាងសង់ ហើយនិងរកទីកន្លែងដ៏ពិតប្រាកដសំរាប់សង់ផ្ទះនោះ . . . នៅពេលដែលកន្លែងរកបានច្បាស់លាស់ហើយ ចាំបាច់ត្រូវរកគ្រូ ដែលពូកែមកសូត្រធម៌ផ្សេងៗ បើអ្នកដែលសូត្រនោះជាសង្ឃ ត្រូវសូត្រជាភាសាបាលី បើអ្នកនោះជា គ្រហស្ថ ត្រូវផ្តល់សាគុណជាអំណោយផ្សេងៗ ប្រោសទឹកមន្ត ដាក់ទៀន ធូប ផ្កាភ្ញី នៅលើដី

ដែលត្រូវសាងសង់ផ្ទះនោះ . . . ” មានចំណុចសំខាន់ខ្លះទៀត ដែលត្រូវធ្វើ ដូច ជាការជ្រើសរើសឈើដ៏ត្រឹមត្រូវល្អ ដែលគាប់ចិត្តដល់វិញ្ញាណអ្នកម្ចាស់ស្រុក (ឈើខ្លះធ្វើឲ្យវិញ្ញាណចូលចិត្ត តែឈើខ្លះទៀត មិនសូវឲ្យវិញ្ញាណចូលចិត្តទេ) ការជ្រើសរើសនោះ ត្រូវតែដាក់ឲ្យត្រូវស្របតាមទិសដៅត្រឹមត្រូវ ជម្រៅនៃរណ្ដៅ សសរនិមួយៗ ត្រូវតែតាមពាក្យគ្រូទាយ រណ្ដៅសសរទីមួយ ត្រូវដាក់ដង្វាយ ជាកាក់ ដោយដាក់កាក់នោះចូលទៅក្នុងរណ្ដៅ តាមក្រិត្យក្រមរបស់លោកគ្រូ មើលវេលា រណ្ដៅដទៃទៀតក៏ត្រូវធ្វើតាមការណែនាំទៅតាមនោះដែរ (តាមពិត ការសាងសង់ មិនទាន់បានចាប់ផ្ដើមនៅឡើយទេ) មួយជំហានចុងក្រោយគេនោះ គឺថា “ក្រណាត់ក្រហម និង ស មួយផ្ទាំង ដែលមានចារយ័ន្តនៅលើនោះ” ត្រូវ យកមកដាក់នៅលើសសរកន្លោង ។ តាមរយៈនៃឧទាហរណ៍នេះអាចដឹងថា ជីវិតរស់នៅប្រចាំថ្ងៃ “ពួកអ្នកស្រុក ដែលកាន់តាមពុទ្ធនិយម មិនបានយល់ឃើញ អ្វីដូចជា “ពួកមិនជឿអ្វីទាំងអស់” ឬ ពួកអ្នកមិនជឿលើពិភពខាងវិញ្ញាណ” ។ Davis បាន គូសបញ្ជាក់បន្ថែមទៀត ដោយពណ៌នាពីកូនខ្ទមតូចៗ គគោកគដី និង កន្លែង ដោតជើងធូប ដែលបានគិតថាជា កន្លែងវិញ្ញាណរបស់អ្នកតាម្ចាស់ស្រុក ឬ ជំនាង ផ្ទះ ។ លើសពីនេះទៀត គឺជាលំដាប់ថ្នាក់នៃ “វិញ្ញាណនៃអ្នកតាម្ចាស់ ស្រុក” ។ Davis បានបន្ថែមពត៌មានថ្មីៗ ជាច្រើននៅក្នុងការបោះពុម្ពជាលើកទី ២ របស់គាត់ នៅក្នុងជំពូកទី ៣ ។ ទាំងពីរ គឺជំពូក ៤ “ទេវសាស្ត្រនៅក្នុងស្រុក” ហើយនិង ជំពូក ៥ “លក្ខណៈនៃការរងឈឺចាប់” (គ្មានក័ណ្ឌណាមួយ ដែលស្ដីពី ពុទ្ធសាសនា អាចមើលរំលងមេរៀននេះឡើយ ) បានទទួលនូវការកែប្រែ និង ស្រាវជ្រាវ យ៉ាងច្រើន ។ ចំពោះពុទ្ធសាសនិកជន មានរូប គឺមានទុក្ខ ។ មានតែផ្លូវ មួយគត់ ដែលអាចរត់គេចពីការរងទុក្ខ ដោយសារមានការយល់ដឹងត្រឹមត្រូវ (ឃើញផ្លូវល្អ ច្បាស់) គឺថា ត្រូវយល់ថា រងទុក្ខ “នឹងគ្មានទៀតឡើយ បើគ្មាន កិលេស/ការប៉ងប្រាថ្នា ។ ” ជំពូក ៥ ក្នុងការបោះពុម្ពលើកទី ២ ដែលមានការកែ ប្រែមានចុះបញ្ជី នៃប្រយោគពន្យល់នៅខាងក្រោម ៦៨ កន្លែង ។ នៅដើមជំពូក ៦ អ្នកនិពន្ធផ្ដល់ ឲ្យយើងនូវការយល់ដឹងដ៏ល្អអំពីរបៀប ដែលយើងឲ្យបកស្រាយ ដែលស៊ីនឹង ស្ថានការណ៍ដ៏ត្រឹមត្រូវ ។ គាត់និយាយដោយមានប្រយោជន៍បំផុត ដែលថា “គ្រប់ការសូត្រធម៌ ការធ្វើពិធីផ្សេងៗ និង បុណ្យទាននានា ត្រូវបាន

យើងសង្កេតដោយប្រុងប្រយ័ត្ន ទុកជាយានដ៏សំខាន់សំរាប់សេចក្តីពិតគ្រីស្ទបរិស័ទ " ។

ប៉ុន្តែទម្លាប់ដ៏ច្រើនលើសលប់នោះ បានបែងចែកជាផ្នែកច្រើន "បើមិនបានប្រកាន់យកឲ្យច្បាស់លាស់ទេនោះ ឬ ខ្ជីខ្ជារនោះ សង្គមនឹងរាប់ថាជា "អំពើបាប" ដែលមនុស្សទាំងឡាយដឹងថា មិនសូវសំខាន់ ។ ពិធីខ្លះ គឺជាពិធីពុទ្ធសាសនាសុទ្ធសាធ ឯពិធីខ្លះទៀតជាពិធីធ្វើតាមទំនៀមទម្លាប់ទៅវិញ ។ ក្នុងការកំណត់ឲ្យស្គាល់ពីការនោះ (មិនមែនជាការងាយស្រួលឡើយ) បេសកជនអាចលើកទឹកចិត្តឲ្យប្រើទម្រង់បែបបទនៃពិធីបុណ្យនោះ ទុកជារបស់សំរាប់ដាក់បញ្ចូលអ្វីៗដែលថ្មី ។ ត្រង់នេះ Davis ហៅថា "ការដាក់បញ្ចូល" វិស័យគ្រីស្ទបរិស័ទ និង អត្ថន័យថ្មីនោះ ចូលទៅក្នុងទំនៀមទម្លាប់របស់អ្នកនៅក្នុងស្រុក ។ ឧទាហរណ៍ គ្រីស្ទបរិស័ទថៃខ្លះ គេយកពិធីផ្កាឈូកអណ្តែត មកធ្វើជាពិធីបុណ្យនៃការអត់ទោសបាប និង ពិធីសន្សំកុសល (នៅពេលដែលដុតទៀនបណ្តែតចុះតាមដងទន្លេ ដាក់លើស្លឹកឈូក ជានិមិត្តរូបថា "គ្រប់ទាំងអ្នកបណ្តែតទៀនទាំងអស់ ចង់បំបាត់នូវការអាក្រក់ទាំងឡាយ") ហើយគេបានកែពិធីនេះ ឲ្យទៅជាពិធីមួយ ដែលមានន័យថា សុំការអត់ទោសពីព្រះជាម្ចាស់ និង អរព្រះគុណដល់ព្រះជាម្ចាស់ទៅវិញ មិនមែនជាពិធីបួងសួងដល់ព្រះ ដែលរក្សាដងទន្លេនោះឡើយ ប៉ុន្តែបែរទៅរកព្រះជាម្ចាស់នៃចក្រវាឡទាំងមូល ។ ពួកអ្នកជឿ ដែលរៀនពូកែប្រែទំនៀមទម្លាប់របស់គេឲ្យទៅជា "របៀបមួយ ដែលមានកម្លាំងខ្លាំងដូចគ្នា នឹងពួកជំនុំដែរ" យោងតាម Davis ហើយនិង យោងតាមអ្នកសិក្សាផ្នែកបេសកកម្មដទៃទៀត ដូចជាលោក វ៉ាលឡាម ស្មលី ។ ពួកអ្នកជឿបែបហ្នឹង "រស់នៅក្នុងជីវិតរបស់គេ ដែលគិតបញ្ចូលទាំងសកម្មភាពទាំងឡាយរបស់គេ តាមបែបសង្គមគ្រីស្ទបរិស័ទ នៅក្នុងគំរូរបស់សង្គមរស់នៅតាមតំបន់ . . . " ។

ជំពូក ៧ "ការប្រទាំងគ្នាជាមួយនឹងអំណាចអារក្ស" ជំរុញឲ្យយើងដឹងអំពីអំណាចខាងឯវិញ្ញាណផ្សេងៗ នៅក្នុងអាស៊ីប៉ែកអាគ្នេយ៍នេះ ដោយហេតុថា យើងភាគច្រើន "មិនមានហេតុការណ៍ ឬ មិនមានទេវសាស្ត្រគ្រប់គ្រាន់ ដែលផ្តល់ឲ្យយើងនូវចម្លើយទាំងនោះឡើយ!" ប៉ុន្តែ Davis បាននិយាយផងដែរថា ចូរយើងសង្ឃឹមយ៉ាងមុតមាំ និង តម្រូវឲ្យព្រះជាម្ចាស់ "ចាក់ព្រះវិញ្ញាណបរិសុទ្ធរបស់ព្រះអង្គ . . . គ្រប់ទាំងទីសំគាល់ និង សេចក្តីសន្យា . . . ទាំងឡាយ យើង

មិនទាន់បានទទួលនៅឡើយ ចូរយើងខំរកមើលរបស់ទាំងនោះ និង កុំជ្រើសរើសរកអ្វី ដែលគ្មានអំណាចនោះឡើយ ។

ជំពូកចុងក្រោយ ពី ៨ ទៅ ១០ ដែលពេញហៀរនូវពត៌មាន អនុវត្តជាក់ស្តែង ។ ជំរុញឲ្យយើងប្រើដោយសេរី នូវផ្នែកសិល្បៈនៃការបង្ហាញពីជីវិតរស់នៅ ក៏ដូចគ្នានឹងការប្រើប្រព័ន្ធផ្សព្វផ្សាយដែរ ។ ការផ្សាយតាមវិទ្យុ ដែលសម្របសម្រួលឲ្យស៊ីនឹងស្ថានការណ៍នៅពេលថ្មីៗនេះ បានទទួលនូវការស្វាគមន៍ដោយ "មានការផ្លាស់ប្តូរគួរឲ្យកត់សំគាល់ក្នុងការឆ្លើយតបមកវិញ ។" ការប្រើរឿងពីបូរាណ និងរឿងប្រវត្តិសាស្ត្រ អាចជួយផ្តល់ឲ្យនូវច្រកចូលទៅក្នុងទំនៀមទម្លាប់។ ក្នុងការពិភាក្សា នៃការប្រៀបធៀបពីសេចក្តីប្រោសលោះ ឬ "បើកភ្នែកឲ្យឃើញ" ជាពិសេសនូវភាពស្រដៀងគ្នា នឹងស្ថានភាពរបស់យើងក្នុងប្រទេសកម្ពុជា ជាពិសេសជាងនេះទៅទៀត គឺការបកស្រាយពីទំនាយ ដែលទាក់ទងទៅនឹង "ព្រះមេស្ស៊ី ដែលជាព្រះសំខាន់បំផុត នៅក្នុងការប៉ងប្រាថ្នាយ៉ាងខ្លាំង និង ក្នុងការបួងសួងរបស់ពុទ្ធសាសនា" ព្រះសិរអារ្យមេត្រី ដែលតាមធម្មតាគេបកប្រែថា "ព្រះអម្ចាស់នៃសន្តិភាព" លោក Davis រាយការណ៍ថា លោកបណ្ឌិត W.C. Dodds ជាបេសកជនមកកាន់ប្រទេសថៃ ១០០ ឆ្នាំ មុន បានរកឃើញនូវឈ្មោះផ្សេងទៀតនៃពាក្យ មេត្រីយ៉ា គឺទៅជា អារីយ៉ា ដែលក្លាយមកពីពាក្យសំស្ក្រឹត មានន័យថា "កើតឡើងខ្ពស់ឧត្តម" ។ Dodds "បានបង្ហាញថា ព្រះយេស៊ូ គឺបានកើតមកលើផែនដីនេះខ្ពង់ខ្ពស់លើសគេទាំងអស់ ហើយនិង ព្រះអង្គមានសេចក្តីមេត្តាករុណាលើសគេ ។" Davis សង្កេតឃើញថា "រឿងនេះគាត់សង្ស័យថា ពួកជំនុំថៃជំនាន់ដើម ប្រហែលជាអាចមកពីរឿងនេះ ទើបគេព្រមជឿព្រះគ្រីស្ទ ដើម្បីឲ្យស្របតាមទំនាយពីបុរាណនេះឯង" ។

នៅក្នុងជំពូក ១០ នៅក្នុងសេចក្តីបន្ថែមថ្មីៗ មានការបង្ហាញពីរចនាសម្ព័ន្ធនៃការដឹកនាំ ដែលគេប្រទះឃើញ នៅក្នុងពួកជំនុំសម័យនេះ ។ ការនេះបង្ហាញយ៉ាងច្បាស់ នូវរបៀបនៃអ្នកដឹកនាំតាមបែបលោកិយ គួរឲ្យស្តាយ ដែលបានជ្រាបចូលក្នុងចំណោមពួកជំនុំជាច្រើន ជាពិសេស ពួកជំនុំនៅទ្វីបអាស៊ីនេះឯង ។ ទីបំផុត Davis ជួយឲ្យយើងរំលឹកឡើងវិញពីការបកស្រាយរបស់យើង គាត់បានធ្វើដូច្នេះតាមរយៈគោលការណ៍ទាំងប្រាំ "ដែលមិនអាចបន្ថយឲ្យតូចបាន"

យ៉ាងច្បាស់លាស់ ដែលយើងអាចរកឃើញនៅក្នុង សន្និសញ្ញាថ្មី របស់ពួកជំនុំ ដោយមិនខ្វល់ពីទំនៀមទម្លាប់ឡើយ ។